វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

# បណ្តុំសំណេរតែងសេចក្តី

## ថ្នាក់ទី ១០.១១.១២

## ភាគ ១

**រួមមាន ៖**

- ប្រធានពន្យល់
- ប្រធានពិភាក្សា
- ប្រធានប្រៀបធៀប



និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆារ៉ា

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ គឺមានសារៈសំខាន់ណាស់នៅក្នុងពេលបច្ចុប្បន្ននេះ មិនថាបុគ្គលិកក្នុងស្ថាប័ននានា មនុស្សក្នុងសង្គមទូទៅពិសេសអ្នកកំពុងសិក្សា ស្វែងរកចំណេះដឹង ត្រូវការជាចំបាច់នូវការអាន ការស្ដាប់ ការកត់ត្រា និងការសាកសួរ ឬស្រាវជ្រាវបន្ថែមនូវរាល់ចម្ងល់ដែលខ្លួនមាន។ ដើម្បីឱ្យការសិក្សារបស់ខ្លួនពេញលក្ខណៈ ឬសិក្សាដោយមិនខាតបង់នូវពេលវេលា សិក្សាដើម្បីទទួលបាននូវផ្លែផ្កានាពេលខាងមុខ។

តាមរយៈស្នាដៃនិពន្ធ និងស្រាវជ្រាវនេះ គឺបានធ្វើឱ្យអ្នកអាន អ្នកសិក្សា និងបានយល់កាន់តែច្បាស់អំពីវិធីសាស្ត្រនៃការសរសេរសំណេរ ហើយធ្វើឱ្យអ្នកអាន អ្នកសិក្សា អាចសរសេរយ៉ាងណាឱ្យបានល្អ សរសេរយ៉ាងណាឱ្យត្រូវប្រធាន កុំបកស្រាយចាកប្រធាន សរសេរតាមបរិបទនៃប្រធានសំណេរ ពិសេសធ្វើឱ្យអ្នកអាន អ្នកសិក្សាស្គាល់ពីលក្ខណៈនីមួយៗរបស់ប្រធានសំណេរ និងចេះពីការធ្វើគ្រោងឆ្អឹងសំណេរ។

តែទោះជាយ៉ាងណាក៏ស្នាដៃនេះគ្រាន់តែជាកិច្ចការស្រាវជ្រាវប៉ុណ្ណោះមិនទាន់មានលក្ខណៈល្អឥតខ្ចោះឡើយ តែអាចឱ្យអ្នកអាន អ្នកសិក្សាយកទៅធ្វើជាគំរូ ឬសិក្សាត្រួសៗបានយ៉ាងងាយស្រួល ហើយវាអាចជួយអ្នកសិក្សាឱ្យមានចំណេះដឹង បន្ថែមលើចំណេះដឹងដែលមានស្រាប់។ លើសពីនេះ ខ្លឹមសារនៃការស្រាវជ្រាវរបស់អ្នកគ្រូនៅមានកម្រិតពុំទាន់មានលក្ខណៈវិទ្យាសាស្ត្រ ជាសកលហើយក៏មិនទាន់ស៊ីជម្រៅលើការស្រាវជ្រាវនៅឡើយ ដែលបណ្ដាលឱ្យមានចំណុចខ្វះចន្លោះឆកល្វែងទាំងឡាយ និងកើតឡើង

ដោយអចេតនាជាក់ជាពុំខាន។ អាស្រ័យដូចបានជម្រាបខាងលើ សូមលោកគ្រូ អ្នកគ្រូ និងមិត្តអ្នកសិក្សាស្រាវជ្រាវ និងកូនសិស្សជាទីរាប់អានមេត្តាជួយបំពេញបន្ថែមព្រមទាំង មេត្តាអធ្យាស្រ័យរាល់ចំណុចខ្វះខាតទាំងនេះ។

សូមឱ្យព្រលឹងអក្សរសាស្ត្រខ្មែរស្ថិតនៅគង់វង្សរីកចម្រើនក្នុងដួងចិត្តកុលបុត្រកុលធីតាខ្មែរគ្រប់ជំនាន់តទៅ។ ស្នាដៃមួយនេះកើតឡើងជារូបរាងបាន ដោយសារតែសេចក្ដីស្រឡាញ់ ដែលមានចំពោះកូនសិស្សគ្រប់គ្នា!!!

# មាតិកា


អារម្ភកថា

សេចក្ដីថ្លែងអំណរគុណ

លំនាំផ្ដើមសេចក្ដី.................................................................1

ប្រធានទី............................................................................ 3

ប្រធានទី២.......................................................................... 7

ប្រធានទី៣ ....................................................................... 12

ប្រធានទី៤........................................................................ 17

ប្រធានទី៥........................................................................ 24

ប្រធានទី៦ ........................................................................ 27

ប្រធានទី៧........................................................................ 31

ប្រធានទី៨........................................................................ 36

ប្រធានទី៩ ........................................................................ 40

ប្រធានទី១០ ..................................................................... 46

ប្រធានទី១១ ..................................................................... 50

ប្រធានទី១២ ..................................................................... 56

ប្រធានទី១៣ ........ 62
ប្រធានទី១៤ ........ 66
ប្រធានទី១៥ ........ 69
ប្រធានទី១៦ ........ 75
ប្រធានទី១៧ ........ 79
ប្រធានទី១៨ ........ 81
ប្រធានទី១៩ ........ 84
ប្រធានទី២០ ........ 88
ប្រធានទី២១ ........ 91
ប្រធានទី២២ ........ 95
ប្រធានទី២៣ ........ 100
ប្រធានទី២៤ ........ 104
ប្រធានទី២៥ ........ 107
ប្រធានទី២៦ ........ 112
ប្រធានទី២៧ ........ 116
ប្រធានទី២៨ ........ 121
ប្រធានទី២៩ ........ 128
ប្រធានទី៣០ ........ 131
ប្រធានទី៣១ ........ 139
ប្រធានទី៣២ ........ 143
ប្រធានទី៣៣ ........ 147
ប្រធានទី៣៤ ........ 151

ប្រធានទី៣៥ ........................................................................ 155
ប្រធានទី៣៦ ........................................................................ 159
ប្រធានទី៣៧ ........................................................................ 167
ឯកសារយោង ........................................................................

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាង ជ្រាលជ្រៅចំពោះលោកអ្នកមានគុណទាំងពីរដែលបានបូជានូវសាច់ស្រស់ ឈាមស្រស់ ក្នុងការតស៊ូបំពេញការងារក្នុងការចិញ្ចឹមបីបាច់ ថែរក្សាកូន ទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយគ្មានទាមទារ នូវអ្វី គឺសូមឱ្យតែកូនបានសេចក្តីសុខសុភមង្គល។ ស្នាដៃនេះត្រូវបានចេញពីស្មារតីឆន្ទៈដ៏មុតមាំរបស់អ្នកគ្រូ ឯកទេសអក្សរសាស្ត្រខ្មែរ។ អរគុណចំពោះ

- ពុកម៉ែ ដែលផ្តល់កំណើត ផ្តល់សំភារៈ ផ្តល់កម្លាំងចិត្ត ផ្តល់សេចក្តីស្រឡាញ់ ផ្តល់...គ្រប់យ៉ាង
- បងប្អូន ដែលផ្តល់ជាគំនិត យោបល់ លុយកាក់ ជំរុញទឹកចិត្ត...
- លោកគ្រូ អ្នកគ្រូ ដែលផ្តល់នូវចំណេះដឹង ការអប់រំទូន្មាន ផ្តល់ចំណង់មិត្តភាព...
- មិត្តភ័ក្ត ដែលផ្តល់នូវមិត្តភាពដ៏ល្អ បទពិសោធជីវិត...
- កូនសិស្សជាទីស្រឡាញ់ ដែលផ្តល់នូវស្នាមញញឹម ការរាប់អានដ៏ស្មោះត្រង់ ការយកចិត្តទុកដាក់...
- ខ្លួនឯងដែលមានជំហរដ៏រឹងមាំក្នុងឆន្ទៈជាគ្រូបង្រៀន...

ជាចុងក្រោយខ្ញុំសូមគោរពជូនពរ ដល់អ្នកដែលកំពុងតែអាននូវស្នាដៃនេះ ទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច គ្រប់ពេលវេលា ជាពិសេសឱ្យការសិក្សាកាន់តែមានភាពរីកចម្រើនឡើងៗ។

ប្រធានៈ សុភាសិតមួយចែងថា« ខ្លួនទីពឹងខ្លួន»។ ចូរពន្យល់។

## របៀបផ្តើមៈ

**ផ្តើមតាមការចងចាំ ឬប្រើសម្រាប់សុភាសិតៈ**« បុព្វបុរសខ្មែរយើង គឺជាមនុស្សដែលពោរពេញទៅដោយចំណេះដឹងជ្រៅជ្រះ ប្រកបដោយភាពប៉ិនប្រសប់ និងគំនិតច្នៃប្រឌិតខ្ពស់។ ពួកគាត់ស្ទើរតែគ្រប់ជំនាន់បានខិតខំចំណាយពេលពេញមួយជីវិត ហ៊ានបូជាមិនស្តាយស្រណោះនូវកម្លាំងកាយចិត្ត អាយុជីវិត ក្នុងគោលបំណងបង្កើត ឬចងក្រងគ្រប់អ្វីៗទាំងអស់មានទាំងអក្សរ សិល្បៈ ទស្សនសុភាសិត សម្រាប់ជាកេរដំណែលដល់ កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយអនុវត្ត ឬធ្វើការពិចារណា។ ដោយបែបនេះហើយទើបយើងឃើញមានសុភាសិតមួយពោលថា« ខ្លួនទីពឹងខ្លួន»។

តើ...បង្កប់នូវអត្ថន័យយ៉ាងដូចម្តេចខ្លះ?

**ផ្តើមដោយផ្អែកលើអក្សរសិល្ប៍ៈ** តាមការសិក្សាអក្សរសិល្ប៍មិនថាអក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប និងអក្សរសិល្ប៍ប្រជាប្រិយឡើយ យើងឃើញថារាល់ស្នាដៃរបស់អ្នកនិពន្ធសុទ្ធតែមានខ្លឹមសារ និងអត្ថន័យអប់រំទាំងអស់។ ក្នុងនោះផងដែរក្រឡេកមើលស្នាដៃអក្សរសិល្ប៍ប្រលោមលោកទំនើប ដែលជាស្នាដៃរបស់លោក ញ៉ុក ថែមវិញកបានបង្ហាញឱ្យឃើញថា ផ្ទៃរឿង

ទាំងមូលកមានលក្ខណៈអប់រំដល់មនុស្សទូទៅ តាមរយៈតួអង្គ។ ដោយមុននឹងស្លាប់ តាចឹមបានពោលនូវសុភាសិតមួយ« ខ្លួនទីពឹងខ្លួន »។

តើ...............បង្កប់នូវអត្ថន័យយ៉ាងដូចម្តេចខ្លះ?

**ផ្តើមលក្ខណៈស៊ីជម្រៅលើប្រធានៈ** មនុស្សយើងម្នាក់ៗកើតមកលើលោកនេះ រមែងមានបំណងប្រាថ្នា ចង់មានចំណេះដឹង មានទ្រព្យសម្បត្តិ មាសប្រាក់ ចង់សម្រេចនូវភាពជោគជ័យគ្រប់ភារកិច្ចក្នុងដំណើរជីវិតរបស់ពួកគេ។ ជាមួយនឹងភាពជោគជ័យសម្រាប់ឆាកជីវិតមួយនេះ លុះត្រាតែយើងម្នាក់ៗក្រោកឈរឡើង និងមានការភ្ញាក់រឮក ខំស្រវាស្រទេញទើបទទួលបាន មានតែខ្លួនឯងទេដែលអាចជួយខ្លួនឯងបាន។ អាស្រ័យបែបនេះហើយ ទើបមានសុភាសិតមួយពោលថា«ខ្លួនទីពឹងខ្លួន »។

តើ.....................បង្កប់នូវអត្ថន័យយ៉ាងដូចម្តេចខ្លះ?

***ប្រធានទី១៖*** *ភាសិតមួយថា "ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" ។ ចូរពន្យល់។*

## គម្រោងតែង

### ក. សេចក្តីផ្តើម

- *លំនាំបញ្ហា៖សរសេរឱ្យទាក់ទងប្រធាន*
- *ចំណូលបញ្ហា៖ភ្ជាប់ប្រធាន*
- *ចំណោទបញ្ហា៖ចោទសួរបែបពន្យល់*

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី*
- *ពន្យល់ពាក្យ: ទឹកឡើង ទឹកស្រក ស៊ី ត្រី ស្រមោច*
- *ពន្យល់ន័យប្រធាន:*
- *បកស្រាយប្រធាន៖*

***ន័យចំ:*** *មានន័យថាពេលទឹកឡើង.......................។ពេលទឹកស្រក.....................................................។*

✓ ***ពង្រីកន័យប្រធាន:***

ទឹកជាប្រភពដ៏សំខាន់..................តែក៏មានគុណសម្បត្តិ...

- ✓ ត្រីជាសត្វដែលរស់នៅក្នុងទឹក
- ✓ ស្រមោចជាសត្វរស់នៅលើគោក
- ✓ សភាពទឹកឡើង លិចលង់ ល្ហល្ហាច ...លិចភូមិឋាន...
- ✓ ទឹកបង្កគ្រោះថ្នាក់ដល់ជីវៈលើគោក គ្មានជម្រក គ្មានដើមឈើ
- ✓ ស្រមោចខំប្រវេប្រវាលើផ្ទៃទឹក តោងកំណាត់ឈើ... គ្មានចំណីអាហារ
- ✓ ប្រការនេះ...ស្រមោចងាយត្រីចាប់ស៊ី...អស់ឫទ្ធិ ព្រោះមិនអាចយកឈ្នះត្រីបានមានតែបណ្ដោយ
- ✓ សភាពទឹកស្រក គោក រីងស្ងួត...
- ✓ ជីវិតក្នុងទឹកដូចជាត្រី...ក្រៀមស្រកា...មិនអាចតតាំងជាមួយស្រមោច...ត្រីងាប់ ស្រមោចស៊ីតាមចិត្ត...។ ជារួម......................

***ន័យធៀប:*** ទឹកឡើងបីដូចអំណាច ឫទ្ធិ ជ័យជម្នះ...។ ទឹកស្រក អំណាចថយ បរាជ័យ អស់បុណ្យ...។

ត្រី ដូចជា អ្នកមានអំណាច មានទ្រព្យ...។ ស្រមោចដូចជា រាស្ត្រ អ្នកគ្មានអំណាច អ្នកក្សត់ខ្សោយ...។ ដូចនេះគេប្រៀប...

- ***ពង្រីកន័យធៀប***

- ✓ ពេលអ្នកតូចជួបអាសន្ន មានទុក្ខលំបាក...អ្នកមានឥទ្ធិពលធ្វើទុក្ខបុកម្នេញ...
- ✓ អ្នកមានស័ក្ដិយសជិះជាន់អ្នកក្រ គ្មានត្រាប្រណី...
- ✓ កេងប្រវ័ញ្ច ធ្វើបាប មិនផ្ដល់សិទ្ធិ...
- ✓ ធ្វើទារុណកម្មតាមរូបភាពផ្សេងៗ បៀតបៀនជីវិត...
- ✓ នាំឱ្យអ្នកក្រ ...ជិះជាន់...
- ✓ ភាពសង្កត់អ្នកតូចនេះ ធ្វើឱ្យគេចងចាំមិនភ្លេច
- ✓ ប្រការនេះពេលអ្នកតូច...មានឱកាសវិញសងសឹកធ្វើបាបចាស់ដៃ មានគំនុំ...
- ✓ រហូតបាត់បង់ជីវិតដោយសេចក្ដីឈឺចាប់ដែលគេជួបប្រទះ...។

ជារួម.....................................។

- ឧទាហរណ៍៖ **ក្នុងសង្គម**
  - ✓ ចោរលួចគ្រប់ប្រភេទមានកម្លាំង មានអាវុធ...គេខ្លាច ដល់គេចាប់បានវិញ...។
    - ប្លន់ជីមួយចំនួន
  - ✓ **ប្រវត្តិសាស្ត្រ:** លន់ នល់ សម្លាប់ខ្មែរ...............ខ្មែរ...សងសឹកទៅវិញទៅមក
    - ស្ដេចដណ្ដើមរាជ្យស្ដេច

- ✓ **អក្សរសិល្ប៍:**
  - រឿងធនញ្ជ័យ(ធនញ្ជ័យជាមួយសេដ្ឋី)
  - រឿងរាមកេរ្តិ៍( នាងសូរបនខា ជាមួយព្រះរាម
  - រឿងភូមិតិរច្ឆាន( ប្ញាវាំង និងជូន នៅ)
- សរុបសេចក្តី៖

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖
- ទស្សនៈ
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៖** ក្រោយពីបានសិក្សារឿងព្រះវេស្សន្តរ មានទស្សនៈមួយថា " ព្រះវេស្សន្តរជាតួអង្គមានលក្ខណៈជាពោធិសត្វ ផង និងមានលក្ខណៈជាមនុស្សសាមញ្ញផង។ ចូរបង្ហាញលក្ខណៈទាំងពីរនេះរបស់ព្រះវេស្សន្តរ និងលើកអំណះអំណាងពីក្នុងរឿងមកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖សរសេរឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖ភ្ជាប់ប្រធាន
- ចំណោទបញ្ហា៖ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ន័យពាក្យគន្លឹះ
  - ពោធិសត្វ៖ ជាអ្នកកំពុងបំពេញបារមីដើម្បីក្លាយជាព្រះពុទ្ធនៅអនាគតជាតិ។
  - មនុស្ស៖ ជាអ្នកប្រកបទៅដោយកិលេស ជាប់ជំពាក់នឹងភាពលោភលន់ មានកំហុស ចេះខឹង ចេះសើច ចេះយំ ....។

- *ពន្យល់ន័យប្រធាន៖ ដូចនេះ ទស្សនៈខាងលើចង់បង្ហាញថា ព្រះវេស្សន្តរមានលក្ខណៈជាពោធិសត្វដែលកំពុងបំពេញបារមីដើម្បីក្លាយជាព្រះពុទ្ធផង ហើយព្រះវេស្សន្តរក៏នៅមានលក្ខណៈខ្លះដូចជាមនុស្សដែរ គឺចេះខឹង ចេះកុហក ចេះសើច ចេះយំ ដូចមនុស្សដែរ។*
- **បំណកស្រាយ៖**
    - ✓ *បង្ហាញពីរូបភាពទូទៅនៃព្រះពោធិសត្វ...*
    - ✓ *លក្ខណៈជាពោធិសត្វនៃតួអង្គព្រះវេស្សន្តរ៖*
    - *ជាជនអស្ចារ្យជាងជនសាមញ្ញ*
    - *ប្រសូតភ្លាមចេះនិយាយភ្លាម*
    - *មានចិត្តចង់ធ្វើទានតាំងពីវ័យក្មេង(អាយុ ៨ ឆ្នាំ)*
    - *អាចទស្សន៍ទាយដឹងពីអនាគត៖ ព្រះវេស្សន្តរបានដឹងថា ថ្ងៃស្អែកនឹងមានព្រាហ្មណ៍ចាស់ម្នាក់ មកសុំកូនទាំងពីរ*
    - *មានសទ្ធាជ្រះថ្លា និងមានព្រះទ័យត្រេកអរក្នុងការឱ្យទាន៖ ទ្រង់បានលះបង់ទានធំៗអស្ចារ្យដូចជាធនបរិច្ចាគ (សត្តសតកមហាទាន) បុត្របរិច្ចាគ និងភរិយាបរិច្ចាគ ទ្រង់បរិច្ចាគដោយទឹកចិត្តរីករាយ និងជ្រះថ្លា*

- មិនជាប់ជំពាក់នឹងផ្លូវកាមៈ ទ្រង់ពុំបានរួមសង្វាសនឹងនាងមទ្រីទៀតទេពេលតាំងសីលនៅក្នុង ព្រៃ...
- មិនជាប់ជំពាក់នឹងទ្រព្យសម្បត្តិ បុណ្យសក្តិ រូបសម្ផស្ស...៖ ទ្រង់មិនទទួលរាជសម្បត្តិពីស្តេចចេតរា ស្ត្រទាំង៦ម៉ឺនអង្គ
- មានមេត្តាធម៌ចំពោះមនុស្សស្មើៗគ្នា៖ ទ្រង់ឱ្យទានទៅមនុស្សគ្រប់គ្នាដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរឡើយ
- ទ្រង់មិនធ្វើឱ្យ ជនណាក្តៅក្រហាយដោយសារខ្លួន៖ អ្នកស្រីពិរា ស្ត្រជាអ្នកដេញទ្រង់ចេញពីនគរ តែទ្រង់មិនបានខឹងគុំគួន ឬចងអាឃាតជាមួយពួកគេឡើយ
- ទ្រង់បំពេញបាននូវទានបារមីទាំង១០

✓ រូបភាពនៃលក្ខណៈមនុស្សទូទៅ

✓ លក្ខណៈជាមនុស្សរបស់ព្រះវេស្សន្តរ

- មានកំហឹង ឆេវឆាវ៖ ពេលតាជូជកវាយកូនទាំងពីរនៅនឹងមុខ ទ្រង់ខឹង ហើយទាញធ្នូបម្រុងបាញ់តាជូជក

- ទន់ជ្រាយ ភ័យខ្លាច រំភើប ៖ ព្រះវេស្សន្តរទ្រង់ភិតភ័យនៅពេលព្ទសូរសន្ធឹកទ័ព ទ្រង់រន្ធត់ចិត្ត និងរំភើបយំរហូតដល់សន្លប់ ពេលបានជួបជុំគ្រួសារវិញ...
- ចិត្តផ្សេងនិយាយផ្សឹង៖ ទ្រង់បានសុំពរពីព្រះឥន្ទ្រសុំឱ្យព្រះបិតា និងមាតាមកយាងទ្រង់ត្រឡប់ទៅនគរវិញ តែពេលព្រះបាទស្រីសញ្ជ័យលើកទ័ពមកដល់ ទ្រង់ធ្វើជាប្រកែកមិនព្រមទៅ
- អាត្មានិយម៖ ដើម្បីតែប្រយោជន៍ខ្លួនឯងទ្រង់ហ៊ានធ្វើគ្រប់បែបយ៉ាង ទោះបីកូន និងប្រពន្ធត្រូវលំបាក...។
- កុហកបោកប្រាស់៖ ទ្រង់បានកុហកនាងមទ្រីអំពីសុបិន...
- ទ្រង់ប្រកាន់វណ្ណៈ ៖ ទ្រង់មិនចង់ឱ្យបុត្រធ្លាក់ទៅប្រឡូកប្រឡាក់ជាមួយវណ្ណៈសាមញ្ញ ដូចទ្រង់បានពោលទៅកាន់ជាលីមុនពេលត្រូវតាជូជកនាំទៅថា " ជាលីអើយ នានាងក្រស្នាជាប្អូនស្រីកបនូវលក្ខណាឆាយាល្អ មកកើតនាត្រកូលអម្បូរថ្លៃ កូនអើយឪពុកក្រែងអ្នកឥត

*អម្បូរពូជពង្សទុរជន មានតែទ្រព្យមកដាក់ឱ្យព្រាហ្មណ៍ យកទៅតាមចិត្ត ប្រាថ្នាជាភរិយាសេពសម្ព័ន្ធនឹងត្រកូលជាន់ទាប...”។*

- *សរុបសេចក្តី៖ សរុបនូវអ្វីដែលយើងត្រូវបកស្រាយ*

**គ. បញ្ចាប់សេចក្តី**

- *វង្វាយតម្លៃប្រធាន*
- *មតិស្នេរ*

***ប្រធានទី៣៖***មានទស្សនមួយពោលថា" ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ប្រកបដោយសុខសុវត្ថិភាព មិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាល ធនធានមនុស្សបានឡើយ។" ក្នុងស្ថានភាពបច្ចុប្បន្ន តើត្រូវបណ្តុះបណ្តាលធនធានមនុស្ស ឱ្យមានលក្ខណសម្បត្តិដូចម្តេចខ្លះ? ចូរបង្ហាញពីការបណ្តុះបណ្តាលទាំងក្នុងសង្គម និងអក្សរសិល្ប៍។

# គម្រោងតែង

## ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យើងដឹងច្បាស់ហើយថានៅក្នុងសង្គមគ្រួសារក្តី ក្នុងសង្គមជាតិទាំងមូលក្តី គឺត្រូវចាំបាច់បំផុតនូវធនធានមនុស្ស.......................................សំខាន់ដែលពុំអាចខ្វះបាន ក្នុងការកសាង........................................សង្គមជាតិ។ តាមរយៈនេះលុះត្រាតែយើងនាំគ្នាចូល..........................ក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្ស ឱ្យបានគ្រប់គ្រាន់ ព្រោះថាធនធានមនុស្ស គឺជាកត្តាសំខាន់ ក្នុងការអភិវឌ្ឍ។
- ចំណោលបញ្ហា៖ លើកប្រធានមកសរសេរ

- ចំណោទបញ្ហា៖ តើពាក្យនោលខាងលើមានន័យដូចម្តេច? តើត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ ដើម្បីចូលរួមក្នុងការអភិវឌ្ឍជាតិ?

## ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងល្អឥតខ្ចោះនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖
  - ការអភិវឌ្ឍ មានន័យថាការរីកចម្រើនខ្លាំង...
  - សុវត្ថិភាព មានន័យថាភាពប្រកបដោយសេចក្តីសុខ
  - ធនធានមនុស្ស មានន័យថាមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ...
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថាការធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនខ្លាំង ប្រកបដោយសេចក្តីសុខ គឺមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ បានឡើយ...
- **បកស្រាយប្រធាន**
  - គាំទ្រទៅលើប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម៖

- បណ្ដាប្រទេសមួយចំនួន ដែលមានធនធានធម្មជាតិយ៉ាងច្រើនលើសលប់ ក៏មិនប្រាកដថាជាប្រទេស រីកចម្រើននោះដែរ...
- បើសម្បូរពោរពាសដោយសម្បត្តិធម្មជាតិតែខ្វះខាតនូវធនធានមនុស្សនោះ ក៏វាមិនមានការរីកចម្រើនទៅយ៉ាងរលូនដែរ...
- ចំណែកឯប្រទេសមួយចំនួន ដែលគ្មានធនធានធម្មជាតិ ក៏មិនប្រាកដថាជាប្រទេសអន់ថយដែរ...
- មានជាអាទិ៍ ដូចជាប្រទេសជប៉ុន ប្រទេសសិង្ហបុរី ជាប្រទេសដែលមិនសូវមានធនធានធម្មជាតិនោះទេ តែប្រទេសរបស់គេសម្បូរដោយធនធានមនុស្ស ទើបប្រទេសទាំងនេះមាន ការរីកចម្រើនលើគ្រប់វិស័យទាំងអស់...
- យ៉ាងណាមិញ ប្រទេសកម្ពុជាយើង ដើម្បីធ្វើការអភិវឌ្ឍ គឺត្រូវចូលរួមបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចជា

**បណ្ដុះបណ្ដាលតាមរយៈសង្គមបច្ចុប្បន្ន៖**

- ⇨ កាយសម្បទារឹងមាំ(ឱ្យតម្លៃ លើកីឡា)
- ⇨ ប្រាជ្ញាសម្បទា(រៀន និងបង្រៀន)
- ⇨ សីលសម្បទា(មានសីលធម៌រស់នៅល្អ)
- ⇨ វិជ្ជាសម្បទា(មានបំណិនជីវិត មានបទពិសោធ)

⇨ ចរិយាសម្បទាន(មានការប្រព្រឹត្តល្អ ប្រកបដោយគុណ)

⇨ សិទ្ធិ និងប្រជាធិបតេយ្យ

⇨ ចេះរួមរស់ក្នុងសន្តិភាព និងចុះសម្រុងគ្នា។

**បណ្តុះបណ្តាលតាមរយៈអក្សរសិល្ប៍៖**

⇨ រឿងព្រះអាទិត្យថ្មី (សមទទួលការបណ្តុះបណ្តាលពីអ្នកជំនាញខាងវិស័យកសិកម្ម...ធ្វើឱ្យសង្គមជាតិរីកចម្រើន)

⇨ រឿងថៅកែចិត្តចោរ(ផានីត បានចំណេះពីការរៀនសូត្រយកមកអនុវត្ត...បានចូលរួមរក្សាយុត្តិធម៌ជូនសង្គម)

⇨ រឿងទុំទាវ(ទុំ ទៅបួសរៀនក្នុងអារាមដើម្បីទទួលបានចំណេះ និងជំនាញ...យកទៅអភិវឌ្ឍ សង្គមគ្រួសារ និងជាតិ)។

• សរុបសេចក្តី៖សរុបសេចក្តីជារួមមក .................................... បញ្ជាក់ឱ្យឃើញថា ក្នុងស្ថានភាពបច្ចុប្បន្ន យើងត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានគ្រប់សមត្ថភាព ទាំង............... ហើយចេះឱ្យតម្លៃលើសិទ្ធិ និងប្រជាធិបតេយ្យ។

**គ. សេចក្តីបញ្ចប់**

• វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិត ចំពោះទស្សនៈរបស់ប្រធានខាងលើនេះ យើង

ឃើញថាទស្សនៈរបស់ប្រធានខាងលើ ពិតជាផ្តល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅព្រោះ............................................... របស់សង្គម។ លើសពីនេះចង់ឱ្យយើងមានលទ្ធភាពចូលរួមក្នុងការកសាងជាតិ ព្រោះយើងជាកុលបុត្រកុលធីតាខ្មែរដែលពោរពេញទៅដោយចំណេះដឹង ...................ជាសសរត្រូវនៃការអភិវឌ្ឍប្រទេសជាតិ។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ..............................និងសីលធម៌ រវាងបុគ្គល និងសង្គម រវាងជាតិ និងអន្តរជាតិ។
- ពាក្យស្លោក ឬសុភាសិត៖ សមទស្សនៈមួយពោលថា៖"ប្រទេសជាតិរីកចម្រើនទៅបាន គឺអាស្រ័យលើធនធានមនុស្ស"។

**ប្រធានទី៤៖** មានទស្សនមួយថា៖ " តួអង្គក្នុងរឿងទំនាវភាគច្រើនបានជាប់ជំពាក់នឹងទោសនៃកាមតណ្ហា"។ ចូរបង្ហាញ ដោយលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖រឿងទំនាវជាប្រលោមលោកមនោសញ្ចេតនា ដ៏ល្បីល្បាញមួយ ដែលកវីនិពន្ធខ្មែរតាក់តែងឡើងប្រកបដោយ ទេព្យកោសល្យខ្ពង់ខ្ពស់បំផុតគឺភិក្ខុសោម ក្នុងឆ្នាំ មួយពាន់ប្រាំបួនរយដប់ប្រាំ។ ហើយរឿងនេះបានបង្ហាញចំណុចសំខាន់ ធ្វើឱ្យទាក់ទាញអារម្មណ៍អ្នកអាន អ្នកសិក្សានោះគឺបញ្ហាស្នេហា ដែលស្តែងចេញតាមតួអង្គពោរពេញដោយ ភាពងប់ងល់ក្នុងសេចក្តីត្រូវការ ខ្វះការពិចារណាដកខ្លួនមិនរួច។
- ចំណូលបញ្ហា៖បែបនេះហើយទើបមានទស្សនមួយពោលថា៖ " តួអង្គក្នុងរឿងទំនាវភាគច្រើនបានជំពាក់នឹងទោសនៃកាមតណ្ហា"។
- ចំណោទបញ្ហា៖ តើតួអង្គណាខ្លះជំពាក់នឹងទោសកាមណ្ហា?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖
- ពន្យល់ពាក្យ

– ជំពាក់៖ មានន័យថាទាក់ទាម ឬទាក់ទិន
– ទោស៖ ជាកំហុស ឬកំហឹង
– កាមតណ្ហា៖ សេចក្តីប្រាថ្នា សម្រេកដោយអន្ទះអន្ទែង..
– ពន្យល់ប្រធាន៖
– បកស្រាយប្រធាន៖គំនិតគាំទ្រ

ជាការពិតណាស់តាមខ្លឹមសារនៃរឿងបានបង្ហាញឱ្យឃើញបែបនេះមែន។

- តណ្ហាមានទោសពីរធំៗគឺ៖

-គឺកិលេសតណ្ហា និងវត្ថុកាមតណ្ហា

-ក្នុងកិលេសតណ្ហា គឺជាគ្រឿងសៅហ្មងចិត្តដែលនាំឱ្យកើតសេចក្តីចំណង់ ឬសម្រេកក្នុងអារម្មណ៍រាគៈ ការជំពាក់សេចក្តីប្រាថ្នាអន្ទះអន្ទែង ឆ្អែតឆ្អន់មិនសប្បាយចិត្តជាមួយអ្វីដែលមិនបានដូចចិត្ត ចង់បានឱ្យទាន់ទាន់ចិត្ត បំពេញតាមចិត្តដែលចង់បានបើមិនបានសមដូចបំណងនោះក្នុងអារម្មណ៍នៅមិនសុខ មិនសប្បាយ។

-ចំណែកវត្ថុកាមវិញសំដៅលើចំណង់គឺរូបមានក្លិន រស និងសម្ផស្ស ដែលកាមតណ្ហានេះជាដើមចមនៃទុក្ខទោស បង្កសេចក្តីទុក្ខសោកដល់មនុស្ស សត្វ។ ចំណុចនេះគឺបង្កឱ្យមាន

ភាពក្រៀមក្រំថប់អារម្មណ៍ សោកសៅអួលអាក់ថ្ងូចថ្ងូរ សង្រេងតឹងចិត្តនិយាយមិនរួចជាដើម។មួយវិញទៀតទោស នៃកាមតណ្ហានេះផងដែរ នាំឱ្យហ៊ានប្រព្រឹត្តអំពើបាប ទាំងពួង ដូចជាករណីរំលោភបំបាន ធ្វើអត្តឃាត មានះ រឹងរូស អត្តនោម័ត និងឃាតកម្មផងដែរ...។

- ជាឧទាហរណ៍៖ ជាក់ស្តែងក្នុងដំណើររឿងទុំទាវបានបង្ហាញ តាមរយៈតួអង្គទុំនិងទាវ។ យើងឃើញថាតួអង្គទុំជំពាក់កាម ទៅនឹងរូប សំឡេង ក្លិន និងសម្ផស្សចំពោះគ្នាទៅវិញទៅមក ដោយបង្កកើតចិត្តរំលោភបំពាន មានះថែមទៀត។ តួយ៉ាងទុំ បានបំពានលើទំនាយគ្រូ ព្រោះលោកគ្រូមិនឱ្យសឹកតែនៅតែ ធ្វើរហូតលួចសឹកខ្លួនឯងថ្វាយបង្គំថា៉ វន្ទាវន្ទៈអ្នកកុំឃាត់ ផ្លាស់ស្បង់ចោលហ្មត់មិនស្រណោះ រួចស្លៀកសំពត់ហូលល្អ ស្រស់ លើកអស់អង្សក្រដាក់ទុកទើរ៉។ ត្រង់ចំណុចនេះបាន បញ្ជាក់ថាទុំហ៊ានបំពានលួចសឹកដោយខ្លួនឯងមិនបានធ្វើ ពិធីត្រឹមត្រូវក៏ដោយសារ ទ្រាំមិនបានក្នុងផ្លូវអារម្មណ៍ដែល ជាប់ជំពាក់កម្ម វិវដ្តសង្សារសត្វលោកព្រោះរឿងស្នេហ៍។
- មិនតែប៉ុណ្ណោះ ដោយឈ្លក់ក្នុងកាមតណ្ហាខ្លាំងពេកបានធ្វើ ឱ្យទុំឆ្លេឆ្លា ពុំគិតពិចារណាឱ្យបានដិតដល់ចំពោះបញ្ហាមិន ខ្លាចស្លាប់ បែរជាយកស្រីស្រាជាត្រីមុខរហូតបាត់បង់ជីវិត

ដោយសារ ការបំពេញសេចក្តីត្រូវការក្នុងអារម្មណ៍ទាំងងប់ងល់។

- លើសពីនេះ តួអង្គទាវក៏មិនខុសពីទុំប៉ុន្មានដែរ ហេតុតែសេចក្តីស្នេហា ជ្រាបចូលយ៉ាងជ្រៅក្នុងអារម្មណ៍ បានធ្វើឱ្យនាងហ៊ានតតាំងជាមួយម្តាយ ហ៊ានសម្លាប់ខ្លួនតាមទុំពេលនាងបានឃើញខ្មោចប្តីដូចករីលើកបរិយាយថា " ទាវប្រែះប្របប្តីដៃប្រវា បានកាំបិតស្លារអាឆ្មេងឆិត ត្រូវដាច់បំពង់កក្បៀយពិត កៀកកិតកើយគងទំនងជុំ"។ បានន័យថាទាវធ្វើអត្តឃាតខ្លួនឯង ព្រោះមិនអាចរស់នៅបានបើគ្មានទុំ។ ចំណុចនេះ សឱ្យឃើញថាការស្លាប់របស់ទាវក៏ព្រោះតែជាប់ជំពាក់ក្នុងកាមតណ្ហា បាត់ប្រុសស្នេហារស់នៅគ្មានន័យសម្រាប់ជីវិតនាងឡើយ។
- ចំណែកឯម្តាយទាវវិញ ដក់ជាក់ដោយកាមតណ្ហាប្រាថ្នាឋានៈខ្ពស់ ទ្រព្យសម្បត្តិ យសសក្តិ អំណាច គាត់បានបោះបង់កុសលធម៌ ដែលធ្លាប់មានពីមុនមក ហើយបែរជាងាកមកប្រមាថ ឈ្នានីស ប្រើហិង្សាយកឈ្នះចាញ់គ្នា យ៉ាងសាហាវព្រៃផ្សៃបំផុត។ គាត់បានបំបែកទាវពីទុំឱ្យមករៀបការជាមួយម៉ឺន ងួនកូនស្តេចត្រាញ់អរជូន ខំប្រើឧបាយកលកុហកថាខ្លួនឈឺ ដើម្បីយកនាងមករៀបការដូចគាត់បានថា"បើបានទាវកូនមកដល់ហើយ បង្អង់អ្វីឡើយរៀបកែកុន

កែគិតឱ្យង្ហួនជាប្រពន្ធ” បានសេចក្ដីថាម្ដាយទាវពង្រាត់ទាវនៅពេលនាងមកដល់លំនៅឋាន ឱ្យរៀបការជាថ្មី ទោះបីគាត់ដឹងថាទាវជាប្រពន្ធទុំ ត្រូវស្ដេចរាមារៀបចំរួចហើយក៏ដោយ។

- មិនតែប៉ុណ្ណោះគាត់បានញុះញង់ឱ្យអរជូនចាប់ទុំយកទៅសម្លាប់គ្មានត្រាប្រណី គ្មានការពិចារណាឡើយ ដែលលទ្ធផលចុងក្រោយ ត្រូវព្រះរាជាកាត់ទោសប្រហារជីវិត។
- រីឯម៉ឺន ង្ហួនវិញក៏បានបង្ហាញពីកាមតណ្ហាយ៉ាងខ្លាំងដោយគាត់ស្រឡាញ់នាងទាវឡើងផ្កាប់មុខ មិនជំទាស់ឪពុកម្ដាយងប់ងល់រៀបការជាមួយទាវទាំងដឹងថាជាប្រពន្ធគេ ហើយហ៊ានសម្លាប់ប្ដីគេដើម្បីចង់បានប្រពន្ធគេមកជារបស់ឯង។
- មិនតែប៉ុណ្ណោះអរជូនដែលជាឪពុករបស់ម៉ឺន ង្ហួនប្រើអំណាច អាងទ្រព្យសម្បត្តិយសសក្ដិ ព្រមរៀបការកូនជាមួយនាងទាវទាំងបំពាន ទោះបីខ្លួនដឹងហើយថាទាវបើមិនបាន ទុំ ក៏ក្លាយជាស្នំព្រះរាជាដែរ។ អរជូនមិនញញើតនឹងសម្លាប់ទុំ គ្រាន់តែម្ដាយទាវនិយាយថា “ស្រែកថាអរជូនខ្លួនមានបុណ្យ មិនគិតកែកុនឆាប់រហ័ស ចាប់អាទុំចោរចិត្តមានះ ទាញពីលើផ្ទះទម្លាក់ទៅ” នេះសឱ្យឃើញថាអរជូនក្ដៅក្រហាយ ខឹងទុំដែលហ៊ានប្រជែងជាមួយកូនរបស់ខ្លួនមានទ្រព្យសម្បត្តិសក្ដិយស ខ្ញុំកំដរមិនចេះអស់ ។ លើសពី

នេះអរជូននៅតែបំពានលើស្តេចរាមាទាំងស្រុង។ យ៉ាងហើចណាស់ក៏ត្រូវដឹងថា ទុំជាមនុស្សរបស់ស្តេចដែរ ព្រោះទុំជាម៉ឺន ឯក។ ទីបំផុតទោសត្រូវកាត់ទោសប្រហារជីវិតដូចបន្ទូលស្តេច" ចូរអស់នាម៉ឺនជំនុំទោស ឃើញកុំសន្តោសអាចោរខ្នាំង អាចោរខ្មោចចូរប្រមូលអាំង កាន់ក្រាំងកត់ត្រាឃាត់ខាឃុំ"ដោយពពួកអរងរជូននិងកូនត្រូវកប់រាស់ជាដើម។

- ចុងក្រោយទោសតណ្ហាក៏ត្រូវធ្លាក់មកដល់ព្រះរាមាផងដែរ ដោយព្រះអង្គវង្វេងនឹងសម្រស់ទាវ បម្រុងនឹងសម្លាប់ទុំនៅពេលច្រៀងសារភាពខ្លួនស្នេហ៍ទាវ។ ម៉្យាងទៀតការកាត់ទោសអរជូន ម្តាយទាវ និងបក្សពួកនៅត្បូងឃ្មុំយ៉ាងសាហាវព្រៃផ្សៃគឺមកពីព្រះអង្គស្តាយទុំទាវ ពិសេសខឹងអរជូនដែលមិនគោរពរាជសារ ឬកោតខ្លាចអំណាចខ្លួនសោះ។ ពោលគឺលែងទុកចិត្តអរជូនទាក់ទងនឹងអំណាចតែម្តង។ ប្រការនេះហើយដែលធ្វើឱ្យស្តេចកាត់ទោសគ្មានវិនិច្ឆ័យត្រឹមត្រូវ កាត់ទោសទាំងកំហឹង រហូតទៅដល់រាស្ត្រត្បូងឃ្មុំដែលមិនដឹងអ្វីសោះទាំងក្មេងទាំងចាស់ ទារកក្នុងផ្ទៃ ក្លាយជាអ្នកងារយ៉ាងទារុណបំផុត។
- សរុបសេចក្តីមក តួអង្គជំពាក់ទោសនៃកាមតណ្ហា គឺទុំទាវ ម្តាយទាវ អរជូនម៉ឺន ងួន និងស្តេចរាមាដែលធ្លាក់ក្នុងអន្លង់កិលេសតណ្ហាដោយក្តីឈ្នានីស អន្ទះអន្ទែង ក្នុងសម្រេក

លោភៈ។ ម៉្យាងជំពាក់វត្ថុកាមតណ្ហាក្រាស់ក្រែល គឺស្នេហានេះតែម្តង។ ការជំពាក់នេះបានបង្កជាទុក្ខទោស ហិង្សា អត្តនោម័ត មានញរឹងរូស ហើយនាំឱ្យមហន្តរាយយ៉ាងធ្ងន់ធ្ងរ។

**គ. សេចក្តីបញ្ចប់៖**

- ***វាយតម្លៃប្រធាន៖*** *ឆ្លងតាមរយៈការបកស្រាយយ៉ាងក្បោះក្បាយនូវមតិប្រធានខាងលើ យើងស្វែងយល់ច្បាស់ពីប្រធាន ព្រោះបានបង្ហាញផលអាក្រក់ផ្សេងៗដែលកើតចេញពីទោសនៃតណ្ហា។ មិនតែប៉ុណ្ណោះគឺបានផ្តល់ជាគតិអប់រំដាស់តឿន ជនគ្រប់រូបឱ្យជៀសចេញ នូវកាមតណ្ហាប្រកបដោយមនសិការ និងការពិចារណាយ៉ាងល្អិតល្អន់ផងដែរ។*
- ***មតិផ្ទាល់ខ្លួន៖*** *ដូចនេះយើងចាំបាច់ត្រូវខិតខំកសាងកុសលក្នុងជីវិត ឱ្យបានល្អត្រឹមត្រូវ ពិសេសបញ្ចៀសនូវកាមតណ្ហាឱ្យអស់ពីជីវិតដើម្បីកុំឱ្យមានការសោកស្តាយ មានកំហុស ឱ្យមានភាពខ្ពង់ខ្ពស់ និងមានសុភមង្គលក្នុងជីវិត ដូចពុទ្ធភាសិតពោលថា" ការអស់ទៅនៃតណ្ហា រមែងឈ្នះអស់ទុក្ខទាំងពួង"*

**ប្រធានទី៥៖ ប្រធាន៖** «អ្នកនិពន្ធរឿងទុំទាវបានគាក់តែងរឿងដោយឱ្យតួអង្គមួយចំនួនទទួលមរណភាព»។ តើការគាក់តែងបែបនេះអ្នកនិពន្ធមានគោលបំណងដូចម្តេចខ្លះ? ចូរបង្ហាញរួចវិនិច្ឆ័យលើវិធីនេះតាមគំនិតមនុស្សនិយមនាបច្ចុប្បន្ននេះផង។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ អក្សរសិល្ប៍ខ្មែរទាំងបុរាណ ទាំងសម័យទំនើបសុទ្ធតែបានបង្ហាញពីការ ស្លាប់របស់តួអង្គនានា ដែលធ្វើឱ្យអ្នកអានមានទាំងក្តីរំភើប ក្តីស្អប់ និងខឹង។
- ចំណូលបញ្ហា៖ ហើយនៅក្នុងរឿងទុំទាវក៏បានបង្ហាញពីសិល្បវិធីតែងនិពន្ធដែលមានតួអង្គសំខាន់ៗ ជាច្រើននាក់ទទួលមរណភាព ។
- ចំណោទបញ្ហា៖ តើការគាក់តែងបែបនេះ អ្នកនិពន្ធមានគោលបំណងដូចម្តេចខ្លះ? វិធីបែបនេះមនុស្សសម័យបច្ចុប្បន្នមានការយល់ឃើញដូចម្តេច?

### ខ. តួសេចក្តី

– ឃ្លាភ្ជាប់សេចក្តី:

– ពន្យល់ពាក្យ

✓ តាក់តែង៖សំដៅលើការនិពន្ធរឿងការកំណត់សាច់រឿង

✓ មរណភាព៖ គឺការស្លាប់ ការបាត់បង់ជីវិត។

➢ ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានចង់ឱ្យយើងបង្ហាញ នូវគោលបំណងអ្នកនិពន្ធរឿងទុំទាវដែលបានកំណត់សាច់រឿងរបស់លោកដោយតម្រូវឱ្យតួអង្គជាច្រើនស្លាប់ដោយប្រការផ្សេងៗពីគ្នា។ ហើយក៏ចង់ឱ្យលើកទស្សនៈវាយតម្លៃរបស់មនុស្សទូទៅជុំវិញការស្លាប់នោះផង។

➢ ការបកស្រាយប្រធាន៖

✓ ការស្លាប់របស់ទុំ៖ ព្រោះប្រហែស អំនួត គឺមិនល្អ

✓ ការស្លាប់របស់ទាវ៖ ស្មោះភក្ដី ភាពប្រសើរនៃស្ត្រីខ្មែរ

✓ ការស្លាប់របស់នាងនោះ៖ ស្មោះនឹងចៅហ្វាយ ពុំល្អទេគួរជ្រើសរើសវិធីផ្សេង

✓ ការស្លាប់របស់ម្ដាយទាវ អរជូន ម៉ឺនងួន៖ មកពីលោភៈ ទោសៈ មោហៈ មិនល្អ

➢ សរុបសេក្ដីមក៖ អ្នកនិពន្ធបានតែងនិពន្ធដោយឱ្យតួអង្គមួយចំនួនស្លាប់ គឺមានបំណងចង់ដាស់តឿនដល់ជនជំនាន់ក្រោយកុំបណ្ដោយខ្លួនស្លាប់ព្រោះតែអបាយមុខ ស្លាប់ព្រោះប្រើសិទ្ធិបំពានអ្នកស្លូតត្រង់តទៅទៀត។ បើស្លាប់ព្រោះភក្ដីអាចមានឈ្មោះជាជនដ៏ប្រសើរ។ ទោះបីយ៉ាងណាក្នុងនាម

ជាមនុស្សត្រូវធ្វើឱ្យការស្លាប់របស់ខ្លួនមានគេអាណិតអាសូរ និងគោរព។

## គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធានះឆ្លងតាមការពន្យល់បកស្រាយរួចមកហើយ យើងអាចវាយតម្លៃបានតាមការបង្ហាញពីមរណភាពរបស់តួអង្គ នៃអ្នកនិពន្ធរឿងទុំទាវ ពិតជាផ្ដល់នូវតម្លៃអប់រំល្អដល់អ្នកអានមែន។ ដោយសារតែសិល្បវិធីតែងបែបនេះ បានផ្ដល់នូវមេរៀនដល់សាធុជន ឱ្យរក្សាជំហរល្អ ជ្រើសរើសវិធីល្អ រក្សាជីវិតខ្លួនឱ្យរស់នៅបានយូរអង្វែង។
- ទស្សនៈផ្ទាល់ខ្លួនះ ដូចនេះទោះជាកាលៈទេសៈណាក៏ដោយ មនុស្សពុំគួរយកការសម្លាប់ខ្លួនស្រាយបញ្ហា តោងពិចារណាវែងឆ្ងាយបញ្ចៀសការស្លាប់ដោយអគតិធម៌នោះ។

**ប្រធានទី៦៖** ដូនតាខ្មែរ " និយមជឿលើហោរាសាស្ត្រ ប៉ុន្តែលោកបែរជាទូន្មានថា ភូតនៅហោរទៅវិញ" ។តើនេះមកពីមូលហេតុអ្វីខ្លះ? ចូរបង្ហាញដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក.ផ្តើមសេចក្តី៖

- លំនាំបញ្ហា៖ តាំងពីបុរាណកាលមកប្រជាជនខ្មែរតែងតែ........................................សម្រាប់ប្រយោជន៍ជាតិខ្មែរ។
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ តើបញ្ហានេះបណ្តាលមកពីរអ្វី?

### ខ. តួសេចក្តី៖

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ហោរាសាស្ត្រមានន័យថាក្បួនទាយ។ ហោរសំដៅអ្នកទាយ។
- ពន្យល់ន័យប្រធាន៖ ចង់បង្ហាញឱ្យកូនចៅជំនាន់ក្រោយបានដឹងថាដូនតាខ្មែរលើកតម្កើងគាំទ្រ ក្បួនទាយតាំងពីដើមរៀងមក។ ប៉ុន្តែលោកមិនចង់ឱ្យកូនចៅជឿលើហោរពេកទេ ប្រយ័ត្នប៉ះចំហោរភូតកុហក........................................។
- បកស្រាយប្រធាន៖ ជាការពិតណាស់.............

- គំនិតខំខាន់

មូលហេតុដែលដូនតាជឿលើហោរាសាស្ត្រព្រោះ៖

- ✓ ដោយសារលោកចងក្រងយោងពិសោធន៍ជាក់ស្តែងច្រើនឆ្នាំ
- ✓ ក្បួនទាយបែបគិតគន់ គួរលេខច្បាស់លាស់
- ✓ ទស្សន៍ទាយតាមជើងលេខ...

ឧទាហរណ៍៖

- ក្នុងសង្គម៖
- មុនធ្វើដំណើរទៅណាមកណាហាមធ្វើដំណើរចំកណ្តាលថ្ងៃត្រង់...
- មុនរៀបការមើលខែឆ្នាំ...
- សង់ផ្ទះគន់គួរមើលចំពេលអំណោយផល...
- ក្នុងអក្សរសិល្ប៍៖
    - រឿងទុំទាវ(គ្រូទុំទាយមិនឱ្យទុំសឹក...)
    - រឿងរាមកេរ្តិ៍( ពិភេកទាយ............)
    - រឿងទំនៀមទម្លាប់ផ្កាស្លាបី..........................។
- ✓ មូលហេតុទូន្មានភូតនៅលើហោរ
    - ហោរទាយតែតាមបំណងមនុស្សមិនដូចគណិតវិទ្យា...
    - ហោរចេះក្បួនទាយស្ទើរៗ ទាយផ្សំនឹងវោហារសព្ទ...

- *ហេតុទាយបម្រើចិត្តលោភៈរបស់ខ្លួន...*

*ឧទាហរណ៍៖*

- **ក្នុងសង្គម៖**
- ✓ *ទាយឱ្យឧកញ៉ាដោយមើលឃើញ...*
- ✓ *ទាយតាមទឹកមុខ...*
- ✓ *ទាយតាមចំណាំជូនកាលគ្មានក្បួនតែធម្មជាតិអំណោយផលក៏ផ្សំគម្រិះខ្លួនបន្តិចកើតបានជាការទស្សន៍ទាយមួយ...*
- **ក្នុងអក្សរសិល្ប៍៖**
- ✓ *រឿងផ្កាស្រពោន(គ្រូអានទាយថានាងវិធាវីឆុងរាសីត្រូវស្រោចទឹក)*
- ✓ *រឿងធនញ្ជ័យ(ទាយវាសនាធនញ្ជ័យអាក្រក់ដោយច្រណែន)*
- ✓ *រឿងសង្ខ័សិល្ប៍ជ័យ(ហោរទាយពីវាសនាល្អទៅអាក្រក់ដោយសារចង់បានលាភ ដោយទូលព្រះបាទសេនាកុត្តរាជថាបុត្រសង្ខ័សិល្ប៍ជ័យនាំក្តីវិនាសដល់ព្រះនគរ...)*

*សរុបសេចក្តី៖ ហេតុដែលនាំឱ្យចាស់បុរាណលោកឱ្យតម្លៃលើហោរាសាស្ត្រព្រោះក្បួននេះកើតពីការសិក្សាស្រាវជ្រាវ សង្កេតច្រើនជំនាន់......................................................................។ ប៉ុន្តែលោកមិនចង់ឱ្យជឿលើក្បួនទាយស្ទើរ.........................។*

**គ. សេចក្តីបញ្ចប់៖**

- ✓ *វាយតម្លៃប្រធាន៖ ឆ្លងតាមការពន្យល់បកស្រាយរួចមក ..............................................យកតាមហោរាសាស្ត្រខ្មែរល្អ តែគួរកម្ចាត់ចោរហោរទាយស្មើរៗ...................*
- ✓ *មតិផ្ទាល់ខ្លួន៖*

**ប្រធានទី៧៖** *ភាសិតមួយថា "កុំខ្ញើកតាមខ្យល់ កុំខ្វល់មតាមរលក" ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។*

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងនឹងប្រធាន
- ចំណូលបញ្ហា៖ ប្រើឃ្លាភ្ជាប់ជាមួយប្រធាន
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖
- ពន្យល់ពាក្យ៖ ខ្ញើក ខ្យល់ ខ្វល់ រលក
- ពន្យល់ន័យប្រធាន៖...
- បកស្រាយប្រធាន

**ន័យចំ៖**ប្រធាននេះចង់បង្ហាញ.......................................។

- ពង្រីកន័យចំ(បែបម៉្យាង)
  - ✓ ខ្យល់តែងតែបក់ហោក ទោរទន់...
  - ✓ ខ្យល់តែងតែនាំវត្ថុដែលងាយនឹងកម្រើក រេតាមខ្លួន..

- ✓ តែបើវត្ថុរឹងវិញ ខ្យល់មិនអាចឱ្យវត្ថុនោះរេតាមខ្លួនឡើយ...
- ✓ ខ្យល់បក់ ទឹករលក...
- ✓ ទឹករលកកាចសាហាវ ធ្វើឱ្យអ្នកទូកខ្វល់ខ្វាយ ជ្រួលជ្រើម នាំឱ្យទូកលិចមានគ្រោះអាសន្នជាក់ជាពុំខាន...

**ន័យធៀប៖**ចែកជាពីរផ្នែក៖

**ផ្នែកទី១៖** "កុំខ្ជិកតាមខ្យល់"

- ✓ ខ្យល់ជាអ្នកនាំអាក្រក់ ប្រៀបដូចជាពាក្យចចាមអារាម ពាក្យញុះញង់...
- ✓ ខ្ជិកការរេតាម...
- ✓ ពាក្យសម្តីឥតបានការ បើយើងធ្វើតាមនាំឱ្យវិនាសដល់ខ្លួន...

**ពង្រីកន័យធៀប៖**

- ✓ រាល់ពាក្យឥតបានការគឺមានគ្រោះថ្នាក់ និងកម្លាំងខ្លាំងណាស់...
- ✓ បើយើងធ្វើតាមដូចជួយឱ្យពាក្យនោះកាន់តែមានឥទ្ធិពល...

- ✓ ការធ្វើការទាំងកម្រោល តាមសម្តីញុះញង់ ខ្វះការពិចារណា...
- ✓ គ្មានគោលដៅ មិនច្បាស់ការ...
- ✓ ភ្លេចរូបភាព ដែលល្អនោះ នាំឱ្យគេជួបប្រទះបញ្ហាចំពោះមុខ...

ឧទាហរណ៍៖

- ✓ ក្នុងសង្គមសិស្សចាញ់បោកមេខ្យល់មួយចំនួនថាជួយឱ្យប្រឡងជាប់ នាំឱ្យគេភ្លេចខ្លួន ទទួលបរាជ័យ ការងារតាមការជួយរកឱ្យធ្វើ បង់លុយអស់ជាច្រើន...។ តែបើយើងខិតខំរៀន .......................ទទួលបានជោគជ័យ...

ក្នុងអក្សរសិល្ប៍

- ✓ បុរសបរទេះគោ(ទន្សាយមិនជឿលើសត្វក្រពើទើបកាត់ក្តីបានយុត្តិធម៌)
- ✓ រឿងកុលាបប៉ៃលិន(ចៅចិត្តមិនខ្វល់ចំពោះសម្តីនាងឃុននារី...)
- ✓ រឿងចៅកែចិត្តចោរ( ការជឿលើពាក្យញុះញង់របស់ចៅកែចិត្តចោរ ធ្វើឱ្យពូហំត្រូវ...)

មួយទៀត "កុំខ្វល់តាមរលក"

- *រលកប្រៀបបានឧបសគ្គ ន័យនេះបើយើងភ័យ...ឧបសគ្គចំពោះមុខនាំឱ្យគ្រោះថ្នាក់*

*៣ពង្រីកន័យ*

- *កាលណាយើងខ្វល់នូវអ្វីដែលយើងកំពុងជួបប្រទះនាំឱ្យយើងបាត់បង់ភាពម្ចាស់ការ*
- *ទន់ជ្រាយ ទន់ខ្សោយ*
- *បាត់បង់ទំនុកចិត្ត ................នាំឱ្យរលាយ។*
- *កុំរាថយតាម ត្រូវរកវិធីដោះស្រាយចំពោះឧបសគ្គ...*
- *បើមិនទន់ជ្រាយ ភិតភ័យ មានឆន្ទៈរកវិធីដោះស្រាយ កុំបារម្ភ មិនត្រូវគិតហួសហេតុរហូតបាត់ជំនឿជាក់ដែលនោះនឹងនាំឱ្យ......................................។*

***ឧទាហរណ៍៖*** *សង្គម៖ កីឡាករបើគ្រាន់តែឃើញគូប្រកួតហាក់មានអារម្មណ៍ខ្លាច....នោះនាំឱ្យយើង......។ ចំពោះសិស្សប្រឡងបើគ្រាន់តែឃើញវិញ្ញាសាបាក់ស្បាត.....ធ្វើមិនត្រូវ តែបើយើងខំដោយប្រុងស្មារតី....................ប្រឡងជាប់។*

***អក្សរសិល្ប៍***

- ✓ *រឿងភូមិតិរច្ឆាន(ជូន នៅមិនខ្វល់ពីអំណាចបារាំង នាំឱ្យគេទទួលបានជោគជ័យ)*

- ✓ រឿងទុំទាវ(មិនខ្លាចឧបសគ្គ....................នាំឱ្យគេទទួលបានជោគជ័យ)
- ✓ រឿងរាមកេរ្តិ៍( ព្រះរាមមើលឃើញក្រុងរាពណ៍នាំនាងសីតាជិះរាជរថបញ្ឈើរ បែរជាទន់ខ្សោយធ្វើអ្វីមិនកើត....)

សរុបសេចក្តី៖

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ប្រធាន...ផ្តល់តម្លៃអប់រំ...
- ទស្សនៈផ្ទាល់ខ្លួន៖ ក្នុងនាមយើងជា...

ប្រធានទី៨៖ មានទស្សនៈមួយពោលថា«ការប្រមាថកើតមានចំពោះអ្នកប្រមាទ»។ ចូរពន្យល់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំ៖ ការខិតខំប្រឹងប្រែងដោយប្រុងប្រយ័ត្នតែងតែមានជោគជ័យ។ តែបើមានការធ្វេសប្រហែសនាំឱ្យបាត់បង់ប្រុងប្រយ័ត្នព្រោះមើលស្រាល បណ្តាលឱ្យបរាជ័យទៅវិញ។
- ចំណូលបញ្ហា៖ "សរសេរប្រធានមកវិញ"
- ចំណោទបញ្ហា៖ តើទស្សនៈប្រធាននេះមានន័យយ៉ាងណា?

### ខ. តួសេចក្តី៖

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖
  - ប្រមាថ៖ ការមើលងាយ មើលស្រាល ការបៀតបៀន...
  - ប្រមាទ៖ ការធ្វេសប្រហែស ភ្លេចស្មារតី...
- ពន្យល់ន័យប្រធាន៖ មតិប្រធាននេះគេចង់បង្ហាញឱ្យយើងដឹងថាការមើលស្រាល មើលងាយចំពោះ...កើតឡើងពីអ្នកដែលគ្មានការប្រុងប្រយ័ត្ន ការធ្វេសប្រហែស...ហើយនាំឱ្យទទួលលទ្ធផលមិនល្អ...។

## បកស្រាយប្រធាន៖

- រូបភាពនៃការប្រមាថ៖ ការប្រមាថនេះធ្វើឱ្យធ្វើឱ្យមនុស្ស៖

- មើលងាយការងារ
- មើលងាយអ្នកដទៃ
- ការរស់នៅ
- ការរៀនសូត្រ

ប្រការនេះវាកើតឡើងចំពោះអ្នកប្រមាទគឺ៖

- គ្មានបម្រុងប្រយ័ត្ន
- ធ្វេសប្រហែសបម្រុងស្មារតី
- មិនយកចិត្តទុកដាក់
- ខ្ជីខ្ជាខ្ជិលច្រអូស

អ្នកប្រមាទនឹងទទួលផលមិនល្អដូចជា៖

- ការងារមិនសម្រេច
- ចាញ់ បរាជ័យ
- ទទួលក្តីអាម៉ាស់ របួស ស្លាប់ក៏មាន
- អាប់ប្រាជ្ញា
- ខូចយសស័ក្តិ

## បកស្រាយក្នុងសង្គម៖

- សិស្សមើលងាយមេរៀន មិនស្តាប់គ្រូ ខ្ជីខ្ជា ...ប្រឡងធ្លាក់

- ក្នុងគ្រួសារមេគ្រួសារមើលងាយប្រពន្ធ ឬសមាជិកណាមួយ ...គ្រួសារគ្មានសុភមង្គល...
- អ្នកគ្រប់គ្រងក្រុមហ៊ុនមួយចំនួនមិនយកចិត្តទុកដាក់អោង តែខ្លួនមាន...បរាជ័យត្រូវបិទទ្វារបាង...។

ក្នុងប្រវត្តិសាស្ត្រ

- ព្រះបាទស្រីសុគន្ធបទដោយសារតែមិនមានការប្រុងប្រយ័ត្ន ...ត្រូវស្តេចកនធ្វើគុត...(សិស្សអាចរកផ្សេងពីនេះ)

**បកស្រាយក្នុងអក្សរសិល្ប៍៖**

- រឿងថៅកែចិត្តចោរ(ថៅកែ)
- រឿងតេជោយ៉ត(ស្តេចសំរិទ)
- រឿងភូមិតិរច្ឆាន(ជូននិងនៅ)(សិស្សអាចរករឿងផ្សេងពីនេះ)

សរុបសេចក្តី៖.....................................................................ទទួល បរាជ័យពិតប្រាកដមែន។

**គ. សេចក្តីបញ្ចប់៖**

– វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយយ៉ាង ក្បោះក្បាយនូវមតិប្រធានខាងលើយើងស្វែងយល់ ច្បាស់ពីមតិប្រធានគឺពិតជាមានអត្ថន័យអប់រំយ៉ាង ជ្រាលជ្រៅ..........................................................។

- ទស្សនៈផ្ទាល់ខ្លួនៈដូចនេះក្នុងនាមយើងជាសិក្ខាកាម ត្រូវខិតខំរៀនសូត្រ ហើយត្រូវតាំងស្មារតី ប្រុងប្រយ័ត្ន បញ្ចៀសឱ្យបានជាដាច់ខាត......................។
- ពាក្យស្លោក ឬសុភាសិតៈ សមតាមទស្សនៈមួយពោលថាៈ " សេចក្ដីប្រមាទជាឧបាយនាំខ្លួនទៅកាន់ភាពបរាជ័យ"។

**ប្រធានទី៩៖**មានទស្សនមួយពោលថា«រឿងទុំទាវមានលក្ខណៈពិសេសជាង រឿងដទៃ»។ ចូរបង្ហាញ។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ អក្សរសិល្ប៍នីមួយៗ ច្រើនមានតម្លៃពិសេសរបស់ខ្លួនខុសប្លែកពីគ្នាទៅតាមស្នាដៃរបស់អ្នកនិពន្ធ ទាំងក្នុងផ្នែកដំណើររឿង សង្គមបរិយាកាស និងឧត្តមគតិ។ ដោយអត្ថបទខ្លះមានតម្លៃតាមបែប ........................................។
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទ៖ តើរឿងទុំទាវមានតម្លៃពិសេសរបស់ខ្លួនយ៉ាងណា?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖
  - តម្លៃក្នុងន័យនេះមានន័យថា គឺជាលក្ខណៈពិសសមួយដែលកើតឡើងពីការថ្លឹងថ្លែង វិនិច្ឆ័យរបស់មនុស្សទៅលើអ្វី

មួយ ឬក៏លក្ខណៈពិសេសនៃគោលបំណងដែលមាននៅក្នុងផលប្រយោជន៍ ដែលត្រូវបានគេយកចេញពីតម្លៃ...

- ពិសេសគឺអ្វីដែលប្លែក ល្អលើសគេ...
- អក្សរសិល្ប៍គឺជាកម្រងអត្ថបទរឿងទាំងឡាយដែលលាតត្រដាង...
- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើចង់បង្ហាញឱ្យឃើញថា រឿងទុំទាវត្រូវអ្នកសិក្សាកំណត់ថា មានចំណុចដែលប្លែក ពីអត្ថបទរឿង.......................................។

- បកស្រាយប្រធាន៖

- **គំនិតគាំទ្រប្រធាន**

- អត្ថបទផ្សេងទៀតក៏មានតម្លៃរបស់ខ្លួនដែរ ប៉ុន្តែតម្លៃនោះខុសប្លែកពីរឿងទុំទាវតួយ៉ាងដូចជារឿងព្រះវេស្សន្តរ រឿងរាមកេរ្តិ៍ កាកី សព្វសិទ្ធិ កង្រី ទោះមានតម្លៃរបស់ខ្លួនដោយ ក៏បញ្ហាទាំងនោះច្រើនតែទាក់ទងនឹងញាតិខត្តិយវង្ស...
- តម្លៃអក្សរសិល្ប៍ស្តែងឡើងតាមរយៈ អត្ថន័យ អត្ថរូប និងអត្ថរស...
- ចំពោះរឿងទុំទាវបានបង្ហាញជីវភាពរស់នៅរបស់មនុស្សក្នុងសង្គមនាសម័យលង្វែកដែលឆ្លុះបញ្ចាំងពីតថភាពពិតក្នុងសង្គម។ ម្យ៉ាងទៀតរឿងនេះមានតម្លៃពិសេសដែលស្តែងឱ្យឃើញតាមរយៈអត្ថន័យ អត្ថរូប និងអត្ថរសផងដែរ។...

អត្ថន័យ

## ផ្នែកចំណេះដឹង

- ព្រះសង្ឃ៖ ក្នុងជំនាន់នោះព្រះសង្ឃមានជីវភាពប្លែកពីព្រះសង្ឃសព្វថ្ងៃដូចជា៖
- ធ្វើជំនួញ ទុំលក់គោកនៅត្បូងឃ្មុំ ឧ. ដោះដូរចិញ្ចឹមជីវិត...
- សិល្បករ ទុំចេះស្មូត ឯពេជ្រចេះផ្លុំប៉ី ឧ. " ទុំមានវោហារ... មានទាំងសំឡេង..."
- មន្តអាគម សារិកាលិនថោង ឧ. ដាក់ស្នេហ៍ទាវ...
- សិប្បករ ចេះធ្វើគោក ឧ. យកគោកទៅលក់នៅស្រុកឆ្ងាយ...
- ប្រជារាស្ត្រអ្នកក្រ
  - រស់នៅខ្លាចគេ ឧ. ខ្លបខ្លាចពេលដឹងថាគេសម្លាប់ទុំ...
  - គ្មានគំនិតបដិវត្ត...
  - ធ្វើតែតាមគេបញ្ជា ឧ. ចូលរួមពិធីរៀបការរបស់ទាវជាមួយម៉ឺន ងួន...
- រាស្ត្រអ្នកមាន ម្តាយទាវជាដើម
  - មានទ្រព្យសម្បត្តិចាយមិនអស់ ឧ. ...ម្តាយមេម៉ាយស្តុក
  - មានខ្ញុំបម្រើ...
  - ប្រើអំណាចផ្តាច់ការក្នុងគ្រួសារ ឧ. " មិនដែលសោះឡើយទាវអើយនំ..."

- ខ្ញុំបម្រើគេ ត្រូវស្មោះត្រង់ រស់ដោយសារគេ ស្លាប់ដោយសារគេ (លើកឧទាហរណ៍)
- វណ្ណៈមន្ត្រី មានឧញ៉ាអរជូន
  - ប្រើអំណាចផ្ដាច់ការលើប្រជាជនស្លូតត្រង់
  - សម្លាប់មនុស្សគ្មានការកាត់ក្ដី
  - គិតប្រយោជន៍ខ្លួនជាធំ
  - ចាប់កូនការដោយមិនចាំបាច់សួរនាំ

ឧ. ឧញ៉ាអរជូនមាំមួនពេក ធម្មតាក្រោមមេឃទាបជាងភ្នំ...”

- វណ្ណៈស្ដេច គឺព្រះបាទរាមាជើងព្រៃ
  - មានអំណាចខ្លាំង
  - មានចំណុចយុត្តិធម៌ខ្លះ តែការកាត់ទោសជីវិតសងជីវិតដែលមានលក្ខណៈសាហាវណាស់ ឧ. ...ឱ្យអស់សូន្យ បន្ដានបងប្អូនបញ្ជូនងារ...”
  - ជ្រើសរើសស្រីស្នំគ្រប់ទីកន្លែងឱ្យតែខ្លួនពេញចិត្តទោះបី មិនពេញចិត្តក៏ដោយ
- អ្នកងារ គឺធ្វើការដោយមិនទទួលកម្រៃ ព្រោះខ្លួនមានទោស ...

ផ្នែករអប់រំ

- រឿងនេះបានបង្ហាញឱ្យឃើញពីការរើបម្រាស់ទស្សនៈ " នំមិនធំជាងនាលិ" (ម្តាយឪពុកមានសិទ្ធិចាត់ចែងគូ្រសារឱ្យកូន) ដែលតួអង្គទុំទាវស្វែងរកសុភមង្គលប្រឆាំងគំនាបសង្គមរហូតបាត់បង់ជីវិត ក៏ព្រោះតែចង់បានសិទ្ធិសេរីភាពក្នុងការរស់នៅចំពោះស្នេហារបស់ពួកគេដែលឱ្យតម្លៃទៅលើផ្លូវចិត្ត មិនមែនជាស្នេហាដែលឱ្យតម្លៃទៅលើសម្ភារនិយម ហើយស្នេហានេះជួយកាត់បន្ថយគំនិតនិយមរបស់មាតាទាំងឡាយឱ្យចេះសណ្តោសប្រណី និងគោរពឆន្ទៈសមស្របរបស់យុវជនខ្មែរ...។

អត្ថរូប

- ផ្នែកអត្ថរូបគឺអ្នកនិពន្ធបង្ហាញឱ្យឃើញពីស្នាដៃរបស់កវីដោយលោកប្រើពាក្យសាមញ្ញ ងាយស្តាប់ ងាយយល់បញ្ចូលក្នុងអត្ថបទកាព្យបទពាក្យប្រាំពីរពីដើមដល់ចប់.
- អ្វីដែលពិសេសទៅទៀតរឿងទុំទាវបង្ហាញពីប្រពៃណីទំនៀមទម្លាប់ និងទស្សនៈនំមិនធំជាងនាលិ...

សរុបសេចក្តី៖...រៀបរាប់ខាងលើបង្ហាញឱ្យយើងឃើញថារឿងទុំទាវជាស្នាដៃមួយប្រភេទដែលទទួលការគាំទ្រ និងការឱ្យតម្លៃយ៉ាងច្រើនពីមជ្ឈដ្ឋានអ្នកស្តាប់ អ្នកសិក្សា អ្នកស្តាប់...............យ៉ាងពិតប្រាកដមែន។

## គ. សេចក្តីបញ្ចប់

- *វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយខាងលើ បានបង្ហាញឱ្យឃើញថា មតិប្រធានបានផ្សារភ្ជាប់ទៅនឹងការរស់នៅរបស់មនុស្សគ្រប់ស្រទាប់វណ្ណៈនាសម័យលង្វែកដែលជាចំណុចពិសេសរបស់អក្សរសិល្ប៍ខ្មែរយើងមែន ព្រោះជារឿងអភិរក្សនិយមគំនិតមាតាបិតាខ្មែរ..................។*
- *ទស្សនៈផ្ទាល់ខ្លួន៖...តម្លៃពិសេសនេះហើយ ធ្វើឱ្យយើងដែលរស់នៅសព្វថ្ងៃ ហាក់ដូចជាបានរស់នៅក្នុងសម័យនោះដោយឆ្លុះបញ្ចាំងតាមរយៈ...។*

**ប្រធានទី១០៖**មានទស្សនៈមួយពោលថា«ឈ្លោះគ្នាក្នុងគ្រួសារដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិដូចលាតកំណប់បង្ហាញចោរ។ ចូរពន្យល់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ទំនាស់ទាស់ទែងខ្វែងគំនិតគ្នាតែងកើតមានឡើងក្នុង សង្គមគ្រួសារ និងសង្គមជាតិ។ ជម្លោះនោះទោះបីស្ថិតក្នុងកម្រិតណាក៏ដោយ ក៏តែងតែធ្វើឱ្យភាគីទាំងសងខាង....................ជួបនូវក្តីខូចខាត...
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ តើ...........អត្ថន័យយ៉ាងណា?

### ខ. តួសេចក្តី៖

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ( ជម្លោះ ស្រាតកាយាបង្ហាញញាតិ លាតកំណប់ ចោរ)
- ពន្យល់ន័យប្រធាន៖ ការទាស់ទែង ទំនាស់វិវាទកើតក្នុងគ្រួសារ..................បង្ហាញភាពអាម៉ាស់...........ដល់អ្នកជិតខាង។ ជម្លោះក្នុងសង្គមជាតិ

.....................លាតត្រដាងទ្រព្យ............ឱ្យចោរមកលួចប្លន់។

- បកស្រាយប្រធាន៖ ជាការពិតណាស់ជម្លោះកើតឡើងពេលណាក្តី ក្តីអន្តរាយក៏រលាយពេលនោះដែរ។ ជម្លោះគ្មានផ្តល់ការចំណេញ មានតែផ្តល់ការឈឺចាប់ ខ្វះខាត អាប់ឱន ទន់ខ្សោយ បែកបាក់សាមគ្គី ឈានទៅរកក្តីវិនាស៖
- ជម្លោះកើតឡើង
  - ការមិនទុកចិត្តគ្នា មិនយោគយល់គ្នា ប្រកាន់អញត្រូវជានិច្ច...។
  - បក្ខពួកនិយម ដណ្តើមអំណាច ផលប្រយោជន៍មិនស្មើគ្នា ចង់ធ្វើធំរៀងៗខ្លួន...។
- ជម្លោះក្នុងគ្រួសារតែងតែធ្វើឱ្យ៖
  - ខូតខាតទ្រព្យសម្បត្តិ
  - បាត់បង់ពេលវេលាធ្វើការ
  - ជីវភាពធ្លាក់ចុះ
  - បង្កស្នាមរបួស
  - បែកបាក់គ្រួសារ
  - គ្មានសុភមង្គល

  - ➢ បើកកកាយភាពគ្មានខ្មាសអៀន ទាំងអស់នេះហើយនាំឱ្យ អ្នកនៅជុំវិញដឹងពីភាពអាម៉ាស់។

- ក្នុងសង្គម៖ ក្នុងគ្រួសារមួយដែលកើតមានជម្លោះរមែងកកាយរឿងអាស្រូវ រឿងមិនល្អក្នុងគ្រួសារឱ្យញាតិបានដឹង បានឮ ហើយពួកគេមើលងាយមើលថោកបង្អាប់កិត្តិយស កេរ្តិ៍ឈ្មោះ...។
- ក្នុងអក្សរសិល្ប៍៖
  - ➢ រឿងថៅកែចិត្តចោរ៖ជម្លោះរវាងពូហំ និងប្រពន្ធធ្វើឱ្យគេមើលងាយ... ។
  - ➢ រឿងព្រះអាទិត្យរះហើយ៖ លោកគី និងអ្នកស្រីស្រទុំមិនចុះសម្រុងនឹងគ្នា...។
  - ➢ រឿងទុំទាវ៖ ទាវ និងម្តាយ...។
- ជម្លោះក្នុងសង្គមជាតិ
  - ➢ បែកបាក់សាមគ្គីសង្គមចុះខ្សោយ
  - ➢ កើតមានចម្បាំង
  - ➢ គ្មានសុខសន្តិភាព
  - ➢ វិនាសគ្រប់ស្ថានភាព

- ➢ កម្លាំងការពារជាតិចុះខ្សោយ ......................................នាំឱ្យសត្រូវចូលឆក់ប្លន់ ឆ្លៀតកេងចំណេញ.................។
- – ក្នុងប្រវត្តិសាស្ត្រ៖ ដោយសារបែកបាក់សាមគ្គីមានទំនាស់សង្គ្រាមស៊ីវិល...................បាត់បង់ទឹកដីសល់មួយចម្រៀកតូច..................................។ (សិស្សអាចរកប្រវត្តិសាស្ត្រក្រៅពីនេះបាន)
- – ក្នុងអក្សរសិល្ប៍
  - ➢ រឿងតេជោយ៉ត
  - ➢ រឿងធនញ្ជ័យ
  - ➢ រឿងរាមកេរ្តិ៍ សុគ្រីព និងពាលី

***សរុប៖***ការឈ្លោះទាស់ទែងក្នុងគ្រួសារ......................ទទួលក្តីអាម៉ាស់ក្នុងសង្គមជាតិ................ធ្លាក់ចុះ បង្ហាញភាពកំសោយឱ្យសត្រូវចូលប្លន់.........................................។

## គ. សេចក្តីបញ្ចប់

- – វាយតម្លៃប្រធាន៖ មានអត្ថន័យល្អ ដាស់តឿនមនុស្សគ្រប់រូបឱ្យស្គាល់ពីផលអាក្រក់នៃជម្លោះ
- – ទស្សនះផ្ទាល់ខ្លួន៖ ត្រូវរួបរួម.......................

**ប្រធានទី១១៖** មានទស្សនៈមួយពោលថា«មុខងារអប់រំ ជាមុខងារពិសេសជាងគេរបស់អក្សរសិល្ប៍»។ ចូរបង្ហាញព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ អក្សរសិល្ប៍ជាស្នាដៃដែល......................រមែងតែងតែលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមមនោគតិរបស់អ្នកនិពន្ធ។ទន្ទឹមនឹងនេះអក្សរសិល្ប៍មិនត្រឹមតែកម្សាន្តនោះទេ ហើយបង្កប់នូវមុខងារជាច្រើនជាពិសេសគឺមុខងារអប់រំ..................។
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ តើ...........................ដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ន័យពាក្យគន្លឹះ

- អក្សរសិល្ប៍៖ ជាកម្រងរឿងដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមសិល្បវិធីរបស់អ្នកនិពន្ធ។
- មុខងារអប់រំ ៖ គឺជាការណែនាំ ទូន្មានប្រៀនប្រដៅមនុស្សឱ្យជឿជាក់លើអ្វីមួយ ដើរផ្លូវល្អ ត្រឹមត្រូវ និងមានសីលធម៌។
- មុខងារពិសេស៖ ជាមុខងារដែលលេចធ្លោជាងគេ ។

– ពន្យល់ន័យឃ្លា៖ ..................................................បង្កប់នូវមុខងារដែលលេចធ្លោជាងគេគឺ.............។

***បំណកស្រាយ*** ៖ ជាការពិតណាស់ គ្រប់អក្សរសិល្ប៍ទាំងអស់សុទ្ធតែបង្កប់នូវមុខងាររបស់ខ្លួនដែលមិនអាចប្រកែកបាន។ បើទោះជាអក្សរសិល្ប៍ពុទ្ធនិយម ព្រាហ្មនិយម និងខេមរនិយមក៏ដោយ គឺមានតួនាទីសម្រាប់៖

- គំនិតគាំទ្រ៖
  - អប់រំមនុស្សឱ្យស្រឡាញ់អំពើល្អ ស្អប់អំពើអាក្រក់
  - កសាងបុគ្គលិកលក្ខណៈរបស់មនុស្ស សីលធម៌ គុណធម៌
  - បណ្តុះស្មារតីស្រឡាញ់ជាតិ
  - ចេះរស់នៅជាមួយគ្នា
  - សាមគ្គី អធ្យាស្រ័យគ្នា
  - ស្រឡាញ់យុត្តិធម៌ ស្អប់អំពើអយុត្តិធម៌

- ជឿលើសមត្ថភាពខ្លួន
- ភ្ញាក់រឭកពីកំហុសខ្លួន
- ដកស្រង់បទពិសោធល្អៗ
- ដោះស្រាយបញ្ហាដោយសន្តិវិធី
- ធ្វើបុណ្យដាក់ទាន ជំនឿ...

– បំណកស្រាយក្នុងអក្សរសិល្ប៍ពុទ្ធនិយម

- អប់រំឱ្យមានចិត្តល្អ និងដោះស្រាយបញ្ហាដោយសន្តិវិធី
  - ✓ រឿងសុបិនកុមារ៖ ស្រឡាញ់ព្រះពុទ្ធសាសនា សន្សំបុណ្យ
  - ✓ រឿងព្រះតេមិយ៖ មានចិត្តជ្រះថ្លាក្នុងផ្លូវធម៌
  - ✓ រឿងព្រះវេស្សន្តរ៖ ដោះស្រាយបញ្ហារបស់ប្រជារាស្ត្រដោយសន្តិវិធី
- អប់រំឱ្យចេះស្រឡាញ់គ្នាខន្តី មេត្តា អធ្យាស្រ័យ ធ្វើទាន និងលះបង់គ្រប់យ៉ាង
  - ✓ រឿងព្រះសិរីធរ៖ ធ្វើទានដល់អ្នកក្នុងផ្ទះ និងក្រៅផ្ទះឱ្យបរិភោគឆ្អែក
  - ✓ រឿងសុវណ្ណសាម៖ មានចិត្តមេត្តាអនុគ្រោះ
  - ✓ រឿងវិធុរបណ្ឌិត៖
- អប់រំជឿលើទស្សនកម្មផល

- ✓ រឿងពុទ្ធិសែននាងកង្រី៖ ជាតិមុនលោកសេដ្ឋីលួចទ្រព្យនាង១២ទើបជាតិក្រោយនាង១២តាមស៊ីទ្រព្យវិញអស់។(ក្រៅពីនេះក៏បាន)
- ✓ រឿងចៅស្រទបចេក៖ ជាតិមុនចៅស្រទបចេកធ្វើអាក្រក់ដាក់លោកនេនដោយចាប់ស្រោតឱ្យលេចកេរ្តិ៍ខ្មាស ជាតិក្រោយគេគ្មានស្លៀកស្រទបចេកជំនួសខោរអាវ( អាចផ្សេងពីនេះ)
- ✓ រឿងព្រះជនក៖ ផលបុណ្យហុចឱ្យជាតិបច្ចុប្បន្ន

– **បំណាកស្រាយក្នុងរឿងព្រាហ្មណ៍និយមក្នុងរឿងរាមកេរ្តិ៍**

- អប់រំជឿលើអាទិទេព សុភមង្គលកើតឡើងពីអាទិទេពជាអ្នកកំណត់(ព្រះរាមជាអវតាទីពិរបស់ព្រះវិស្ណុ អាចជួយស្រោចស្រង់មនុស្សពីភាពអាក្រក់មកល្អវិញបាន)
- មានចិត្តក្លាហាន ស្មោះត្រង់ចៅហ្វាយនាយ(ហនុមាន...)
- សហការគ្នា( បងប្អូនព្រះរាមទាំងបួនអង្គ...)

- ភក្តីភាព គោរពពាក្យសត្យ( ព្រះនាងសីតាស្រឡាញ់ព្រះរាម ...មិនព្រមវិលចូលនគរវិញទេរហូតព្រះរាមសុគត ...)
- ព្រះគណេសនៅខេត្តសៀមរាបក្នុងសៀវភៅព្រេងខ្មែរភាគ១ ដល់ ១០( សិស្សអាចរករឿងដាក់ផ្សេងបាន)

– **បំណកស្រាយក្នុងរឿងបែមខេមរនិយម**
  - ✓ ជឿជាក់លើសមត្ថភាពរបស់ខ្លួន តស៊ូ មិនដេកចាំសំណាង
    - ✓ រឿងកុលាបប៉ៃលិន៖ ខ្លួនទីពឹងខ្លួន
    - ✓ រឿងតេជោយ៉ត៖ តស៊ូពីកូនកំព្រារហូតក្លាយជាមេទ័យដ៏ឆ្នើម
    - ✓ រឿងនាយខ្វាក់នាយខ្វិន៖ ទោះខ្លួនពិការក៏មិនចាំឱ្យគេចិញ្ចឹមដែរ
  - ✓ ប្រកាន់ពាក្យសច្ច: យុត្តិធម៌ទាមទារឱ្យរួចចេញពីការជិះជាន់ អំពើល្អ ភ្ញាក់រឭកពីកំហុសខ្លួន
    - ✓ រឿងមាលាដួងចិត្ត៖ ទីឃាវុធសច្ចាយកខេត្តខ្មែរដែលថៃយកថ្មីៗមកវិញឱ្យបានបើមិនបានខ្លួនមិនព្រមយកចងសម្ពន្ធមិត្តជាមួយសៀមឡើយ(រឿងបេះដូង)

- ✓ រឿងចៅកែវចិត្តចោរ៖ ហំភ្នាក់រញ្ជកហើយ តស៊ូទាមទាររកយុត្តិធម៌
- ✓ រឿងភូមិតិរច្ឆាន៖ នាងនី នាងបីទាមទារសិទ្ធិសេរីភាពពីបារាំង

✓ កុំឱ្យឆាប់ជឿគេ ហ៊ានរិះគន់ពីការងារប្រទេសជាតិ ការស្រឡាញ់ធម្មជាតិរបស់ប្រទេស

- ✓ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ សម ចាញ់បោក អ្នកនយោបាយបោកប្រាស់
- ✓ រឿងគូលីកំណែន៖ លឹមហ៊ានជជែករិះគន់ពីកិច្ចការប្រទេសជាតិជាមួយតាមុយ
- ✓ រឿងបឹងទន្លេសាប៖ ស្រឡាញ់បរិស្ថាន

- **សរុប៖** អក្សរសិល្ប៍មិនគ្រាន់តែបំផុសឡើងពីជីវិតតែប៉ុណ្ណោះទេ តែវាណែនាំប្រាប់ជីវិត និងវិធីរស់នៅធ្វើយ៉ាងណារស់នៅរបស់យើងមានសុខសុភមង្គល និងរីកចម្រើនទៅមុខ។បានន័យថា គឺធ្វើយ៉ាងណាជំរុញមនុស្ស ផ្តល់ការយល់ដឹងបន្ថែម ដើម្បីកសាងបុគ្គលិកលក្ខណៈមនុស្សឱ្យប្រសើរជាងមុន............................។

## គ. បញ្ចប់សេចក្តី

- វង្វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយយ៉ាង.............។
- មតិស្នេរ៖ ក្នុងនាមយើងជាមនុស្សត្រូវខិតខំ........................។

**ប្រធានទី១២៖** មានមតិមួយលើកឡើងថា៖ "ការសម្រេចចិត្តដោយអត្តនោម័តិ នាំឱ្យមានទុក្ខទោសដល់ខ្លួនឯង និងអ្នកដទៃ"។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ ការសម្រេចចិត្ត គឺជាកត្តា...............មនុស្សគ្រប់រូប ដើម្បីសម្រេចចិត្ត................... ឱ្យគេគិតពិចារណាឱ្យបានវែងឆ្ងាយ ..................................ឬអ្នកដែលនៅជុំវិញខ្លួន ជៀសវាងការសម្រេចចិត្តដោយខ្លួនឯង ឬសម្រេចចិត្តដោយអត្តនោម័តិដែលអាចបណ្តាលឱ្យមាន ទុក្ខសោក ................................ ឬនាំទុក្ខដល់ខ្លួនឯង។
- ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានមតិមួយលើកឡើងថា៖ "លើកប្រធានមកសរសេរ"។
- ចំណោទបញ្ហា៖តើទស្សនៈនេះ................................. ដូចម្តេច? តើការសម្រេច.............................. ចំពោះខ្លួនឯង និងអ្នកដទៃ?

### ខ. តួសេចក្តី៖

ឃ្លាភ្ជាប់សេចក្តី

- ពន្យល់ពាក្យ៖ អត្តនោម័តិ៖ ការទទួលយកតែគំនិតរបស់ខ្លួនឯង គិតថាសុទ្ធតែត្រឹមត្រូវទាំងអស់ ដោយមិនពិភាក្សាជាមួយអ្នកដទៃ។
- ទុក្ខទោសសំដៅទៅលើ ផលពិបាក ទុក្ខកង្វល់ ការព្រាត់ប្រាស់ សេចក្តីអន្តរាយ។
- ពន្យល់ន័យប្រធាន៖ដូចនេះប្រធានខាងលើមានន័យថា ការសម្រេចចិត្ត.................................. គិតថាខ្លួនធ្វើសុទ្ធ........................ នាំឱ្យជួបនូវ ទុក្ខវេទនា.................................. សេចក្តីអន្តរាយដល់ខ្លួនឯង និងអ្នកដទៃ។

បកស្រាយប្រធាន៖

- ➢ គំនិតគាំទ្រប្រធាន៖
  - ជាការពិតណាស់ការសម្រេចចិត្តដោយអត្តនោម័តិនាំឱ្យមានទុក្ខទោសដល់ខ្លួនឯង និងអ្នកដទៃ៖
  - **ព្រោះការសម្រេចចិត្តតែម្នាក់ឯង**
  - មិនមែនសុទ្ធតែល្អសុទ្ធតែត្រឹមត្រូវនោះទេ
  - បើសម្រេចចិត្តខុស
  - វាអាចធ្វើឱ្យយើងជួបនូវ ការវិនាសព្រាត់ប្រាស់ បែកបាក់គ្រួសារ

- បង្កជាទំនាស់ បាត់បង់ទ្រព្យសម្បត្តិ បុណ្យសក្តិ មិត្តភក្តិ កិត្តយស ការងារ ពេលវេលាស្នេហា...។
- **ចំពោះអ្នកដទៃ៖** ធ្វើឱ្យអ្នកដទៃនៅជុំវិញ មានបញ្ហាជាប់ទោស បាត់បង់ជីវិតក៏មាន............................

និយាយរួមៈផលវិបាកដ៏ធ្ងន់ចំពោះខ្លួនឯងដែលកើតពីការសម្រេចចិត្តដោយអត្តនោម័តិគឺ មានដូចជា ធ្វើឱ្យបាត់បង់កិត្តិយស ការងារ ឬមានទោស............................។

## ជាក់ស្តែងក្នុងសង្គម៖

- ការសម្រេចចិត្តទៅដើរលេងមិនឱ្យគ្រួសារដឹង.....................អាចមានគ្រោះថ្នាក់.....................................................គេក៏មានដោយសារយើង(អ្នកទៅជាមួយ)........................ការគេចសាលា............................................................អាចបបួលគេដើរផ្លូវខុស ជាប់ទោសការសម្រេចចិត្ត ស្ថិតក្នុងអំពើទុច្ចរិត ដូចជា ឆក់ប្លន់ លួចទ្រព្យសម្បត្តិអ្នកដទៃ ឬសម្លាប់ជីវិតគេដោយប្រការណាមួយ................ខ្លួនឯងជាប់ទោស...........អ្នកដទៃស្លាប់

.....................................................................................................

- ការសម្រេចចិត្តក្នុងការដឹកនាំប្រទេសដោយអត្តនោម័តិ ................ខ្លួនឯងអន្តរាយ...............................។ប្រទេសជាតិ ប្រជាជនរងទុក្ខ.............................
- ក្នុងគ្រួសារដោយការសម្រេចចិត្តអត្តនោម័តិនាំឱ្យគ្រួសារ មិនគោរព.........ឈ្លោះគ្នា...................គ្មានការរីកចម្រើន .................................ក្នុងគ្រួសារគ្មានសុភមង្គល ........................បាត់បង់សមាជិតគ្រួសារ

**ក្នុងប្រវត្តិសាស្ត្រ៖** ព្រះបាទជ័យជេដ្ឋាទី២ ដោយសារតែបំពេញសេចក្ដីត្រូវការរបស់ខ្លួន ក៏សម្រេចចិត្តដោយខ្លួនឯង ......................................ខ្លួនឯងប្រជាជនមិននឹករឭក ស្អប់គ្មានកិត្តិយស...............................បាត់បង់ប្រទេសជាតិ ...............................................។

## អក្សរសិល្ប៍

- ជាក់ស្ដែងរឿងថៅកែចិត្តចោរយើងឃើញ តួអង្គពូហំត្រូវថៅកែបណ្ដេញពីការងារហើយត្រូវជាប់គុកដោយសារគាត់ប្រព្រឹត្តអំពើទុច្ចរិត បើកឡានទៅបុកឡានថៅកែហុងលី ធ្វើឱ្យមានអ្នកស្លាប់បីនាក់ និងរបួសជាច្រើននាក់ .....................................។ ដោយសារអំពើរបស់ពូហំធ្វើឱ្យ

អ្នកដទៃត្រូវបាត់បង់ការងារ

...........................................................................................

- រឿងទុំទាវ៖ ម្តាយទាវក្នុងរឿងទុំទាវគាត់សម្រេចចិត្តដោយអត្តនោម័តិ ក្នុងការរើសគូស្រករឱ្យទាវ...............................។ គាត់ត្រូវប្រហារជីវិត......................................................អ្នកចូលរួមជាមួយត្រូវជាប់ទោសប្រហារជីវិត និងជាប់ទោសជាអ្នកងារ....................................................។
- រឿងរាមកេរ្តិ៍៖ ក្រុងរាពណ៍មិនស្តាប់នរណា សម្រេចចិត្ត ត្រូវតែខ្លួនឯង...................ខ្លួនឯងត្រូវស្លាប់..................បាត់បង់កូនទាំងដប់ ខ្ទេចខ្ទីនគរលង្កា
- រឿងផ្កាស្រពោន៖ ការសម្រេចចិត្តដោយអត្តនោម័តិរបស់គាត់ក្នុងការទុកដាក់គូស្រករឱ្យនាងវិធាវី គាត់បង្ខំនាងឱ្យរៀបការជាមួយណៃ ស៊ត ដែលនាំឱ្យនាងកើតទុក្ខរីងរៃ គ្រាំចិត្តរហូតធ្លាក់ខ្លួនឈឺ..........................បន្សល់ទុកវេទនាដល់គូស្នេហ៍ ការសោកស្តាយ.....................................................
(សិស្សអាចលើករឿងផ្សេងបាន)

***សរុបសេចក្តីមក*** យើងឃើញថា ការសម្រេចចិត្តដោយអត្តនោម័តិគឺពិតជានាំមកនូវ ទុក្ខទោសដល់ខ្លួនឯងដូចជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយស ការងារ មានទោសជាប់គុក .................................................

និងនាំឱ្យបាត់បង់ជីវិតរបស់ខ្លួនទៀត។ រីឯអ្នកដទៃវិញធ្វើឱ្យគេបាត់បង់ការងារ ក្រុមគ្រួសារធ្លាក់ខ្លួនក្រ មានការឈឺចាប់ .........................................................ជូនកាលពួកគេត្រូវបាត់បង់ជីវិតទៀតផង។

## គ. សេចក្តីបញ្ចប់៖

- វាយតម្លៃប្រធានះឆ្លងតាមការរៀបរាប់ខាងលើយើងឃើញថាប្រធានពិតជាមានអត្ថន័យ និងខ្លឹមសារជ្រាលជ្រៅណាស់ ព្រោះបានផ្តល់ជាតម្លៃអប់រំជាច្រើនដល់មនុស្សក្នុងការសម្រេចចិត្តប្រកបដោយ.................................................. ព្រមទាំងផលវិបាកជុំវិញការសម្រេចចិត្តដោយអត្តនោម័តិ។
- ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះ ក្នុងនាមយើងជា កុលបុត្រកុលធីតាខ្មែរត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រ ហើយយកចំណេះដឹងទាំងនោះទៅប្រើប្រាស់ក្នុងការសម្រេចចិត្តប្រកបដោយភាពត្រឹមត្រូវ សុក្រិត និងយុត្តិធម៌.................
- សុភាសិត ឬពាក្យស្លោក៖ " នៅម្នាក់ឯងប្រយ័ត្នគំនិត

**ប្រធានទី១៣៖**មានមតិជាច្រើនបានលើកឡើងថា៖ "ចំណេះវិជ្ជា មានតម្លៃយ៉ាងវិសេសដែលអាចធ្វើឱ្យ មនុស្សមានសុភមង្គលយូរអង្វែងបាន" ។ ចូរពន្យល់ឱ្យបានក្បោះក្បាយព្រមទាំងលើកឧទាហរណ៍បញ្ជាក់ផង។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ ឆ្លងកាត់នូវបទពិសោធរបស់មនុស្ស ...............................................ឧបសគ្គទាំងនោះបានធ្វើអឱ្យមនុស្សចេះប្រើប្រាជ្ញាដើម្បីដោះស្រាយ .................................... បានផ្តុកទៅដោយចំណេះវិជ្ជាយកមកដោះស្រាយបានប្រកបដោយ ...............................................។
- ចំណូលបញ្ហា៖ ហេតុនេះហើយទើបមានមតិជាច្រើនយល់ឃើញថា " លើកប្រធានមកសរសេរ"។
- ចំណោទបញ្ហា៖តើ................ មានអត្ថន័យដូចម្តេចដែរ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ មុននឹងធ្វើការបកស្រាយទស្សនៈខាងលើនេះ......................................... ចំនួនជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យថា "ចំណេះវិជ្ជា" និង "សុភមង្គល"
- ពន្យល់ន័យប្រធាន៖ អត្ថន័យរបស់ប្រធាននេះចង់និយាយថា ការចេះដឹងនូវជំនាញផ្សេងៗឱ្យ ......................... យូរអង្វែង ផ្ទុយទៅវិញបើមនុស្សមិនមានចំណេះវិជ្ជាទេ ................................ក៏មិនបានទទួលផលល្អប្រសើរដូចអ្នកដែលមានតម្រិះវិជ្ជានោះដែរ។
- បកស្រាយប្រធាន៖

**គំនិតគាំទ្រប្រធាន៖**

ជាការពិតណាស់ការដែលមានចំណេះវិជ្ជាឬជំនាញ ណាមួយឱ្យបានច្បាស់លាស់រមែងឱ្យយើង៖

- ចំណេះកើតពីការខំប្រឹងប្រែង ស្វះស្វែងរៀនសូត្រ
- ចំណេះវិជ្ជាមិនអាចកើតឡើងដោយគ្មានការខំប្រឹងនោះទេ
- មានចំណេះវិជ្ជា ធ្វើឱ្យមនុស្សមានកិត្តិយស សក្តិយស...
- ធ្វើឱ្យយើងអាចដោះស្រាយបញ្ហាមានភាពងាយស្រួល...
- មានសមត្ថភាពក្នុងការប្រកបការងារ......
- ឱ្យមានសេចក្តីសុខ សុភមង្គល ហើយមានកិត្តិយស ..........................................។

**ជាក់ស្តែង៖**

### ក. នៅក្នុងសង្គម

- សម្រាប់ការសិក្សារបស់សិស្សឬយុវជននោះក៏ជាការអភិវឌ្ឍខ្លួន ក្នុងការពង្រឹងសមត្ថភាពនិងគុណភាពតាំងពីចំណេះដឹងទូទៅនិងតាំងពីថ្នាក់តូចឡើងទៅជាបន្តបន្ទាប់រហូតដល់ថ្នាក់ខ្ពស់។
- មានចំណេះវិជ្ជា មិនងាយនឹងចាញ់បោក អាចបញ្ចៀសផុតពីការគេងប្រវ័ញ្ចគ្រប់រូបភាពពីជនខិលខូចនៅក្នុងសង្គម។(សិស្សអាចឧទាហរណ៍ក្រៅពីនេះ)

### ខ. ក្នុងប្រវិត្តសាស្ត្រ

- ព្រះបាទអង្គឌួង មិនត្រឹមតែជាក្សត្រដែលគិតគូរពីប្រទេសលើការឈ្លានពានពីយួននឹងសៀមទេ ព្រះអង្គជាអ្នកមានចំណេះដឹងជ្រៅជ្រះ និងជាអ្នកនិពន្ធខ្មែរល្បីល្បាញមួយរូបក្នុងសម័យកាលនោះផងដែរ ព្រះអង្គពូកែខាងកំណាព្យកាព្យឃ្លោង។ ព្រះអង្គបាននិពន្ធរឿង ចំប៉ាថោង, ច្បាប់ស្រី, កាកី ជាដើម។(សិស្សអាចលើកតួអង្គផ្សេង)

គ. ក្នុងអក្សរសិល្ប៍

- រឿងកុលាបប៉ៃលិន៖ ដោយសារតែចំណេះវិជ្ជា ធ្វើឱ្យតួអង្គចៅចិត្ររំដោះខ្លួនចេញពីភាពកម្មករ មកជាអ្នក

ត្រួតមើលបញ្ជីត្បូងរួចក្លាយជាកូនប្រសាថៅកែត្បូងថែមទៀត។

- រឿងធនញ្ជ័យ៖ តួអង្គធនញ្ជ័យត្រូវបានទទួលរងនូវការប្រមាថពីសំណាក់មន្ត្រីខិលខូចមានទាំងសេដ្ឋី និងស្តេចផង តែដោយសារធនញ្ជ័យមានប្រាជ្ញាធនញ្ជ័យអាចការពារខ្លួនបានគ្រប់ពេល។
- រឿងតេជោយ៉ត៖ ខំព្យាយាម...មានទំនុកចិត្ត...ក្លាយជាមេទ័ព...មានកេរ្តិ៍ឈ្មោះ....

- សរុបសេចក្តី៖ សរុបមកចំណោះវិជ្ជានាំឱ្យ..................មនុស្សមានវិន័យ និងសេចក្តីថ្លៃថ្នូរក្នុងជីវិតរស់នៅ។

## គ. បញ្ចប់សេចក្តី

- វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា មតិរបស់ប្រធាន ខិតខំរៀនសូត្រ.......................................។
- មតិផ្ទាល់ខ្លួន៖ ដូចនេះយុវជនទាំងឡាយ មិនត្រូវបណ្តោយ ឱ្យពេលវេលាដ៏មានតម្លៃក្នុងការសិក្សារៀនសូត្រកន្លងទៅអសារបង់ឡើយ.............................................។

***ប្រធានទី១៤៖*** តួអង្គ**នៅ**ក្នុងរឿង ភូមិតិរច្ឆានបាននិយាយថា«បារាំងមានអំណាចលើខ្មែរយើង បើយើងសម្លាប់បារាំងមួយ គេក៏ហ៊ានសម្លាប់យើងបានដប់ម្ភៃដែរ»។ ហេតុអ្វីបានជា***នៅ***ពោលបែបនោះ។ ចូរបង្ហាញ ។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- ✓ លំនាំបញ្ហា៖ ប្រទេសកម្ពុជាបានស្ថិតក្រោមនឹមត្រួតត្រារបស់ពួកអាណានិគមនិយមបារាំង បានធ្វើឱ្យប្រជាជនខ្មែរ... ដោយទ្រាំនឹងការឈឺចាប់មិនបានទើប...
- ✓ ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ " បារាំង..." ។
- ✓ ចំណោទបញ្ហា៖ តើសម្តី...អត្ថន័យដូចម្តេច?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ មុននឹងធ្វើការបកស្រាយ...
- ពន្យល់ពាក្យ៖ អំណាច...
- ពន្យល់ន័យប្រធាន៖ ប្រធាននេះគេចង់បញ្ជាក់ពីអ្វី?
- បកស្រាយប្រធាន៖
- ✓ សេចក្តីលម្អិតគាំទ្រលើប្រធាន៖ ជាការពិតណាស់ បារាំងបានត្រួតត្រាលើប្រទេសខ្មែរ...

**បង្ហាញពីចំណុចខ្លាំង ឬអំណាចរបស់បារាំង៖**

- ✓ ក្មែកបារាំងច្រើនដូចក្មែកម្នាស់
- ✓ បារាំងកេណ្ឌប្រជាជនខ្មែរទៅធ្វើជាទ័ពដើម្បីច្បាំងជាមួយអាល្លឺម៉ង់
- ✓ តម្លើងពន្ធគ្រប់រូបភាព
- ✓ យកវត្ថុអារាមហាត់ទ័ព(ថែវព្រះវិហារព្រះកែវមរកត)
- ✓ ពេលខ្មែរសម្លាប់បារាំងម្នាក់ឈ្មោះកូម៉ែយចោទខ្មែរថាជាចោរ
- ✓ បាដេសចេញទារពន្ធដោយខ្លួនឯង
- ✓ បាដេសដាក់ខ្នោះអ្នកមិនមានប្រាក់បង់ពន្ធ

**បង្ហាញពីផលវិបាកក្រោយពីសម្លាប់បាដេស**

- ✓ ប្រជាជនខ្មែរមិនបានរស់នៅក្នុងភូមិព្រោះរត់គេច
- ✓ ចាប់ប្រជាជនខ្មែរដាក់គុក
- ✓ បាញ់សម្លាប់ខ្មែរដោយមិនញញើត
- ✓ ភូមិក្រាំងលាវត្រូវដូរឈ្មោះជាភូមិតិរច្ឆាន
- ✓ អ្នកភូមិជាប់ឈ្មោះជាអ្នកទោស ហើយចំណាយប្រាក់ដើម្បីធ្វើបុណ្យ

ការសម្លាប់នេះក្រុមអ្នកដឹកនាំឈ្មោះ ជួន និង នៅមានគោលបំណង

- ✓ ចង់ឱ្យប្រទេសខ្មែររួចផុតពីនឹមអាណានិគមនិយមបារាំង

- ✓ ចង់បានសេរីភាពជូនប្រជាជនខ្មែរ
- ✓ ចង់ទុកឈ្មោះឱ្យកូនខ្មែរជំនាន់ក្រោយបានដឹង
- ✓ ចង់បង្ហាញពីការសាមគ្គី រួបរួមជាកម្លាំងតែមួយចង់ឱ្យកូនខ្មែរចេះតស៊ូក្នុងជីវិត ទោះស្ថិតក្រោមអំណាចបារាំងក៏ដោយ

សរុបសេចក្ដី៖ សរុបន័យដែលបានបកស្រាយ

**គ. សេចក្ដីបញ្ចប់**

- វាយតម្លៃប្រធាន៖ ក្រោយពីបានបកស្រាយ..............
- ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះ........................................
- ប្រសិនបើមានពាក្យស្លោក ឬសុភាសិតដែលទាក់ទងនឹងប្រធានគឺអាចដាក់បាន

**ប្រធានទី១៥៖ មានទស្សនៈមួយពោលថា**«អក្សរសិល្ប៍ពុទ្ធនិយមមានវិធីអប់រំពីរយ៉ាង គឺការទូន្មានប្រៀនប្រដៅឱ្យធ្វើល្អតាមទ្រឹស្តីពុទ្ធសាសនា និងការបន្លាចដោយវិធីបង្ហាញការដាក់ទោសឱ្យមានបាបកម្មយ៉ាងធ្ងន់ធ្ងរ»។ ចូរពន្យល់ទស្សនៈខាងលើនេះដោយលើកយកឧទាហរណ៍ ក្នុងរឿងមហាវេស្សន្តរជាតកមកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖និយាយឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖លើកប្រធានមកដាក់
- ចំណោទបញ្ហា៖ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ(អក្សរសិល្ប៍ពុទ្ធនិយម គឺជាអក្សរសិល្ប៍ដែលផ្តេកគំនិតតាមទ្រឹស្តីនៃព្រះពុទ្ធសាសនា...។ បន្លាច ធ្វើឱ្យខ្លាច...។ បាបកម្មមានន័យថាការធ្វើអំពើអាក្រក់តាមដំណើរដែលខុសឆ្គង...។)
- ពន្យល់ន័យប្រធាន៖ អក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនាប្រើវិធីពីរយ៉ាង គឺការទូន្មានប្រៀន

ប្រដៅឱ្យធ្វើអំពើល្អតាមគោលការណ៍នៃពុទ្ធនិយម និងធ្វើឱ្យខ្លាចដោយវិធីដាក់ទោសចំពោះទង្វើខុសឆ្គង ឬដោយអំពើអាក្រក់...។

- **បកស្រាយប្រធាន៖**
  - អក្សរសិល្ប៍ពុទ្ធនិយម
    - ✓ ទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា
    - ✓ ទាក់ទងនឹងបញ្ហាកម្មផលបុណ្យបាប
    - ✓ ពៀររំងាប់ដោយការមិនចងពៀរ
    - ✓ ការដោះស្រាយបញ្ហាទំនាស់ដោយប្រើធម៌អហិង្សា
    - ✓ បង្ហាញឱ្យឃើញពីកម្មរបស់មនុស្ស ធ្វើល្អទទួលបានផលល្អ ធ្វើអាក្រក់នឹងទទួលផលអាក្រក់
    - ✓ ឆ្លុះបញ្ចាំងឱ្យឃើញពីកម្មផលបីយ៉ាងគឺ កម្មអតីតជាតិហុចផលទៅបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលក្នុងបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលទៅអនាគតជាតិ...

តាមការសង្កេត ជាទូទៅចំពោះអក្សរសិល្ប៍បែបពុទ្ធនិយមបានឱ្យឃើញថា អ្នកនិពន្ធតែងតែប្រើវិធីពីរយ៉ាងដើម្បីអប់រំមនុស្ស៖

- ***អប់រំតាមវិធីទីមួយបែបត្រជាក់(អប់រំឱ្យធ្វើអំពើល្អ)***

✓ ទូន្មានឱ្យធ្វើល្អទាំងកាយ ទាំងចិត្ត នឹងនាំឱ្យយើងបានសេចក្តីសុខ

✓ចេះពិចារណារកហេតុផលដោយប្រើបញ្ញានាំឱ្យយើងមានសុខសន្តិភាព

✓ ការធ្វើល្អ សន្សំកុសលដើម្បីសមតាមបំណងអ្វីមួយដែលខ្លួនប៉ង

✓ ការចែករំលែក ជួយគ្នាទៅវិញទៅមកផលហុចផលឱ្យពេលយើងមានទុក្ខមានគេជួយ

✓ ជឿថាអ្នកធ្វើល្អនឹងឡើងឋានសួគ៌...

ដោយរូបភាពបែបនេះហើយ ធ្វើឱ្យមនុស្សប្រព្រឹត្តអំពើល្អ ..........................................................................។

- ***អប់រំតាមវិធីទីពីរ ដាក់ទោសឱ្យទទួលបាបកម្ម***

✓ បន្លាចឱ្យខ្លាចពីផលអាក្រក់

✓ ធ្វើឱ្យមនុស្សតក់ស្លុតចំពោះទង្វើអាក្រក់ រអាលែងហ៊ានប្រព្រឹត្ត

✓ បង្ហាញឱ្យឃើញពីការដាក់ទោសឱ្យធ្លាក់នរក

✓ បង្ហាញឱ្យឃើញកើតជាសត្វតិរច្ឆានបើមានការកាប់សម្លាប់សត្វ...

✓ អាចមិនសមតាមបំណង

✓ បង្ហាញឱ្យឃើញពីការការនិទ្ធាររបស់អ្នកដទៃចំពោះខ្លួន ដោយសារទង្វើរបស់ខ្លួន...

ដោយឃើញរូបភាពបែបនេះធ្វើឱ្យមនុស្សវៀរចាកការប្រព្រឹត្តអំពើអាក្រក..............................។

ឧទាហរណ៍៖

- ការប្រព្រឹត្តអំពើល្អ រឿងព្រះវេស្សន្តរ៖
- ព្រះអង្គធ្វើទានចំពោះមនុស្សគ្រប់ស្រទាប់វណ្ណៈ ផលទទួលបានគឺសេចក្តីស្រឡាញ់...គ្រាន់តែឮឈ្មោះព្រះវេស្សន្តរស្គាល់...
- ព្រះអង្គធ្វើទានចំពោះអ្នកបណ្តេញព្រះអង្គចេញពីព្រះនគរ ...អ្នកស្រុកស្រីពិរាស្ត្របាត់ខឹង ទទួលសាទរព្រះអង្គ គោរពស្រឡាញ់ព្រះអង្គ
- ការធ្វើល្អ ការចេះជួយអ្នកជួបបញ្ហារបស់ព្រះវេស្សន្តរ ធ្វើឱ្យព្រះអង្គយាងដល់ទីណាមានតែគេចង់បាន ចង់ការពារព្រះអង្គ(ស្តេចនៅមាតុលនគរ និងចេត្របុត្រ)
- ពេលសោយទិវង្គតបានកើតនៅឋានតុសិត
- ការធ្វើទានជាទ្រព្យមានសេចក្តីអំណាត់...ឱ្យទ្រង់បានសម្រេចក្នុងការត្រាស់ដឹង...។

***សិស្សអាចរកតួអង្គផ្សេងទៀតបាន***

- ✓ ចំពោះទង្វើអាក្រក់ តួអង្គតាជូជក និងនាងអមិត្តតាបនា ឬ អមិត្តធីតា
- ✓ តាជូជកសុំបុត្តពីព្រះវេស្សន្តរដើម្បីបំពេញតម្រូវការរបស់ខ្លួន ជាប្រយោជន៍របស់ខ្លួន មិនមែនសុំយកទៅមើលថែទាំទេ
- ✓ នាងអមិត្តធីតាចង់បានជាលី ក្រស្នាក្នុងគោលបំណងយក ទៅបម្រើជាខ្ញុំដែលជាប្រយោជន៍ខ្លួន
- ✓ តាជូជកត្រូវស្លាប់ដោយសារបែកពោះ ទាំងដែលគ្មានជំងឺ ដោយភាពលោភលន់ហួសប្រមាណនៃការបរិភោគហួស កម្រិត...
- ✓ ព្រោះតែទង្វើអ្នកទាំងពីរមិនបានជួយបំពេញទានឱ្យព្រះ វេស្សន្តរទេ តែជាការតាមព្យាបាទ ប្រកបដោយអគតិ មច្ឆា ទិដ្ឋិ មហិច្ឆតា និងបំពេញបំណងរបស់ខ្លួនតែប៉ុណ្ណោះ...ពេល ស្លាប់ទៅហើយត្រូវចុះនរក
- ✓ ភាពមិនឆ្អែតនៃតម្រេករបស់ខ្លួនបានធ្វើឱ្យនាងចុះនរក ស្លាប់ទៅជានាងចិញ្ចាមាណាវិកាមានមាត់ប៉ុនម្ជុល ពោះ ប៉ោង
- ✓ ទង្វើរបស់អ្នកទាំងពីរបានធ្វើឱ្យព្រះធរណីស្រូបធ្លាក់ចូលក្នុង នរកទៅក្នុងរណ្តៅអវចីទទួលទុក្ខទោសសែនវេទនាខ្លោច ផ្សារកទីបំផុតគ្មាន....។

សរុបសេចក្តី៖ អក្សរសិល្ប៍ពុទ្ធនិយម......................................។ រាល់ការបង្ហាញបែបនោះ ជាសិល្បវិធីក្នុងការអប់រំមនុស្សគ្រប់រូប ឱ្យចេះកសាងអំពើល្អវៀរចាកអំពើអាក្រក់គ្រប់យ៉ាង ដែលសង្គមស្អប់ខ្ពើមនោះ។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ឆ្លងតាម...បានបង្ហាញឱ្យឃើញថាប្រធាននេះបានផ្សារភ្ជាប់នឹងផ្នត់គំនិតខ្មែរ ដែលនិយមប្រកាន់ខ្ជាប់ព្រះពុទ្ធសាសនា ដោយការរក្សាសីលទាន ដើរតាមផ្លូវសុចរិត ទៀងត្រង់។ លើសពីនេះប្រធាននេះបានអប់រំមនុស្ស ..........................................។
- ទស្សនៈស្មេរ៖

**ប្រធានទី១៦៖** *សុភាសិតខ្មែរបានចែងថា«ការងារជាមាសប្រាក់»។ ចូរអ្នកបកស្រាយដោយលើកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់*

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សទាំងឡាយរមែងតែងចង់បាននូវទ្រព្យសម្បត្តិមាសពេជ្រកែវកង របស់របរមានតម្លៃសម្រាប់ខ្លួនជានិច្ច។ ដើម្បីបានសម្រេចតាមបំណងប្រាថ្នានេះ ល្អិកណាយើងស្វះស្វែងរកការងារដែលត្រឹមត្រូវ ធ្វើជាប្រចាំ។
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ការងារ មាសប្រាក់
- ពន្យល់ន័យប្រធាន៖ ការងារទាំងឡាយណាដែលជាមុខរបរត្រឹមត្រូវពិតជាទ្រព្យសម្បត្តិ...។

- *បកស្រាយប្រធាន៖ ការងារនៅទីនេះសំដៅទៅដល់ការងារទាំងឡាយណាដែលត្រឹមត្រូវ សុចរិតទៀងត្រង់ស្របទៅតាមច្បាប់សង្គម និងមិនធ្វើឱ្យប៉ះពាល់ផលប្រយោជន៍អ្នកដទៃ។*
- ***រូបភាពនៃការងារទាំងនោះមាន៖***
  - ✓ *កសិករ៖ ធ្វើស្រែចម្ការដើម្បីទទួលបានទិន្នផល*
  - ✓ *កម្មករ៖ ធ្វើការដោយប្រើកម្លាំងប្រាក់ដើម្បីទទួលបានប្រាក់កម្រៃ*
  - ✓ *ពាណិជ្ជករ៖ រកស៊ីលក់ដូរដើម្បីផលចំណេញ*
  - ✓ *ការងារមន្ត្រីរាជការ*
  - ✓ *សិល្បករ...*
- ***លក្ខណៈការងារដែលទទួលបាននូវតម្លៃល្អសម្រាប់ជីវិតមនុស្ស***
  - ✓ *មានភាពសុចរិតត្រឹមត្រូវសមស្របក្នុងសង្គម*
  - ✓ *ការងារបង្រៀនឱ្យមនុស្សមានការពិចារណាខ្ពស់*

- ✓ ការងារធ្វើឱ្យមនុស្សមានក្រមសីលធម៌ខ្ពស់ ចេះអធ្យាស្រ័យគ្នា គោរពច្បាប់
- ✓ ការងារបម្រើមនុស្សជាតិ និងប្រទេសជាតិ

- **ផលប្រយោជន៍**
  - ✓ ទទួលបានប្រាក់កម្រៃសម្រាប់ផ្គត់ផ្គង់គ្រួសារ
  - ✓ សេដ្ឋកិច្ចគ្រួសារមានភាពរីកចម្រើនទៅមុខជាលំដាប់
  - ✓ ជីវភាពគ្រួសារមានស្ថេរភាពយូរអង្វែង
  - ✓ មានកេរ្តិ៍ឈ្មោះល្បីល្បាញ
  - ✓ មានភាពល្អប្រសើរក្នុងជីវិត
  - ✓ គ្រួសារមានសុភមង្គល និងសេចក្ដីសុខ
  - ✓ សង្គមជាតិទទួលបានសុខសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ...
- អំណះអំណាង
  - ✓ រឿងកុលាបប៉ៃលិន
  - ✓ រឿងមាយើង
  - ✓ រឿង ថៅកែចិត្តចោរ(ផ្ទុយ)

សរុបសេចក្ដី៖ ...ការងារពិតជាមាសប្រាក់ពិតប្រាកដមែន ព្រោះថាលុយកាក់ទ្រព្យសម្បត្តិពិតជាកើតមានឡើងដោយការប្រកបកិច្ចការ

ទាំងអស់ បើពុំសោតនោះទេមិនអាចទទួលបានមានសប្រាក់នោះទេ។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖...មានអត្ថន័យ តម្លៃល្អជ្រាលជ្រៅបំផុតអំពី...នាំឱ្យកើតមានទ្រព្យសម្បត្តិ...
- មតិផ្ទាល់៖ ...ខិតខំធ្វើកិច្ចការណាសុចរិត...។

**ប្រធានទី១៧៖** មានទស្សនមួយចែងថា«ការអប់រំគឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត»។ ចូរបកស្រាយដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- ✓ លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងនឹងប្រធាន
- ✓ ចំណុចបញ្ហា៖ លើកប្រធានមកសរសេរ
- ✓ ចំណោទបញ្ហា៖ ចោទបែបពន្យល់

### ខ. តួសេចក្តី

- ✓ឃ្លាភ្ជាប់សេចក្តី
- ✓ ពន្យល់ពាក្យ៖ ការអប់រំ សិទ្ធិ សេចក្តីថ្លៃថ្នូរ
- ✓ ពន្យល់ន័យប្រធាន
- ✓ បកស្រាយប្រធាន៖ មនុស្សយើងម្នាក់អាចធ្វើឱ្យជីវិតរបស់ខ្លួនឯងទទួលបានភាពថ្លៃថ្នូរដោយសារតែបុគ្គលមានសិទ្ធិទទួលការអប់រំលើផ្នែក សីលធម៌

គុណធម៌ សុជីវធម៌ ចំណេះដឹងជំនាញផ្សេង ព្រម ទាំងអប់រំឱ្យស្រឡាញ់ប្រទេសជាតិមាតុភូមិ...។

- ✓ គំនិតគាំទ្រ

  រូបភាពនៃការអប់រំ

  - ➢ ការអប់រំក្នុងគ្រួសារ៖
  - ➢ ការអប់រំក្នុងសាលារៀន៖
  - ➢ ការអប់រំក្នុងសង្គម៖

- ✓ លក្ខណៈថ្លៃថ្នូរដែលមនុស្សចង់បាន៖
  - ➢ ចង់មានមុខមាត់ក្នុងសង្គម
  - ➢ ចង់ឱ្យសង្គមទទួលស្គាល់
  - ➢ ចង់បានការងារសមស្របតាមច្បាប់សង្គម
  - ➢ .................................................................

- ✓ លទ្ធផល
  - ➢ មានការងារ មានមុខរបរ...
  - ➢ សម្រេចតាមបំណង...
  - ➢ .................................................................

ឧទាហរណ៍៖

- ការអប់រំក្នុងគ្រួសារ៖ រឿង កុមារកំព្រា រឿងកុលាបប៉ៃលិន ថៅចិត្រស្តាប់តាមការអប់រំរបស់ឪពុក...ជីវិតរបស់ពួកគេមានជីវភាពធូរធារ...។
- ការអប់រំនៅសាលា៖ រឿងគូលីកំណៃន រឿង មាលាដួងចិត្ត ...ជីវិតរបស់ពួកគេមានមុខងារ មានកិត្តិយស សក្តិយស...។
- ការអប់រំក្នុងសង្គម៖ រឿងធនញ្ជ័យ រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់...មានប្រាជ្ញា ក្នុងការជួយជីវិតខ្លួនឱ្យរួចផុតពីការជិះជាន់...។

**សរុបសេចក្តីមក៖**

## គ. សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន
- ✓ ទស្សនៈផ្ទាល់ខ្លួន

**ប្រធានទី១៨៖** *ករីរាជសម្ភារបានថែងថា«ខ្លែងហើរដ្បិតខ្យល់»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។*

## គម្រោងតែង

### ក. សេចក្ដីផ្ដើម

- ✓ លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ✓ ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ✓ ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្ដី

- ✓ ឃ្លាភ្ជាប់សេចក្ដី
- ✓ ពន្យល់ពាក្យ៖ ខ្លែង ខ្យល់
- ✓ ពន្យល់នយប្រធាន
- ✓ បកស្រាយប្រធាន៖

– **ន័យចំ៖** មានន័យថាខ្លែងអាចហោះហើរលើអាកាសបានដោយសារតែមានខ្យល់សម្រាប់ទ្រទ្រង់ ឬពឹងលើខ្យល់តែម្ដង

✓ **ពង្រីកគំនិត**

– គេបង្ហោះខ្លែងនៅរដូវខ្យល់ធ្លាក់

- ខ្លែងធ្វើផ្លង់ផ្កាស្ទិច បំពង់ឫស្សី ដែលមានទម្ងន់ប្រហែលគ្នា
- ខ្លែងមានក្បាល តួ ត្រចៀក និងកន្ទុយ
- ខ្លែងហើរលើវេហា ឮសំឡេងកូតជាមួយខ្យល់
- បើគ្មានខ្យល់ ខ្លែងក៏ហើរមិនរួចដែរ
- ហើយពេលខ្លែងរក្សាបានក្នុងលំហអាកាសហើយ បើអស់ខ្យល់ ខ្លែងនឹងធ្លាក់មក
- បើមានខ្យល់ខ្លាំង ខ្យល់ព្យុះនោះខ្លែងនឹងធ្លុះរហែក...

• **ន័យធៀបៈ** ខ្លែងប្រៀបទៅនឹងបុគ្គលគ្រប់ស្រទាប់វណ្ណៈ មានក្រ ប្រុសស្រី ចាស់ក្មេង

✓ ហើរលើវេហាសំដៅលើការជោគជ័យរបស់មនុស្ស ទ្រព្យកិត្តិយស...

✓ ខ្យល់សំដៅមនុស្សភាគីជាដៃគូ អ្នកជួយជ្រោមជ្រែង អ្នកជួយឧបត្ថមប្រៀបទៅនឹងបុគ្គលដែលមានការជោគជ័យ...គឺត្រូវអ្នកជួយណែនាំជ្រោមជ្រែង...។

- ពង្រីកគំនិត

✓ មនុស្សរស់នៅក្នុងសង្គមត្រូវទំនាក់ទំនង ទាក់ទងគ្នា ជួយគ្នាការពារគ្នាទៅវិញទៅមក

✓ មនុស្សមិនអាចរស់នៅម្នាក់ឯងបានទេ

✓ តែបើមនុស្សអាងភ្លេចខ្លួន អាងតែជំនួយនឹងវិលមកសភាពដើមវិញ

- ✓ បើជួយមនុស្សខុស បង្កើននូវភាពឱ្យមានមនុស្សជាច្រើនខ្ជិល

ឧទាហរណ៍៖ រឿងរាមកេរ្តិ៍ ព្រះរាមអាចចេះចប់គម្ពីត្រៃវេទព្រោះមានឥសីពិស្វាមិត្រជួយ...។ រឿងទុំទាវ៖ ទុំអាចមានងារជាម៉ឺនឯកដោយសារព្រះរាជាតែងតាំង...។

រឿងព្រះវេស្សន្តរ៖ព្រះនាងមទ្រី ជាលិក្រស្នាជួយបំពេញទាន...។

សរុប៖

## គ.សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន
- ✓ ទស្សនៈផ្ទាល់ខ្លួន

ប្រធាន១៩៖ មានមតិមួយពោលថា«វិស័យអប់រំមានការរីកចម្រើនដោយសារប្រទេសជាតិមានសន្តិភាព»។ ចូរពន្យល់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ វិស័យអប់រំជាវិស័យមួយត្រូវបានយកចិត្តទុកដាក់បំផុត ព្រោះវាជាមធ្យោបាយដ៏សំខាន់ក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព។ វិស័យនេះអាចដំណើរការទៅបាន ពឹងផ្អែកទាំងស្រុងលើស្ថានភាពនយោបាយប្រទេស ពិសេសសុខសន្តិភាពតែម្តង។
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យគន្លឹះ៖ វិសយអប់រំ សន្តិភាព
- ពន្យល់ន័យប្រធាន៖ រាល់ការសិក្សារៀនសូត្រ បង្ហាត់បង្រៀនអប់រំ ទូន្មាន ណែនាំ មនុស្សគ្រប់វិស័យឱ្យមាន

សមត្ថភាព ទាំងចំណេះដឹង ចំណេះធ្វើ គុណធម៌ល្អរលូនទៅមុខបានដោយពឹងផ្អែកភាពសន្តិសុខក្នុងសង្គម។

- បកស្រាយប្រធាន៖
  - ✓ រូបភាពប្រទេសជាតិមានសន្តិភាព
    - ➢ គ្មានសង្គ្រាម ចម្បាំងរាំងជល់
    - ➢ សុខស្ងប់ប្រកបដោយសុខសន្តិភាព
    - ➢ គ្មានភាពភ័យខ្លាច
    - ➢ សុខសាន្តទាំងផ្លូវកាយវាចាចិត្ត
    - ➢ ធ្វើដំណើរដោយសេរី
    - ➢ គ្មានទំនាស់ ការបាញ់ប្រហារ កាប់សម្លាប់មនុស្ស
    - ➢ គ្មានចោរកម្ម លួចឆក់ប្លន់
    - ➢ គ្មានអណាធិបតេយ្យ...

កាលបើប្រទេសជាតិមានសន្តិភាពពេញលេញគ្រប់គ្រាន់ គ្រប់ទីកន្លែងនោះវាបានធ្វើឱ្យវិស័យអប់រំមានការរីកចម្រើនដូចជា៖

- ➢ មានសាលារៀនគ្រប់ភូមិសិក្សា គ្រប់តំបន់
- ➢ បង្កើតសាលាតាមមូលដ្ឋានដោយប្រមូលឱ្យសិស្សចូលរៀនគ្រប់កម្រិត
- ➢ ទាំងសាលារដ្ឋ និងឯកជនបើកទ្វារ

- មានសកលវិទ្យាល័យតាមបណ្តាលខេត្តសម្រាប់ឱ្យនិស្សិតបានបន្តការសិក្សា
- បណ្តុះយុវជនឱ្យមានចំណេះដឹង ជំនាញ ឥរិយាបថ
- ការអប់រំមានទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ
- មធ្យោបាយអប់រំសម្បូរបែប តាមប្រពន្ធផ្សព្វផ្សាយ អ៊ីនធើណេត ហ្វេសបុក
- បង្កើតឱ្យមានការអប់រំទូលំទូលាយផ្លូវលោក ផ្លូវធម៌
- បង្ហាញឱ្យឃើញពីវិធីសាស្ត្របង្រៀនសម្បូរបែប
- មានសម្ភារសិក្សាទំនើប ជាក់ស្តែង
- បណ្តុះនូវធនធានមនុស្ស ពលករជំនាញ
- ធ្វើឱ្យពលរដ្ឋ ឬសិក្សានុសិស្សអាចប្រកួតប្រជែងលើឆាកជាតិ និងអន្តរជាតិ...

ឧទាហរណ៍

- ✓ សង្គម៖ រាជរដ្ឋាបង្កើតសាលា...
- ✓ អក្សរសិល្ប៍៖ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- ✓ រឿង ផ្កាស្រពោន
- ✓ រឿង សូផាត

- សរុបសេចក្តី៖

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ក្រោយពីបានបកស្រាយ...
- មតិផ្ទាល់ខ្លួន៖ ដូចនេះ.................................
- ពាក្យស្លោក ឬសុភាសិត៖ ...........................

**ប្រធានទី២០៖** *អក្សរសិល្ប៍ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងសង្គម។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។*

# គម្រោងតែង

## ក. សេចក្តីផ្តើម

*-លំនាំបញ្ហា៖ សរសេរទាក់នឹងសង្គម ឬអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងពីសង្គម និង................។*

*-ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានទស្សនៈមួយលើកឡើងថា "អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម"*

*-ចំណោទបញ្ហា៖ តើទស្សនៈខាង លើនេះមានអត្ថន័យយ៉ាងណាខ្លះ?*

## ខ. តួសេចក្តី

*-ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយក្នុងការបកស្រាយនូវប្រធានខាងលើ យើងគប្បីយល់ន័យរបស់ពាក្យគន្លឹះជាមុនសិន។*

*-ពន្យល់ពាក្យគន្លឹះ*

- ✓ *អក្សរសិល្ប៍*

-ជាកម្រងអត្ថបទដែលលើកយកបញ្ហានៃមនុស្សក្នុងសង្គមមកចោទ និងដោះស្រាយ ទៅតាមសិល្បវិធី និងទៅតាមបរិយាកាសនៃសង្គមនីមួយៗ និងមានការវិវត្តទៅតាមសង្គមកាលនីមួយៗ។

-សង្គម: ការជួបជុំគ្នា ការប្រជុំគ្នា ការប្រមូលរួបរួមក្រុមមនុស្សជាច្រើន ដែលជាជនជាតិ មានសាច់ឈាម ពណ៌សម្បុរ វប្បធម៌ប្រពៃណី អត្តសញ្ញាណតែមួយ ជារដ្ឋ ឬ ប្រទេសមួយ។

- ✓ ពន្យល់ន័យប្រធាន៖ គ្រប់បញ្ហាទាំងឡាយរបស់សង្គមណាមួយ ទោះបីជា បញ្ហាល្អក្តី អាក្រក់ក្តី តែងតែត្រូវបានអ្នកនិពន្ធលើកយកមកបញ្ចូលទៅក្នុងស្នាដៃ អក្សរសិល្ប៍របស់ខ្លួនដើម្បីឆ្លុះបញ្ចាំងពីការពិតនៃសង្គម។

បកស្រាយប្រធាន៖

-អក្សរសិល្ប៍ តែងផ្សារភ្ជាប់ទៅនឹងតថភាពជាក់ស្តែងនៃសង្គមមនុស្ស កម្មវត្ថុរបស់អក្សរសិល្ប៍គឺសិក្សាពីបញ្ហានៃមនុស្ស ទោះជាអក្សរសិល្ប៍ខ្លះតួអង្គមិនមែនជាមនុស្ស ក៏អ្នកនិពន្ធបង្កប់អត្ថន័យខ្លឹមសារឆ្លុះបញ្ចាំងពីសង្គមមនុស្សដែរ

-ឆ្លុះបញ្ចាំងពីរបបនយោបាយ ការដឹកនាំ ការគ្រប់គ្រងប្រទេស រាជានិយម ផ្តាច់ការរបបអាណានិគម បញ្ហាជីវភាពរស់នៅ ឆ្លុះបញ្ចាំងពីបញ្ហានៅក្នុងសង្គមតាមសម័យកាលនីមួយៗជាដើម។

-ឆ្លុះបញ្ចាំងពីផ្នែកវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់នៃជាតិសាសន៍ក្នុងសម័យកាលណាមួយ។

ឧ. រឿងទុំទាវ (ស្នេហាយុវវ័យ ស្តេចត្រាញ់ ព្រះមហាក្សត្រ ជារបបសក្តិភូមិផ្តាច់ការ)

ឧ. រឿងភូមិតិរច្ឆាន (ការតស៊ូប្រឆាំងនឹងអាណានិគមបារាំង)

ឧ. រឿងរាមកេរ្តិ៍(ជំនឿ ផ្នត់គំនត់ និងទំនៀមទម្លាប់ជាច្រើន)

ឧ.អត្ថបទកំណាព្យ "មើលផែនដីខ្មែរ" របស់លោក ជួន ម៉េន (ឆ្លុះបញ្ចាំងបញ្ហាសង្គម នៅសម័យកម្ពុជាប្រជាធិបតេយ្យ)

សរុបសេចក្តី៖ សរុបសេចក្តីមកអក្សរសិល្ប៍ទាំងអស់សុទ្ធតែបានលើកយកបញ្ហារបស់សង្គម តាមសម័យកាលនីមួយៗមកបង្ហាញដល់អ្នកសិក្សា អ្នកអានទាំងឡាយឱ្យបានយល់ដឹង តថភាពពិតនៃសង្គមកាលនីមួយៗ។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មានអត្ថន័យល្អជ្រាលជ្រៅ ដោយបង្ហាញពីតម្លៃនៃអក្សរ សិល្ប៍ ក៏ដូចជារំឭកដល់អ្នកនិពន្ធទាំងឡាយឱ្យមានការគិតគូរច្បាស់លាស់ មុននឹង សម្រេចនិពន្ធអត្ថបទរបស់ខ្លួនសម្រាប់សាធារណជន។
- មតិផ្ទាល់ខ្លួន៖ ដូច្នេះហើយអក្សរសិល្ប៍ មានតួនាទីសំខាន់ណាស់សម្រាប់ឱ្យយើងសិក្សា...។

**ប្រធានទី២១៖** មានសុភាសិតមួយចែងថា«ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកញ្ជា

# គម្រោងតែង

## ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ចំណោលបញ្ហា៖ ភ្ជាប់ជាមួយប្រធាន
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

## ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ឈើត្រង់ ឈើវៀច កង់ ទូក
- ពន្យល់ន័យប្រធាន៖...ឈើដែលមានសណ្ឋានវៀចត្រូវយកមកធ្វើកង់...ព្រោះកោងស្រាប់...ឈើដែលមានសណ្ឋានត្រង់...ធ្វើទូក...បីដូចការប្រើមនុស្សទៅតាមអត្តចរិតឬសមត្ថភាព
- បកស្រាយប្រធាន៖

**-ន័យចំ៖** គេចង់បង្ហាញថា កង់មានរាងជារង្វង់ កោង មូលគេនិយម យកឈើវៀចទៅធ្វើ ចំណែកឯទូករទេះ វាមានសណ្ឋានត្រង់ ដូច្នេះ គេត្រូវយកឈើត្រង់ៗទៅធ្វើទូកបាន។

✓ **ពង្រីកន័យ**

- ប្រភេទឈើ និងសារប្រយោជន៍នៃឈើតាមប្រភេទនីមួយៗ
- បង្ហាញឱ្យគេយល់ថាហេតុអ្វីបានជាគេយក់ឈើវៀចទៅធ្វើកង់(មិនពិបាកតម្រង់) ហើយឈើត្រង់យកទៅធ្វើទូក(មិនពិបាកពត់)
- លក្ខណៈនៃឈើ៖ សរសៃ មានភាពរឹងមាំ ត្រង់មិនងាយពត់(ស្រួយ) ឈើមិនមែនដែកដែលអាចពត់ពេលត្រូវកម្តៅបាន
- ដូច្នេះកង់រទេះមានរាងមូលយើងគួរយកឈើវៀច...
- រីឯទូកវិញក៏ដូច្នោះ មានរាងត្រង់...

ឧទាហរណ៍៖ ដើមឈើ៖ នាងនួន បេង ត្នោត...ធ្វើជាជញ្ជាំង ក្តារផ្ទះ ...មៃក គល់ ធ្វើជាសម្ភារផ្សេងៗ...។

សរុបមក៖ សរុបន័យចំ

✓ **ន័យធៀប៖**

- ឈើ៖ ប្រៀបទៅមនុស្សក្នុងសង្គម។ កង់ ទូករទេះ គេប្រដូចនឹងសមត្ថភាពមនុស្ស ឬការងារមនុស្ស...។ សុភសិតនេះ ចង់បង្ហាញថាមនុស្សក្នុងសង្គម សុទ្ធតែមានសមត្ថភាពខុសគ្នាទេពកោសល្យពិសេសរៀងៗខ្លួន ដែលអាចប្រកបការងារផ្សេងៗបាន។ ...

## ពង្រីកន័យធៀប

- ➢ ប្រភេទមនុស្ស បុគ្គលិកលក្ខណ: សមត្ថភាព និងទេពកោសល្យ
- ➢ ប្រភេទមនុស្សឈើវៀច៖ មនុស្សមិនស្លូត មិនល្អ កោងកាច ...។ ប្រភេទមនុស្សបែបនេះមានសមត្ថភាពខាងមានកម្លាំងបាយ...ធ្វើជាទ័ព ការពារប្រទេសជាតិ...។
- ➢ ប្រភេទមនុស្សឈើត្រង់៖ ស្លូត សុភាព មានសីលធម៌ មានភាពថ្លៃថ្នូរ...ធ្វើការគ្រប់គ្រង...។

សរុបន័យធៀប៖

## ឧទាហរណ៍៖

- ➢ សង្គមអតីតកាល៖ ឧកញ៉ាសន្ធរវោហារម៉ុក
- ➢ **អក្សរសិល្ប៍៖**
    - ✓ រឿងអាខ្វាក់អាខ្វិន(មនុស្សពីរប្រភេទ)

- ✓ រឿងមាយើង(មនុស្សពុំសូវមានប្រាជ្ញា)
- ✓ រឿងកុលាបប៉ៃលិន(ចៅចិត្រ)

## សរុបសេចក្តី៖

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយយ៉ាងក្បោះក្បាយ..
- ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះ.......................................................
- សុភាសិត ឬពាក្យស្លោក.......................................................

**ប្រធានទី២២៖** មានមតិមួយពោលថា«អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំទេ»។ តើជាការត្រឹមត្រូវដែរឬទេ? ចូរពិភាក្សាដោយលើកអំណះអំណាងក្នុងរឿងមកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សជាច្រើនយល់ថាអក្សរសិល្ប៍មានតួនាទី
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ តើមតិខាងលើត្រឹមត្រូវដែរឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖
- ពន្យល់ពាក្យ៖
    - ✓ អក្សរសិល្ប៍ប្រជាប្រិយ៖ ជាអក្សរសិល្ប៍ទាំងឡាយណាដែលនិយាយតៗគ្នាពីកន្លែងមួយទៅកន្លែងមួយគ្មានអ្នកនិពន្ធ និងកាលកំណត់តែងច្បាស់លាស់។

- ✓ តម្លៃអប់រំ៖ ជាតម្លៃដែលប្រៀនប្រដៅ ទូន្មានយើងឱ្យប្រកាន់អាកប្បកិរិយាល្អ ត្រឹមត្រូវ ឬប្រការណាមួយតាមរយៈអត្ថបទ។

- ពន្យល់ន័យប្រធាន៖ អក្សរសិល្ប៍ទាំងឡាយណាដែលនិយាយតៗគ្នា គ្មានកាលបរិច្ឆេទ និងគ្មានអ្នកនិពន្ធច្បាស់លាស់ពុំមានបង្កប់នូវតម្លៃនៃការអប់រំនោះឡើយ។
- បកស្រាយស្រាយប្រធាន៖
  - ➤ មតិស្របះ «អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំទេ» ព្រោះ៖

    គំនិតគាំទ្រ៖

    - ✓ ជារឿងប្រឌិត(គ្មានមូលដ្ឋានច្បាស់លាស់)
    - ✓ ជាការប្រឌិតឡើងដែលបកស្រាយពី៖
      - ប្រវត្តិទឹកដី
      - ទំនៀមទម្លាប់ប្រពៃណី
      - បាតុភូតធម្មជាតិ
      - ការរិះគន់
      - ដើម្បីបង្កើតភាពសប្បាយរីករាយតែប៉ុណ្ណោះ
      - រឿងប្រឌិតឡើងដោយមិនផ្អែកលើការពិត

- ជាការបំផ្លើស
- .......................................................។

**ឧទាហរណ៍៖**

- ✓ រឿង ភ្នំនាងកង្រី៖ មនុស្សដួលស្លាប់ក្លាយជាភ្នំ។
- ✓ រឿង តឹង្កក់ និងតាព្រហ្ម៖ ដោយសារតែតួអង្គកន្លែងកើតហេតុ ឬាតុភូតធម្មជាតិ
- ✓ ធនញ្ជ័យ៖
- ✓ រឿង សម្លាញ់ពីរនាក់បានប្រព្វគ្រប់លក្ខណ៍និងខាតលក្ខណ៍

សរុបមតិស្រប៖

សំណួរភ្ជាប់ទៅមតិផ្ទុយ៖ តើអក្សរសិល្ប៍ប្រជាប្រិយពិតជាគ្មានតម្លៃអប់រំមែនទេ?

- ➢ មតិផ្ទុយ៖ «អក្សរសិល្ប៍ប្រជាប្រិយ មិនមែនគ្មានតម្លៃអប់រំទេ» ព្រោះ

  គំនិតគាំទ្រ៖

  - ✓ ស្គាល់ពីសាវតារបស់យើង
  - ✓ ស្គាល់ពីផ្នត់គំនិតរបស់ខ្មែរ

- ✓ ទទួលបានចំណេះដឹង
- ✓ ឱ្យចេះសាមគ្គី
- ✓ ដឹងពីរបៀបដោះស្រាយបញ្ហាសង្គម
- ✓ កតញ្ញូចំពោះអ្នកមានគុណ
- ✓ ......................................................។

ឧទាហរណ៍៖

- ✓ រឿង កង្រី(ជំនឿ កម្មពៀរ កតញ្ញូ...)
- ✓ អាខ្វាក់អាខ្វិន
- ✓ គីង្គក់(សាមគ្គីគ្នា)
- ✓ ..............................................................។។

សរុបន័យផ្ទុយ៖

- ➢ (ពិភាក្សា)៖រួមសេចក្តីមក យើងឃើញមានមតិពីរខ្វែងគំនិតគ្នា។ ដោយមតិទី១យល់ថា«អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំទេ»។ ចំណែកមតិទី២យល់ថា«អក្សរសិល្ប៍ប្រជាប្រិយមានតម្លៃអប់រំ»។ ការយល់ឃើញថាអក្សរសិល្ប៍ប្រាប្រជាប្រិយ គ្មានតម្លៃអប់រំនោះ មិនមែនជាការល្អ ឬត្រឹមត្រូវនោះទេ។ ព្រោះយើងឃើញថា រាល់ស្នាដៃអក្សរសិល្ប៍មានតួនាទីក្នុងការអប់រំដល់មនុស្សគ្រប់ស្រទាប់

វណ្ណៈ តាមរយៈសមត្ថភាពរបស់តួអង្គក្នុងសាច់រឿង ដើម្បីទុកជាប្រយោជន៍ឱ្យអ្នកសិក្សា ចេះពិចារណា និងអនុវត្តតាម។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មិនត្រឹមត្រូវ មិនសមហេតុផលទេ
- ទស្សនផ្ទាល់ខ្លួន៖ ដូចនេះ.......................................។

**ប្រធានទី២៣៖** មានទស្សនៈមួយពោលថា«អក្សរសិល្ប៍មិនត្រឹមតែបង្ហាញពីសកម្មភាពមនុស្សទេ តែក៏បង្កប់នូវការអប់រំផងដែរ»។ ចូរបង្ហាញដោយលើកឧទាហរណ៍អក្សរសិល្ប៍ប្រជាប្រិយអក្សរសិល្ប៍ទំនើប និងអក្សរសិល្ប៍បុរាណមកបញ្ជាក់ ។

## គម្រោងតែង

### ក. សេចក្ដីផ្ដើម

- ✓ លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធានបទ
- ✓ ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ✓ ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្ដី

- ✓ ឃ្លាភ្ជាប់សេចក្ដី៖
- ✓ ពន្យល់ពាក្យ៖ អក្សរសិល្ប៍ សកម្មភាព អប់រំ
- ✓ ពន្យល់ន័យប្រធាន៖
- ✓ បកស្រាយប្រធាន
    - គំនិតគាំទ្រ
        - ➢ និយមន័យអក្សរសិល្ប៍

- ឆ្លុះបញ្ចាំងពីសកម្មភាពមនុស្សទាក់ទងទៅលើ
  - ការគ្រប់គ្រង
  - ការគោរពប្រតិបត្តិ(ជំនឿ ប្រពៃណី ទំនៀមទម្លាប់ សាសនា ការអប់រំ...)
  - ការរស់នៅរបស់ប្រជាជនក្នុងសម័យកាលណាមួយ
  - ជីវភាពរបស់មនុស្ស
  - សកម្មភាពក្នុងការតស៊ូ
  - សកម្មភាពនៃការព្យាយាម
  - ............................................................

- អក្សរបានបង្កប់ការអប់រំបណ្តុះបណ្តាលដើម្បីប្រយោជន៍ដល់មនុស្សដែលរស់នៅក្នុងសង្គមដូចជា៖
  - ធ្វើឱ្យមនុស្សមានចំណេះដឹង
  - លត់ដំមនុស្ស ទទួលនូវបំណិនប្រសប់
  - អប់រំមនុស្សឱ្យចេះពិចារណាមុននឹងធ្វើអ្វីមួយ
  - អប់រំមនុស្សឱ្យមានទំនួលខុសត្រូវ

- អប់រំមនុស្សឱ្យចេះរៀបចំខ្លួនឱ្យបានល្អក្នុងការរស់នៅ
- ឱ្យចេះរស់នៅក្នុងសង្គម
- ចេះដោះស្រាយបញ្ហា
- បណ្តុះស្មារតីស្នេហាជាតិ
- បណ្តុះស្មារតីគ្រប់បែបយ៉ាងដើម្បីប្រយោជន៍រួម
- ........................................................

ឧទាហរណ៍៖

- ✓ រឿង ធនញ្ជ័យ
  - ដោយសារតែវណ្ណៈថ្នាក់លើចូលចិត្តជិះជាន់អ្នកស្លូតត្រង់(ធ្វើឱ្យធនញ្ជ័យតស៊ូរើបម្រះ...)
  - ដោះស្រាយបញ្ហាដោយប្រើប្រាជ្ញា
  - មានទំនួលខុសត្រូវចំពោះប្រទេសជាតិ

បង្ហាញពីការគ្រប់គ្រងសម័យនោះ...

- ➢ រឿង រាមកេរ្តិ៍
- ✓ អប់រំឱ្យមនុស្សចេះអធ្យាស្រ័យគ្នា
- ✓ ស្អប់ខ្ពើមសង្គ្រាម
- ✓ គោរពពាក្យសត្យ

- ✓ អប់រំមនុស្សឱ្យចេះចៀស(គ្រាន់តែទំនាស់បងប្អូនពឹងអ្នកក្រៅមកបំផ្លាញជាតិខ្លួនឯង)
- ✓ បង្ហាញពីយុទ្ធវិធីនៃការគ្រប់គ្រង

.......................................................។

រឿង ទុំទាវ

- ✓ ធ្វើឱ្យមនុស្សមើលឃើញពីឥទ្ធិពលស្នេហា(ដោយសារស្នេហាមនុស្សអាចបោះបង់អ្វីគ្រប់យ៉ាង)
- ✓ ការប្រឆាំងទាមទារសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ
- ✓ បង្ហាញឱ្យឃើញពីការគ្រប់គ្រងក្នុងសម័យនោះ

..............................................................។

សរុបសេចក្តី៖

៣. សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយ..................
- ✓ ទស្សនៈផ្ទាល់ខ្លួន៖ ក្នុងនាមយើងជា............................

**ប្រធានទី២៤៖** ក្រោយពីសិក្សារឿងធនញ្ជ័យចប់មានទស្សនៈមួយពោលថា«សាច់រឿងពោរពេញទៅដោយការអប់រំ»។ ចូរបកស្រាយតម្លៃអប់រំនៅក្នុងរឿងធនញ្ជ័យ ដោយភ្ជាប់អំណះអំណាងនៅក្នុងរឿងធនញ្ជ័យឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ ក្រោយពីសិក្សារឿងធនញ្ជ័យ...
- ចំណូលបញ្ហា៖ លើកប្រធានមកដាក់
- ចំណោទបញ្ហា៖ តើរឿងធនញ្ជ័យផ្តល់តម្លៃអប់រំដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖
- ពន្យល់ពាក្យ៖ តម្លៃ អប់រំ
- ពន្យល់ន័យប្រធាន៖ រឿងធនញ្ជ័យ...មានសារប្រយោជន៍...ណែនាំដល់អ្នកសិក្សា...
- បកស្រាយប្រធាន៖

- ✓ អប់រំឱ្យចេះដោះស្រាយបញ្ហាប្រកបដោយភាពឈ្លាសវៃ
- ✓ បណ្តុះឱ្យមានសេចក្តីស្នេហាជាតិ
- ✓ ចេះតស៊ូចំពោះឧបសគ្គ
- ✓ មានទំនួលខុសត្រូវចំពោះការងារដែលយើងធ្វើ
- ✓ កុំកុហក
- ✓ ចេះគោរពប្រពៃណី
- ✓ សាមគ្គីគ្នា
- ✓ ..........................................។

ឧទាហរណ៍៖ តួយ៉ាងធនញ្ជ័យដោះស្រាយបញ្ហាប្រកបដោយភាពឈ្លាសវៃ....

- ធនញ្ជ័យជាបុគ្គលមួយរូបដែលភក្តីចំពោះប្រទេសជាតិ...
- ពេលមានឧសបសគ្គធនញ្ជ័យមិនដែលរួញរា .............
- ធណញ្ជ័យមិនដែលធ្វើឱ្យនរណាម្នាក់ខកចិត្តនោះទេ................
- បើមានការកុហក នោះនឹងធ្វើឱ្យមានការខឹង គុំគួន.......................

*សរុបសេចក្តីមកៈយើងឃើញថា ..............................................................ពិតប្រាកដមែន។*

## គ. សេចក្តីបញ្ចប់

- *វាយតម្លៃប្រធានៈ .....................................ជាបទពិសោធអប់រំ អត្ថន័យ..................។*
- *ទស្សនៈ .........................................................ខ្លួនឯង និងសង្គមជាតិ។*

ប្រធានទី២៥៖ អ្នកវិភាគអក្សរសិល្ប៍បានពោលថា៖ "រាល់ស្នាដៃអក្សរសិល្ប៍ខ្មែរគឺតែងឆ្លុះបញ្ចាំងឱ្យឃើញពីជំនឿ ទំនៀមទម្លាប់ ប្រពៃណីក្នុងសង្គមមួយ " ។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍ឱ្យបានបីជាអក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប អក្សរសិល្ប៍ប្រជាប្រិយមកបញ្ជាក់មកបញ្ជាក់។

## គម្រោងតែង

### ក.សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ ចោទសួរបែបសំណួរ

### ខ.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យគន្លឹះ៖

-អក្សរសិល្ប៍៖ជាកម្រងអត្ថបទដែលបានប្រមូលចងក្រងនូវរឿងរ៉ាវប្រកបដោយសិល្បវិធីដែលកើតមានឡើងនៅក្នុងសង្គម

-ជំនឿ៖ការតាំងចិត្តស៊ប់ដោយយល់ថាពិត ការទុកចិត្តទៅលើអ្វីមួយ ឬបុគ្គលណាមួយ...

-ទំនៀមទម្លាប់៖អ្វីដែលធ្លាប់ធ្វើតៗគ្នាតាមគ្នា អាចជាទម្លាប់ល្អ និង អាក្រក់...។

-ប្រពៃណី ៖ជាកិរិយាប្រពៃ ដែលល្អ ដែលនាំឱ្យចម្រុងចម្រើន មិនប្រាសចាកវិចារណញ្ញាណ មិនប្រាសចាកពីជំនឿ និងកម្មផល ហើយជាកិរិយាដែលគេទាំងឡាយចាត់ទុកថាជាការគួរសមបំផុត។

- ***ពន្យល់***ន័យប្រធាន៖គ្រប់ស្នាដៃរឿងដែលអ្នកនិពន្ធលោកចងក្រងឡើងគឺសុទ្ធតែបានលាតត្រដាងឱ្យ ដឹងពីការជឿ ការធ្វើតាមគ្នា មានទាំងល្អ ទាំងអាក្រក់...។

បំណកស្រាយប្រធាន

១.គំនិតគាំទ្រ ៖ជាការពិតណាស់យើងឃើញថាអក្សរសិល្ប៍សុទ្ធតែបង្ហាញពីតថភាពក្នុងសង្គមនាសម័យកាលណាមួយ...

***អក្សរសិល្ប៍មានតួនាទី៖***

▪អប់រំដល់អ្នកសិក្សា... ▪ផ្តល់ពុទ្ធិ បទពិសោធ..

▪ផ្តល់នូវការកម្សាន្ត ...

▪ផ្តិតយកជីវភាពរស់នៅ សេដ្ឋកិច្ច វប្បធម៌...ឆ្លុះបញ្ចាំងឱ្យឃើញពីតថភាពសង្គម ពិសេសជំនឿ ទំនៀមទម្លាប់ប្រពៃណីខ្មែរ...ហើយ

- ជំនឿ ទំនៀមទម្លាប់ ប្រពៃណីទាំងនោះដក់ជាប់ក្នុងអារម្មណ៍របស់មនុស្ស មិនថាពីមុន ឬឥឡូវទេ។ ម៉្យាងទៀតធ្វើឱ្យពួកគេយកមក អនុវត្ត គ្រប់ភារកិច្ច មិនថា

តូចឬធំ ដែលយើងអាចនិយាយបានថា ធ្វើទៅជាទម្លាប់ទៅហើយ ដូចជា៖

**ជំនឿលើអរូបិយមាន៖**

- ជំនឿលើអ្នកតា( អ្នកតាភូមិ ឃុំ ស្រុក )
- ជំនឿលើព្រលឹងឪពុកម្តាយ ជំនឿលើវត្ថុស័ក្តិសិទ្ធិ ជំនឿលើមន្តអាគម ជឿលើសត្វ កុក ខ្លែង...
- ជំនឿលើមេបា(មេបាចាស់ទុំ មេបាកំលោះក្រមុំមេបាផ្តាប់មុខ)ជឿលើគ្រូ(គ្រូអាចារ្យ គ្រូឧបជ្ឈាយ៍ គ្រូបាធ្យាយ)
- ជំនឿដាក់លើកម្លាំង(កាយចិត្ត)

**ទំនៀមទម្លាប់ខ្មែរមានច្រើន**

- ពេលកើត(មុនកើត កើត ក្រោយពេលកើត)
- ពេលរៀបការ (មុនពេលការ(ពិធីចែចូវ ស្តីដណ្តឹង ស៊ីស្លាភ្ជាប់ពាក្យ, ពេលរៀបការ,ក្រោយពេលរៀបការ
- ពេលឈឺ ពេលស្លាប់ បំបួសនាគ...
- ប្រពៃណីមានគារវកិច្ច(សំពះ) ប្រពៃណីស្លៀកពាក់(សម្លៀកបំពាក់ខ្មែរ) ប្រពៃណីធ្វើបុណ្យ ពិធីរៀបការ...

**ឧទាហរណ៍ក្នុងអក្សរសិល្ប៍**

- អក្សរសិល្ប៍ប្រជាប្រិយ៖ រឿងភ្នំនាងកង្រី
- ជំនឿ៖សេដ្ឋី និងប្រពន្ធយកចេកទៅបន់អ្នកតាសុំកូនមន្តអាគម នាងសន្ធមារដាក់ស្នេហ៍បិតាពុទ្ធិសែន...

- ជំនឿវត្ថុស័ក្តិសិទ្ធិ៖នាងសន្ធមារជឿថាកែវភ្នែកនាងទាំង ១២អាចឱ្យនាងមានអាយុអមត:
- ជំនឿលើព្រលឹងខ្មោច
- ជំនឿលើកម្មផលៈបាបកម្មនាងទាំង១២ត្រូវគេខ្វេះភ្នែក ដោយសារជាតិមុនពួកនាងៗនាំគ្នាចាក់ភ្នែកត្រី)
- ទំនៀមទម្លាប់៖កូនស្រីត្រូវថែរក្សាទ្រព្យសម្បត្តិក្នុងផ្ទះ ដូច នាងកង្រីត្រូវថែរក្សាថ្នាំ គ្រាប់ភ្នែក...
- ប្រពៃណី ពុទ្ធិសែនរៀបការជាមួយនាងកង្រីមុននឹងក្លាយ ជាប្តីប្រពន្ធត្រូវឆ្លងកាត់រៀបការ...

**រឿងរាមកេរ្តិ៍** ៖ ➔ជំនឿលើសត្វកុក ជាសត្វចង្រៃ

- ទំនៀមទម្លាប់ ៖ការចូលកោដ្ឋបញ្ឆោតនាងសីតា(មាន ពិធីបូជាសពព្រះរាម.។ការជ្រើសរើសគូស្រករជាភារកិច្ច ឪពុកម្តាយ។
- ការប្រកាន់ពាក្យសច្ចៈ
- ប្រពៃណី ៖ការរៀបការកូនប្រុសត្រូវទៅរៀបការនៅផ្ទះ ខាងស្រី ព្រះរាមយាងទៅរៀបអភិសេកនៅនគរមិថិលា...
- ពិធីច្រត់ព្រះនង្គ័ល ព្រះបាទជនកទ្រង់ធ្វើពីធីច្រត់ព្រះ នង្គ័លដើម្បី...។

**រឿងទុំទាវ**

- ជំនឿ ៖ជឿលើការទស្សន៍ទាយ

- ទស្សនកម្មផលៈ ពេលទំពិបាកចិត្តពេលលួចសឹកបាន ពោលថា"មិនស្លាយផ្អូសប្រាណបានប៉ុនសក់ កម្មនាំកញ្ឆាក់ឱ្យងងឹត..."
- ជឿលើមន្តគាថាគម្ពីរអថវិវេទ(ដាក់ស្នេហ៍)
- ទំនៀមទម្លាប់ប្រពៃណីៈពិធីចូលម្លប់(ទំនៀមទម្លាប់ខ្មែរ),បួសរៀន,ពិធីចូលស្តីដណ្តឹង,ពិធីរៀបការ
- (សម្គាល់ៈសិស្សអាចរករឿងផ្សេងពីអត្រាកំណែបានឱ្យតែស្របតាមគម្រោង)

សរុបសេចក្តី

គ.សេចក្តីបញ្ចប់

- វាយតម្លៃប្រធានៈ ឆ្លងតាមការបកស្រាយ...................
- ទស្សនៈផ្ទាល់ខ្លួនៈ ដូចនេះ.........................................។

**ប្រធានទី២៦៖** សុភាសិតមួយចែងថា«ម្រឹគមិនដែលបោលចូលមាត់សីហៈដែលដេកលក់ទេ»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖ ភ្ជាប់ប្រធាន
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ពន្យល់ន័យពាក្យគន្លឹះ
    - ម្រឹគ ៖ចតុប្បាទព្រៃមានដូចជាឈ្លូស រមាំង គោព្រៃសជាដើម។
    - សីហៈជាសត្វចតុប្បាទមួយពួកមានឫទ្ធិអំណាចអង់អាចក្នុងព្រៃ ស៊ីសាច់ឆៅជាអាហារ។
    - បោល ៖ រត់ចូលពេញទំហឹង។
- ពន្យល់ន័យឃ្លា៖ សត្វសីហៈ ទោះបីជាសត្វដែលមានអំណាចអង់អាចក៏ដោយ តែបើវារវល់តែដេកលក់មិនខ្វល់

គិតដើររកចាប់ចំណីមកស៊ីទេ អត់មានពួកសត្វម្រឹគណារត់ចូលមាត់ឱ្យឆីដោយឯងៗទេ។

– បំណកស្រាយន័យចំ៖
  - **ន័យចំ៖** ឱ្យអត្ថន័យន័យចំ
  - ពង្រីកគំនិតន័យចំ៖
    - ✓ ប្រភេទសត្វនៅក្នុងព្រៃ និងការរកស៊ីចិញ្ចឹមជីវិត
    - ✓ ពន្យល់ន័យបន្ថែមទៅលើពាក្យ ម្រឹគ និង សីហៈ និងទំនាក់ទំនងក្នុងការរស់នៅរបស់វា
    - ✓ ពន្យល់ពីសកម្មភាពសីហៈដេកគ្មានសកម្មភាព និងម្រឹគ...ចៀសពីសត្វធំៗ

– បំណកស្រាយន័យធៀប៖
  - **ន័យធៀប៖** ម្រឹគប្រៀបដូចជាចំណេះ លាភសំណាងផ្សេងៗដែលមនុស្សតែងប្រាថ្នាចង់បាននៅក្នុងជីវិត រីឯសីហៈប្រៀបប្រដូចនឹងមនុស្សគ្រប់ៗរូបក្នុងសង្គម គ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈ។ ចំណែកដេកលក់វិញចង់បង្ហាញពីភាពអសកម្មរបស់មនុស្សម្នាក់ៗ។ ដូចនេះ ឃ្លានេះចង់បង្ហាញថា បើមនុស្សទាំងអស់មិនចេញស្វះស្វែងរកលាភសំណាងទាំងនោះដោយខ្លួន

ឯងទេ គ្មានលាភសំណាងណាហោះមកដោយឯងៗ ឡើយ។

- ពង្រីកគំនិតន័យធៀបៈ
  - ✓ លាភសំណាងសំដៅលើ ចំណេះដឹង ទ្រព្យសម្បត្តិ រូបសម្ផស្ស យសសក្ដិ កិត្តិយស អំណាច កេរ្ដិ៍ឈ្មោះ.....
  - ✓ វិធីដើម្បីទទួលបានលាភសំណាងនោះគឺ
    - – សេចក្ដីព្យាយាម តស៊ូពុះពារដែលផុសចេញពីស្មារតី
    - – ការជឿកជាក់លើខ្លួនឯង
    - – ការមិនផ្ដេកផ្ដួលលើអ្នកដទៃ
    - – ភាពឧស្សាហ៍ព្យាយាម
    - – ការមិនផ្ដេកផ្ដួលលើព្រេងវាសនា
  - ✓ លទ្ធផលនៃភាពស្វះស្វែង( នៅក្នុងការសិក្សា ការងារ និងក្នុងជីវិត)
- **ឧទាហរណ៍៖**
  - ✓ នៅក្នុងសង្គម៖ ទស្សនៈព្រះពុទ្ធ "អត្តាហិ អត្តនោ នាថោ"

✓ នៅក្នុងប្រវត្តិសាស្ត្រ៖ សម័យអង្គររុងរឿង ដោយសារ អ្នកដឹកនាំ និងប្រជាជនគ្រប់ជាន់ថ្នាក់ស្វះស្វែងធ្វើការយ៉ាងស្រុះគ្នា

✓ ក្នុងអក្សរសិល្ប៍៖

❖ រឿងធនញ្ជ័យ៖យសសក្តិរបស់ធនញ្ជ័យ មិនកើតឡើងពីការជឿលើហោរាឡើយ

❖ រឿងកុលាបប៉ៃលិន៖ ភាពជោគជ័យចៅចិត្រផ្តើមឡើងពីការព្យាយាមស្វះស្វែងរកដោយខ្លួនឯង...។

❖ រឿងមាលាដួងចិត្ត ៖ ការខិតខំប្រឹងប្រែងឥតឈប់ឈរ និងមិនខ្លាចនឿយហត់របស់ទីឃាវុធ...។

– សរុបសេចក្តី (ន័យចំ + ន័យធៀប)

## គ. បញ្ចប់សេចក្តី

– វង្វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយ.......................

– មតិស្នេរ៖ ដូចនេះ..............................................................

ប្រធាន**២៧**៖ មានទស្សនៈថា៖ "ស្ត្រីជាកម្លាំងចលករក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិ"។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖ភ្ជាប់ជាមួយប្រធាន
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យគន្លឹះ
  - ✓ កម្លាំង៖ សំដៅទៅលើថាមពល កត្តាលីករ អំណាច ដែលជួយជំរុញអ្វីមួយឱ្យមានចលនា
  - ✓ ចលករ៖ អ្នកជំរុញ...
  - ✓ អភិវឌ្ឍ៖ ការធ្វើសកម្មភាពអ្វីមួយឱ្យមានការរីកចម្រើនលូតលាស់ទៅមុខ...។

- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើនេះចង់បង្ហាញថា៖ស្ត្រីគឺជាអ្នកមានអំណាច ឥទ្ធិលពល ឬជាអ្នកជំរុញដ៏សំខាន់ ដែលរួមចំណែកក្នុងការដឹកនាំអ្នកដែលមិនដឹងគោលដៅ ឱ្យបានសម្រេចគោលដៅ ហើយជាអ្នកធ្វើឱ្យគ្រួសារ និងសង្គមមានការរីកចម្រើនលូតលាស់ទៅមុខឥតឈប់ឈរ
- បកស្រាយប្រធាន៖
  - ❖ គំនិតគាំទ្រ
  - ❖ លក្ខណ:ស្ត្រី

-ស្ត្រីជាផ្នែកមួយនៃសុភមង្គល

-ស្ត្រីមានភាពលះបង់ខ្ពស់ ចិត្តដាច់

-ស្ត្រីមានភាពទន់ខ្សោយខាងកម្លាំងកាយតែមិនចាញ់ខាងប្រាជ្ញា

-ស្ត្រីជាថាមពលដ៏សំខាន់

-ស្ត្រីមានទេពកោសល្យ ល្បិច

-មានចិត្តត្រជាក់ ក្លាហាន មោះមុត

-ស្ត្រីមានភាពវៃឆ្លាតក្នុងការរៀបចំឱ្យមានសណ្តាប់ធ្នាប់..

ស្ត្រីដើរតួនាទីសំខាន់មិនថាការងារក្នុងផ្ទះ ក្រៅផ្ទះ តូចធំនោះទេគេអាចរ៉ាប់រងបានយ៉ាងល្អដូចជា៖

✓ ក្នុងគ្រួសារ

- ជាអ្នកគ្រប់គ្រងផ្ទះសំបែង
- ជាភរិយាចាំជួយដាស់តឿន ចង្អុលបង្ហាញផ្លូវដល់ស្វាមី
- ស្ត្រីជាអ្នកទុកដាក់ទ្រព្យសម្បត្តិដែលប្តីរកបាន
- ជាមាតាដ៏ល្អនៃកូនៗ
- ជាអ្នកជំរុញឱ្យគ្រួសារមានមុខ មានមាត់ក្នុងសង្គម.......... មានសុភមង្គល

**ឧទាហរណ៍៖** លោកជំទាវម៉ែន ស៊ុន ម៉ុងឫទ្ធីជាមេផ្ទះល្អ ជាមាតាដ៏កក់ក្តៅក្នុងគ្រួសារ។ លោកជំទាវតែងតែជាកម្លាំងចិត្តដល់ស្វាមី..................................រហូតស្វាមីមានមុខមានមាត់ក្នុងសង្គម។

- ក្នុងសង្គមជាតិ
  - នារីធ្វើការងារធំមិនចាញ់បុរសទេ
  - នារីជួយដោះស្រាយបញ្ហាលំបាកធំៗ(បើជាតិមានបញ្ហាខ្លាំងស្ត្រីដើរតួជាចារនារី)...
  - នារីប្រឡូកការងារក្នុងសង្គមដូចជា៖ គ្រូពេទ្យ(ពេទ្យឆ្មបជួយសម្រាលស្ត្រីដូចគ្នា) គ្រូបង្រៀន(ទន់ភ្លន់) អ្នកគ្រប់គ្រងក្រុមហ៊ុន...
  - ក្នុងនយោបាយ៖ជាអ្នកដឹកនាំជួរដ្ឋាភិបាល ជាថ្នាក់ដឹកនាំពីថ្នាក់ក្រោម ដល់ថ្នាក់កំពូល(ធ្វើការរហ័ស ឆាប់យល់ ទទួលបានផលល្អ)...

***ឧទាហរណ៍ក្នុងសង្គម៖*** *លោកជំទាវ ភឿង សកុណា មានងារជារដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ លោកជំទាវឈ្លុសឈ្លុលយ៉ាងសកម្មក្នុងការដាក់គោលនយោបាយជំរុញ និងលើកកម្ពស់សិល្បៈភាពយន្តខ្មែរឱ្យមានការអភិវឌ្ឍ និងរីកចម្រើន។ លោកជំទាវថែមទាំងដាក់សម្បត្តិវប្បធម៌មួយចំនួនចូលជាបេតិកភណ្ឌពិភពលោក...ចំណុចនេះហើយដែលបង្ហាញឱ្យឃើញថាលោកជំទាវចូលរួមអភិវឌ្ឍសង្គមមួយឱ្យលេចធ្លោលើឆាកអន្តរជាតិ*

*ឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រ៖ ព្រះនាងឥន្ទ្រទេវី*

*ឧទាហរណ៍ក្នុងអក្សរសិល្ប៍៖*

- ✓ *រឿងមាយើង(ស្ត្រីប្រពន្ធក្រោយមាណពចេះរៀបចំទុកដាក់ជួយជំរុញស្វាមីរហូតថៅមាណពក្លាយជាអ្នកមានទ្រព្យសម្បត្តិច្រើន និងមានតួនាទីប្រាកដមួយនៅក្នុងរាជវាំង...*
- ✓ *រឿងភូមិតិរច្ឆាន(សកម្មភាពនាង នី និងនាងប៊ី មានសេចក្តីក្លាហានក្នុងការប្រកែកតវ៉ាជាមួយពួកណានិគម...)*
- ✓ *រឿងតេជោយ៉ត(ជំទាវស្រែនជួយការងារស្វាមី ការងារប្រទេសជាតិជួយកម្ចាត់សត្រូវ ជនក្បត់ជាតិបានសម្រេច...)*

*សរុបសេចក្តី៖*

*គ. សេចក្តីបញ្ចប់*

- *វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយ................*
- *ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះ........................................*

ប្រធានទី២៨៖ អ្នកសិក្សាអក្សរសិល្ប៍បានពោលថា «អក្សរសិល្ប៍សុទ្ធតែបង្ហាញឱ្យឃើញពីផ្នត់គំនិតខ្មែរ»។ ចូរបង្ហាញ។

# គម្រោងតែង

## ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន
- ចំណូលបញ្ហា៖ លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

## ខ. តួសេចក្ដី

- ឃ្លាសេចក្ដី
- ពន្យល់ពាក្យ៖
  - អក្សរសិល្ប៍គឺជាកម្រងអត្ថបទដែលបានប្រមូលចងក្រងនូវរឿងរ៉ាវប្រកបដោយសិល្បវិធីដែលកើតមានឡើងនៅក្នុងសង្គម។
  - ឆ្លុះបញ្ចាំងមានន័យថាការធ្វើឱ្យឃើញអ្វីៗ ឬបង្ហាញពីអ្វីមួយ...

– ផ្នត់គំនិត គឺជាការយល់ឃើញរបស់មនុស្ស ឬជាតិសាន៍ណាមួយដែលជាប់ក្នុងសន្តានចិត្តរបស់ពួកគេមិនងាយនឹងដកចេញ ហើយប្រកាន់យកតាំងពីយូរលង់ណាស់មកហើយ...។

- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើគឺចង់បង្ហាញឱ្យឃើញថា កម្រងរឿងទាំងឡាយគឺសុទ្ធតែបានបង្ហាញលាតត្រដាងអំពី ការយល់ឃើញ ....................................ជាគំនិតដក់ជាប់ក្នុងអារម្មណ៍របស់ប្រជាជនដែលគេតែងតែជឿជាក់ និងអនុវត្តតាំងពីយូរលង់ណាស់មកហើយ។
- បកស្រាយប្រធាន៖"ជាការពិតណាស់អក្សរសិល្ប៍សុទ្ធតែបង្ហាញឱ្យឃើញពីផ្នត់គំនិតខ្មែរ"

គំនិតគាំទ្រ

- ✓ ផ្នត់គំនិតគឺជាគំនិត ជាការយល់ឃើញដែលជិតដាមនៅក្នុងអារម្មណ៍ គំនិតរបស់មនុស្សម្នាក់ៗទៅតាមការកំណត់របស់សង្គម និងវប្បធម៌។
- ✓ ហើយផ្នត់គំនិតកើតឡើង និងអនុវត្តតាម
- ✓ ទំនៀមទម្លាប់ ប្រពៃណី សាសនា
- ✓ ស្ថិតក្នុងជំនឿ

- ✓ ការរស់នៅរបស់មនុស្សតាមទម្លាប់
- ✓ គោលគំនិតដែលមិនទាន់វិនិច្ឆ័យ(បុរេនិច្ឆ័យ)
- ✓ ទស្សនៈ
- ✓ ទឹកចិត្ត( សាមគ្គី ភក្តីភាព ស្លូតចិត្ត ភ័យខ្លាច...)
- ✓ ភាសា អក្សរ ...

ផ្នត់គំនិតក្នុងអក្សរសិល្ប៍បង្ហាញតាមរយៈ

- ✓ ក្នុងការដឹកនាំ
- ✓ ផ្នត់គំនិតក្នុងការងារ
- ✓ ផ្នត់គំនិតក្នុងគ្រួសារ
- ✓ ផ្នត់គំនិតរស់នៅ

បកស្រាយក្នុងអក្សរសិល្ប៍ប្រជាប្រិយ

- ✓ រឿងបុរសបួននាក់រៀនសិល្ប៍សាស្ត្រ
  - មានជំនឿលើការទស្សន៍ទាយ( បុរសទាំងបួននាក់ក្រោយពីមករៀនវិជ្ជាពីគ្រូអាចារ្យទិសាបោមោក្ខក៏សុំលាលោកគ្រូ ..................មកដល់កណ្តាលផ្លូវឈប់សម្រាកបុរសចេះទាយក៏គន់គូរមើលហេតុភេទ...)
  - កូនប្រុសត្រូវស្វែងរកចំណេះវិជ្ជា( ដោយសង្គមខ្មែរគ្រប់ម្តាយឪពុកតែងបញ្ជូនកូនទៅរៀន...)

- ផ្តត់គំនិតមិនឱ្យមនុស្ស ប្រុសស្រីប៉ះពាល់គ្នាមុនពេលរៀបការ បើប៉ះគឺត្រូវជាគូគ្រងរៀបការជាមួយ( នារីម្នាក់នោះរៀបការជាមួយបុរសដែលបានប៉ះនាងមុនគេ...)
- ការរៀបការកូនស្រីត្រូវម្តាយឪពុករៀបចំទុកដាក់ឱ្យ...
- ការកាត់ក្តី( មានរឿងរ៉ាវ មានហេតុ ផល យុត្តិធម៌)...

បកស្រាយក្នុងអក្សរសិល្ប៍បុរាណ

✓ រឿងរាមកេរ្តិ៍

- ព្រះរាជពិធីច្រត់ព្រះនង្គ័ល គឺជាទំនៀមទម្លាប់ដែលប្រព្រឹត្តធ្វើពីមុនរហូតដល់សព្វថ្ងៃ..
- ជ្រើសរើសកូនស្រី និយមគិតលើសមត្ថភាព...
- ការគោរពពាក្យសច្ចៈ( គោរពសម្តីមិនអាចលេបបានទេ...)
- ការរៀបមង្គលការនៅផ្ទះខាងស្រី
- ជឿលើវត្ថុក្រៅខ្លួន( អទិទេព...)
- ជំនឿលើសត្វកុកជាសត្វចង្រៃ
- ខ្មែរនិយមទុកអដ្ឋិធាតុក្នុងកោដ្ឋ
- ការបញ្ចូលផ្នត់គំនិតជាតិនិយមក្នុងស្នាដៃ( រឿងរាមកេរ្តិ៍ខ្មែរមានប្រភពពីរឿងរាមាយណៈឥណ្ឌា តែអ្នកនិពន្ធបានបញ្ចូលលក្ខណៈមនុស្សនិយម ពិតប្រាកដ..)

..............................................................................

បស្រាយក្នុងអក្សរសិល្ប៍ទំនើប

✓ រឿងទុំទាវ

- ទស្សនៈ "នំមិនធំជាងនាលិ" ក្នុងការរស់នៅ...ម្តាយទាវជាអ្នកសម្រេចលើវាសនាកូន
- មិនទុំមុនស្រគាលៈ ខ្មែរប្រកាន់ណាស់បើមានកើតឡើងលើគ្រួសារណាមួយ គ្រួសារនោះនឹងជួបភាពអាម៉ាស់...
- ភក្តីភាព៖ ប្រពន្ធត្រូវស្មោះត្រង់នឹងប្តី...
- ជំនឿ៖ ខ្មែរយើងគឺតែងតែទស្សន៍ទាយមុននឹងធ្វើនឹងធ្វើអ្វីមួយ...
- ការរស់នៅមិនថាក្នុងសង្គម ឬក្នុងគ្រួសារទេបើមានការហាមឃាត់ខ្មែរយើងតែងតែរើបម្រាស់ទាមទារសិទ្ធិសេរីភាព...
- ហើយមានការទាមទារសិទ្ធិខ្មែរយើងក៏នៅតែមានគំនិតមួយគឺ "ពងមាន់កុំជល់នឹងថ្ម"
- ការរៀបមង្គលការគឺមានពិធីចៃចូវ ស្តីដណ្តឹង...
- ការគ្រប់គ្រង(អ្នកក្រោមអំណាចស្តាប់អ្នកធំ)៖ ដូចអរជូន គោរពតាមបទញ្ជាស្តេច ទាវត្រូវស្តាប់ម្តាយ

**សិស្សអាចរករឿងផ្សេងបាន...**

*សរុបសេចក្តី*

## គ. សេចក្តីបញ្ចប់

– *វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយ....*

– *ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះ............................*

**ប្រធានទី២៩៖** អ្នកជំនាញខាងអក្សរសិល្ប៍បានកំណត់ថា«ការសិក្សាអក្សរសិល្ប៍គឺជាការសិក្សាពីបញ្ហាមនុស្ស ដើម្បីមនុស្ស។ ចូរបង្ហាញ។

## គម្រោងតែង

### ក.ផ្តើមសេចក្តី

- លំនាំបញ្ហា៖សិស្សត្រូវសរសេរចំណុចនេះ។
- ចំណូលបញ្ហា៖......«..............» ។
- ចំណោទបញ្ហា៖សិស្សត្រូវចោទសួរបែបពន្យល់។

### ខ.តួសេចក្តី

- ឃ្លាភ្ជាប់៖......................................
- ពន្យល់ពាក្យ៖សិស្សត្រូវពន្យល់ពាក្យគន្លឹះ៖ អក្សរសិល្ប៍ និងបញ្ហា
- ន័យប្រធាន៖សិស្សត្រូវសរសេរប្រាប់ពីន័យប្រធាន៖
- បំណកស្រាយ
- គោលគំនិតគាំទ្រប្រធាន៖សិស្សត្រូវសរសេរ គំនិតគោលៗមានអ្វីខ្លះ?

  ចំណុចទាំងនោះមាន៖

  សិក្សាពីមនុស្ស៖

- *សិក្សាពីការរស់នៅរបស់មនុស្សក្នុងសម័យណាមួយ*
- *សិក្សាពីស្ថានភាពសង្គម*
- *សិក្សាពីវប្បធម៌*
- *សិក្សាពីសកម្មភាពការតស៊ូ ការព្យាយាម...*

**ដើម្បីមនុស្ស**

- ✓ *ផ្តល់ចំណេះដឹងដល់មនុស្ស*

ជំនាញ ការរស់នៅ ទំនាក់ទំនង

- ✓ ដើម្បីកែខៃមនុស្សឱ្យមានចំណេះដឹង
- ✓ ដើម្បីកែខៃចំណុចអាក្រក់ បន្តចំណុចល្អ
- ✓ ដើម្បីដឹងពីរបៀបរស់នៅរបស់មនុស្សពីសម័យកាលមួយទៅសម័យកាលមួយ
- ✓ ដើម្បី..............................

ឧទា.បញ្ជាក់ ឬភ័ស្តុតាង ៖ *សិស្សត្រូវទាញឧទាហរណ៍គោលៗ មានអ្វីខ្លះ ។*

- ✓ រឿង ទុំទាវ
- ✓ នាងហ៊ានមានស្នេហាទាំងខ្លួននៅចូលម្លប់(មើលឃើញថាសេចក្តីស្នេហាអាចឱ្យមនុស្សហ៊ានលះបង់កិត្តិយស ទ្រព្យ ប្រពៃណី...)
- ✓ នាងទាវប្រឆាំងទាមទារសិទ្ធិក្នុងការជ្រើសរើសគូស្រករ(ទាមទារសិទ្ធិ

- ✓ ការគ្រប់គ្រងប្រទេស ផ្តាច់ការ...

រឿងរាមកេរ្តិ៍

- ✓ អប់រំឱ្យគោរពតាមប្រពៃណីក្សត្រ(បុត្រច្បងឡើងគ្រងរាជ្យ)
- ✓ ឱ្យចេះយោគយល់គ្នា៖ ព្រះបាទទសរថឈឺព្រះទ័យ... ប្រសិនបើមានការយោគយល់គ្នា ព្រះបាទទសរថមិនសុគតទេ...
- ✓ អប់រំបញ្ចៀសសង្គ្រាម៖ តួយ៉ាងព្រះភិរុត ពលិកម្មយ៉ាងឧត្តុង្គឧត្តមបំផុតសម្រាប់គ្រួសារ និងសង្គមជាតិ
- ✓ ការគោរពពាក្យសត្យ៖ ព្រះរាមមិនវិលចូលនគរទេទាល់តែគ្រប់ដប់បួនឆ្នាំ
- ✓ ដើម្បីឱ្យមនុស្សស្គាល់បំណងអាក្រក់របស់មនុស្សអាក្រក់នឹងតាមឈ្នានីស៖ នាងសូរបនខា ក្រុងរាពណ៍
- ✓ ស្គាល់ពីកំហុសនៃទំនាស់បងប្អូន៖ ទំនាស់រវាង ពាលី និង សុគ្រីព ក្រុងរាពណ៍ និងពិភេក បង្កគ្រោះថ្នាក់ដល់ប្រទេសជាតិ...
- ✓ ព្រះរាមប្រើល្បិចដាក់មហាជម្ពូយល់ព្រមជួយ
- ✓ ស្គាល់ពីយុទ្ធសាស្ត្រនៃការគ្រប់គ្រង៖ ការផ្តល់រង្វាន់ ការលើកទឹកចិត្តរបស់ព្រះរាម...
- ✓ បង្ហាញពីជីវិតប្តីប្រពន្ធឈ្លោះ ខឹងគ្នាដោយសារតែភាពប្រចណ្ឌ មិនទុកចិត្តគ្នា...

- ✓ ...............................................។

ក្នុងរឿង មាយើង

*សរុបសេចក្តី៖សិស្សត្រូវសរសេរប្រាប់នូវ ចំណុចនេះ។*

គ.បញ្ចប់សេចក្តី

- *តម្លៃប្រធាន៖សិស្សត្រូវសរសេរបញ្ចូល។*
- *ទស្សនៈស្មេរ៖សិស្សត្រូវសរសេរបញ្ចូល។*

**ប្រធានទី៣០៖**ក្រោយពីបានសិក្សារឿងទុំទាវរួចមក ក្នុងសាច់រឿង ឆ្លុះបញ្ចាំងលក្ខណៈជាតិ»។ ចូរបង្ហាញ។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងនឹងប្រធានបទ
- ចំណូលបញ្ហា៖ ភ្ជាប់ប្រធាន
- ចំណោទបញ្ហា៖ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ លក្ខណៈ , ជាតិ
- ពន្យល់ន័យប្រធាន៖
- បំណកស្រាយប្រធាន
- លក្ខណៈជាតិ៖គំនិតគាំទ្រ
    - ជាតិ ជាសហគមន៍នៃមនុស្ស ដែលមានសញ្ជាតិដូចគ្នា
    - ជាសហគមន៍ ដែលរៀបចំឡើងដោយរដ្ឋាភិបាលតែមួយ
    - បង្ហាញពីអត្តសញ្ញាណជាតិ បណ្តុះជាតិនិយម...

- ជាតិផ្អែកលើមូលដ្ឋានរួម ភាសា ទឹកដី ជីវភាព សេដ្ឋកិច្ច វប្បធម៌...

ក្នុងរឿងៈផ្នែកសង្គមៈ

1. សង្គមកិច្ច

– លក្ខណៈជាតិស្ដែងឡើងតាមរយៈជីវភាពនៃសង្គមខ្មែរ

- ឈ្មោះតួអង្គៈ តួអង្គជាមនុស្សខ្មែរសុទ្ធសាធ ដែលរស់នៅលើទឹកដីខ្មែរ( ទុំ ទាវ ពេជ្រ នោ ម៉ឺនងួន អរជូន ស្ដេចរាមា មិនមែនជាស្ដេចព្រហ្មទត្ត ទសរថ ដូចជារឿងដទៃនោះទេ) ឈ្មោះទាំងនេះមានលក្ខណៈធម្មតា មិនអច្ឆរិយ ដែលមនុស្សទាំងនោះរស់នៅក្នុងសង្គម។ ឧ. ថ្លាថ្លែងសម្ដែងឈ្មោះទុំ នៅស្រុកបាភ្នំដែនដីខ្មែរ...
- ទីកន្លែងៈ សម័យលង្វែក សំរោងទង ស្រុកគងពិសីត្បូងឃ្មុំ...សុទ្ធតែទាក់ទងភូមិស្រុក ខេត្ត ក្នុងស្ថានភាពភូមិសាស្ត្ររបស់ប្រទេសខ្មែរ។
- ជីវភាពប្រជាជនៈ ប្រជាជនប្រកបរបរកសិកម្មព្រោះលក្ខខណ្ឌធម្មជាតិ មានអំណោយផលខាងកសិកម្ម
  - សម្ភារប្រើប្រាស់ៈ រទេះគោ ដំរី ទូក ខ្លុយ ទ្រ ក្អមទឹកអណ្ដូង...ឧ. ពេជ្រ ទុំ ផលិតតោកលក់ ប្រជាជន

មានសមត្ថភាពផលិតសូត្រលក់ " សឹងព្រៃសុទ្ធសាធល្អ លាំងកែម៉ូតម៉ាតពណ៌ខៀវខ្ចី..."

- ការកម្សាន្តសិល្ប: ប្រជាជនចូលចិត្តស្តាប់តន្ត្រី...

2. កល្ខណៈដាត់ស្តែងតាមរបបគ្រប់គ្រង៖

របបគ្រប់គ្រងក្នុងរឿងទុំទាវគឺជាផ្ទាំងមួយរបស់សង្គមនាសម័យលង្វែកអំណាចគឺស្ថិតលើស្តេចទាំងមូល ដោយមានស្តេចត្រាញ់ជាជំនួយ៖

- អំណាចស្តេចផែនដី៖ វណ្ណៈខ្ពស់បំផុតរបស់របបសក្តិភូមិ ហើយមានសិទ្ធិកាន់អំណាចគឺស្តេច។ ព្រះរាមាតំណាងឱ្យអ្នកកាន់អំណាចសក្តិភូមិ(គិតពីស្រីញី មិននឹកនាសុខទុក្ខប្រជារាស្ត្រ កាត់ទោសគ្មានសុភវិនិច្ឆ័យ ) តាមរឿងស្តេចខឹងអរជូនណាស់ តែអរជូនសមស្លាប់ប៉ុន្តែ " ធ្វើទុក្ខធ្វើទោសឱ្យអស់សូន្យ សន្តានបងប្អូនបញ្ចូនងារ..."
- អំណាចស្តេចត្រាញ់៖ ត្រួតត្រាតាមតំបន់ មានអំណាចផ្តាច់ការមិនខុសពីស្តេចរាមា។ ស្តេចធំជាងគេ តែស្តេចត្រាញ់តូចជាងស្តេចតែមួយគត់។ ឧ. " ឧកញ៉ាអរជូនមាំមួនពេក ចម្ងាក្រោមមេឃទាបជាងភ្នំ..."
- អំណាចគ្រួសារ៖ ដោយឥទ្ធិពលរបបផ្តាច់ការនាសម័យនោះបានជះឥទ្ធិពលដល់អ្នកមានទ្រព្យសម្បត្តិប្រើអំណាចផ្តាច់

ការក្នុងគ្រួសារ កូនគ្មានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្ត ជ្រើសរើសគូស្រករឡើយ។ ឧ.″ មិនដែលសោះឡើយទាវ អើយនំ ចទ្បើសបើសធំម្តេចជាងនាលិ…″

- អ្នកងារ៖ វណ្ណៈដែលទាបជាងគេគឺមហាជន ប្រជាជនរស់នៅក្នុងភាពភ័យខ្លាចលំបាកវេទនា។ ពួកគេពុំដឹងហេតុផលអ្វីសោះ តែត្រូវមានទោស។ ឧ. ″ ភ័យខ្លួនពួនជ្រកវត់រកហៅកូនចៅទៅផ្ទះរហ័សឆាប់ ចូលព្រៃរំពៃខ្លាចគេចាប់ សម្លាប់ដូចទុំជំនុំគ្នា″។

3. វិស័យសេដ្ឋកិច្ច៖ ( កសិកម្ម សិប្បកម្ម គមនាគមន៍ …ផ្នែកវប្បធម៌ជាតិ

តាមរយៈរឿងទុំទាវឱ្យឃើញពីចំណុចផ្សេងៗ ដែលជាទំនៀមទម្លាប់ប្រពៃណីសំខាន់នាសម័យលង្វែក ហើយប្រកាន់យករហូតដល់បច្ចុប្បន្ន៖

- ទំនៀមទម្លាប់ក្នុងមង្គលការ៖
  - ពិធីចូលម្លប់៖ ទាវចូលម្លប់
  - អាពាហ៍ពិពាហ៍ខ្មែរកើតឡើងតាំងពីសម័យបុរាណមាន ហែរជំនូន ពិធីស្តីដណ្តឹង ពិធីជូនកំណត់ សំពះផ្ទឹម…ឧ. ″ …ឱ្យទៅស្រដីខាងមេបា នាងទាវតើថាប្រការម្តេច?″

❖ ជំនឿ៖

- ជឿលើកម្មផល( ឧ. " អញនៅមិនបានឡើយ ព្រះគុណខ្ញុំអើយហេតុតែកម្ម" )
- ជឿលើការទស្សន៍ទាយ៖ ព្រះគ្រូចៅអធិការមិនឱ្យទុំសឹក ឧ. " លោកគ្រូស្តាប់ដាក់កន្រ្ទាក់ក្តារ ឆ្នូនបូកលេខហាថាតែហោង..." បញ្ជាក់ថាខ្មែរមុននឹងធ្វើអ្វីមួយគឺទាយសិន...
- ជឿលើមន្តគាថា៖ ទុំសូត្រមន្តស្នេហ៍សារិកាលិនថោងដាក់ស្នេហ៍ទាវ

បញ្ហាជំនឿទាំងនេះជាចំណង់ចំណូលចិត្ត គំនិតខ្មែរ ហើយនៅតែមានក្នុងសង្គមទោះបីឈានទៅដល់វិទ្យាសាស្រ្ត។

❖ សាសនា និងវត្តអារាម

- សាសនា កូនប្រុសបួសរៀននៅវត្ត " កើតឡើងលុះធំល្មមប្រមាណ ...ស្វះស្វែងនៅវត្តវិហារធំ..."
- ទីវត្តអារាម៖ កន្លែងផ្តល់ចំណេះដឹង អប់រំ បង្រៀនផ្សព្វផ្សាយព្រះពុទ្ធសាសនា...

❖ ផ្នត់គំនិត៖

- ទស្សន " នំមិនធំជាងនាលិ"

- មិនទុំមុនស្រគាលៈ ខ្មែរយើងប្រកាន់ណាស់ហើយ រឿងទុំទាវគឺជូនតាយើងអប់រំមិនឱ្យប្រព្រឹត្តខុសគន្លង ប្រពៃណី...
- ភក្តីភាព៖ ប្រពន្ធមានភាពស្មោះត្រង់ជាមួយប្តី ស្តែង នាងទាវ...

## សម្បត្តិធម្មជាតិនានា

- ចំពោះព្រៃឈើ៖ ដើមជ្រៃ គុយ ក្រសាំង ក្ទម្ព ញ៉ៅ ស្វាយ ក្រូច សណ្តាន់ ផ្កាស្រែង...”មើលមានជ្រៃជ្រៃ សង្កែផ្ចាន់ ...” ឈើទាំងអស់នោះគឺជាអត្តសញ្ញាណ ជាតិខ្មែរពិត។
- ចំពោះវារីជាតិ៖ ព្រលឹត ត្រកៀត ត្រកួន ត្របែកព្រៃ
- ចំពោះបក្សាបក្សី៖ សត្វក្រវាត់ទុំ មៀម ទីទុយ លលក ពពេច កន្លង់ ត្រលេងត្រលោង...
- ចំពោះមច្ឆាជាតិ៖ ត្រីរ៉ស់ ត្រីព្រួល ប្រា ពោ កន្លង់ ចង្វា ...

.... បង្ហាញពីអត្តសញ្ញាណជាតិដែលមាននៅខ្មែរពិត

## លក្ខណៈជាតិស្តែងតាមចរិតលក្ខណៈរបស់តួអង្គ

- ទុំទាវ៖ តំណាងឱ្យយុវជនខ្មែរសម័យមុនដែលចង់បានសេរីភាពក្នុងគ្រួសារ នាងទាវតំណាងឱ្យកូនស្រីខ្មែរដែលម្តាយបង្ខំ
- ម្តាយទាវ៖ តំណាងឱ្យម្តាយទូទៅនិយមប្រើអំណាចមកលើកូន
- អរជូន៖ ចៅហ្វាយខេត្តសម័យសក្តិភូមិ
- ព្រះរាជា៖ តំណាងឱ្យស្តេចខ្មែរមួយចំនួនដែលសាបព្រោះអំពើជិះជាន់ប្រជាជន

ផ្នែកអត្ថរូប

- ភាសា៖ ប្រើពាក្យពេចន៍សាមញ្ញផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ
- កំណាព្យ៖ ជាបទពាក្យប្រាំពីរ ជាកំណាព្យរបស់ខ្មែរ
- វិធីតែងនិពន្ធ៖មានទំនោរតាមចំណង់ចំណូលចិត្តរបស់ខ្មែរ ទាំងផ្តើម តួរឿង និងបញ្ចប់

សរុបសេចក្តី៖

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន
- ទស្សនៈផ្ទាល់ខ្លួន

**ប្រធានទី៣១៖** សុភាសិតមួយពោលថា«ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី»។ តើសុភាសិតនេះមានអត្ថន័យដូចម្តេច? ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ក្នុងរឿង ធនញ្ជ័យ រឿង រាមកេរ្តិ៍ រឿង ភូមិតិរច្ឆាន មកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖សរសេរឱ្យទាក់ទងនឹងប្រធាន
- ចំណូលបញ្ហា៖លើកប្រធានមកសរសេរ
- ចំណោទបញ្ហា៖ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ: ទឹកឡើង ទឹកហោច ស៊ី ត្រី ស្រមោច
- ពន្យល់ន័យប្រធាន:
- បកស្រាយបរធាន៖

***អត្ថ**ន័យចំ:* មានន័យថាពេលទឹកឡើង.........................ពេលទឹកស្រក ...............................................។

- *ពង្រីកន័យប្រធាន:*
  - ✓ *ទឹកជាប្រភពដ៏សំខាន់..................តែក៏មានគុណសម្បត្តិ...*
  - ✓ *ត្រីជាសត្វដែលរស់នៅក្នុងទឹក...*
  - ✓ *ស្រមោចជាសត្វ...*
  - ✓ *សភាពទឹកឡើង លិចលង់ ល្ហល្ហាច ...លិចភូមិឋាន...*
  - ✓ *បង្កគ្រោះថ្នាក់ដល់ដល់ជីវ:លើគោក គ្មានជម្រក គ្មានដើមឈើ...*
  - ✓ *ខំប្រវេប្រវាលើផ្ទៃទឹក តោងកំណាត់ឈើ...គ្មានចំណីអាហារ...*
  - ✓ *ប្រការនេះ...ស្រមោចងាយត្រីចាប់ស៊ី...អស់ឫទ្ធិព្រោះមិនអាចយកឈ្នះត្រីបានមានតែបណ្តោយ*
  - ✓ *សភាពទឹកស្រក គោក រីងស្ងួត...*
  - ✓ *ជីវិតក្នុងទឹកដូចជាត្រី...ក្រៀមស្រកា...មិនអាចតតាំងជាមួយស្រមោច...ត្រីងាប់ ស្រមោចស៊ីតាមចិត្ត...។*

*ជារួម.......................................................................................។*

***ន័យធៀប:*** *ទឹកឡើងបីដូចអំណាច ឫទ្ធិ ជ័យជម្នះ...។ ទឹកស្រកអំណាចថយ បរាជ័យ អស់បុណ្យ...។ ត្រី ដូចជា អ្នកមានអំណាច*

មានទ្រព្យ...។ ស្រមោចដូចជា រាស្ត្រ អ្នកគ្មានអំណាច អ្នកក្សត់ខ្សោយ...។ដូចនេះគេប្រៀប............................។

- ពង្រីកន័យធៀប
    - ✓ ពេលអ្នកតូចជួបអាសន្ន មានទុក្ខលំបាក...អ្នកមានឥទ្ធិពលធ្វើទុក្ខបុកម្នេញ...
    - ✓ អ្នកមានស័ក្តិយសជិះជាន់អ្នកក្រ គ្មានត្រាប្រណី
    - ✓ កេងប្រវ័ញ្ច ធ្វើបាប មិនផ្តល់សិទ្ធិ...
    - ✓ ធ្វើទារុណកម្មតាមរូបភាពផ្សេងៗ បៀតបៀនជីវិត...
    - ✓ នាំឱ្យអ្នកក្រចងចាំការជិះជាន់...
    - ✓ ភាពសង្កត់អ្នកតូចនេះ ធ្វើឱ្យគេចងចាំមិនភ្លេច
    - ✓ ប្រការនេះពេលអ្នកតូច...មានឱកាសវិញសងសឹកធ្វើបាបចាស់ដៃ មានគំនុំ...
    - ✓ រហូតបាត់បង់ជីវិតដោយសេចក្តីឈឺចាប់ដែលគេជួបប្រទះ...

ជារួម..............................................................។

ឧទាហរណ៍៖

- **ក្នុងសង្គម** ចោរល្លួចគ្រប់ប្រភេទមានកម្លាំង មានអាវុធ...គេខ្លាច ដល់គេចាប់បាន...។ ប្លន់ជីមួយចំនួន ...........................................។

- ប្រវត្តិសាស្ត្រ: លន់ នល់ សម្លាប់ខ្មែរ..............ខ្មែរ .........................សងសឹកទៅវិញទៅមក.......។ រាជដណ្តើម ស្តេច......................................................
- អក្សរសិល្ប៍:
  - ✓ រឿងធនញ្ជ័យ(ធនញ្ជ័យជាមួយសេដ្ឋី)
  - ✓ រឿងរាមកេរ្តិ៍( នាងសូរបនខា ជាមួយព្រះរាម ...)
  - ✓ រឿងភូមិតិរច្ឆាន( ឬាវាំង និងជូន នៅ)

សរុបៈន័យចំ និងន័យធៀប

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធានៈ
- ទស្សនៈ
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី៣២៖** មានទស្សនមួយពោលថា«ការងារផ្តល់នូវសុភមង្គលដល់មនុស្ស»។ ចូរពន្យល់ព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងនឹងប្រធាន
- ចំណូលបញ្ហា៖ សរសេរប្រធានមកវិញ
- ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី៖

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ការងារ សុភមង្គល
- ពន្យល់ន័យប្រធាន៖
- បកស្រាយប្រធាន៖

សេចក្តីលម្អិត

- ✓ ប្រភេទការងារដែលមានក្នុងសង្គម៖ កសិករ គ្រូបង្រៀន ឧស្សាហកម្ម ទេសចរណ៍ ពាណិជ្ជករ សិល្បករ...។

- ✓ បំណែងចែកប្រភេទការងារ៖ កម្លាំងកាយ កម្លាំងប្រាជ្ញា
- ✓ លទ្ធផល
  - ធ្វើឱ្យមនុស្សមានទំនួលខុសត្រូវ
  - មានទ្រព្យ សក្តិយស កេរ្តិ៍ឈ្មោះ
  - មានអាហារហូបគ្រប់គ្រាន់
  - ឱ្យមនុស្សចៀសផុតពីភាពរវើរវាយ
  - ចៀសពីអំពើអបាយទាំងឡាយ
  - ធ្វើឱ្យមនុស្សឃ្លាចឆ្ងាយពីល្បែងស៊ីសង
  - ឃ្លាតពីស្រី ស្រា ខាវ៉ាអូខេ
  - ជួយបណ្តេញជាតិពុលក្នុងខ្លួន
  - ជួយឱ្យមនុស្សរកប្រាក់បានច្រើន
  - ជួយឱ្យមនុស្សរស់នៅក្នុងសង្គមគ្មានការស្អប់ខ្ពើម...

ឧទាហរណ៍៖

- សង្គម៖ ប្រជាជនប្រកបរបរកសិករ...មានបាយហូប មានថវិកាសម្រាប់ដោះដូររបស់របរដែលខ្លួនត្រូវការ...បញ្ចេញជាតិពុលពេលធ្វើការបែកញើស...។
- ប្រវត្តិសាស្ត្រ៖ សម័យបុរេប្រវត្តិតាំងពីមនុស្សមិនទាន់ចេះធ្វើការរហូតចេះច្នៃប្រឌិតជាសម្ភារប្រើប្រាស់ ផ្ទះសម្បែង សម្លៀកបំពាក់ ទូរសព្ទ ប្រដាប់ទាក់ទង មធ្យោបាយសម្រាប់

ធ្វើដំណើរ...ពីការប្រើដៃជើង មកប្រើខួរក្បាល...មានការវិវត្ត ក៏ដោយសារការងារ...។

- ក្នុងអក្សរសិល្ប៍៖
  - ✓ រឿងកុលាបប៉ៃលិន៖
    - ○ បំបាត់ភាពរវើរវាយ
    - ○ បំបាត់ភាពភ័យខ្លាច
    - ○ បង្កើនជីវភាព
    - ○ ផ្ដល់ថាមពលសុខភាពល្អ
    - ○ មានជីវិតរស់នៅប្រកបដោយសុភមង្គល
  - ✓ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
    - ○ ពេលអត់ការធ្វើ តួអង្គសមវិលវល់បាត់សតិ
    - ○ ជីវិតអនាថា
    - ○ ប៉ុន្តែក្រោយពីមានការងារធ្វើ សមទទួលបាន ជីវិតថ្មី មានគោលដៅច្បាស់លាស់ មាន ប្រាក់សម្រាប់ចិញ្ចឹមជីវិត មានកិត្តិយស ...។
  - ✓ រឿង ថៅកែចិត្តចោរ
    - ○ ពូហំធ្វើយ៉ាងណាក៏មិនអាចមានជីវភាពធូរ ធារនេះក៏ដោយសារសង្គមមានអំពើពុក រលួយ...។ ជំរុញឱ្យពូហំប្រព្រឹត្តិអំពើអាក្រក់ រហូតបាត់បង់កិត្តិយស ជាប់គុក។ ប្រសិនបើ

ពូហំធ្វើការងារស្របនឹងច្បាប់សង្គម រួមទាំងសង្គមមានភាពយុត្តិធម៌ម្ល៉េះ សមពូហំច្បាស់មានជីវភាពធូរធារ...

សរុបសេចក្តីមក

## គ. សេចក្តីបញ្ចប់៖

- ✓ វាយតម្លៃប្រធាន៖ ...អប់រំមនុស្សឱ្យស្រឡាញ់ការងារ .................។
- ✓ មតិផ្ទាល់ខ្លួន៖ ដូចនេះ.................................។

**ប្រធានទី៣៣៖** សុភាសិតមួយចែងថា«ទឹកត្រជាក់ត្រីកុំ»។ ចូរបកស្រាយដោយលើកឧទាហរណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- ✓ លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងនឹងប្រធាន
- ✓ ចំណូលបញ្ហា៖ សរសេរប្រធានបទ
- ✓ ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ✓ ឃ្លាភ្ជាប់សេចក្តី
- ✓ ពន្យល់ពាក្យ៖ ត្រជាក់ កុំ
- ✓ ពន្យល់ន័យប្រធាន៖ ទឹកដែលមានភាពសុខស្រួលត្រជាក់ ត្រជុំ មានសុវត្ថិភាពនោះនឹងមានសត្វត្រី ប្រមូលផ្តុំគ្នាមករស់នៅ។ ដូចជាទីកន្លែងដែលផ្តល់សុខសាន្តដល់មនុស្ស ច្បាស់ជាមានមនុស្សមករស់នៅកុះករជាក់ជាមិនខាង។
- ✓ បកស្រាយប្រធាន៖

***ន័យចំ៖*** *...កាលណាទឹកដែលមានសីតុណ្ហភាពត្រជាក់សមល្មម ទីនោះសម្បូរដោយពពួកសត្វត្រីមករស់នៅ។*

***ពង្រីកន័យចំ៖***

- *ទឹកដែលត្រជាក់ ច្បាស់ជាមានរុក្ខជាតិដុះ មានចំណីច្រើន មានសុវត្ថិភាព មានរបងការពារ...ត្រីបន្តរស់នៅក៏ដូចជាបន្ត ពូជនៅទីនោះ...ជាហេតុសម្បូរទៅដោយសត្វត្រី...។*

*ឧទាហរណ៍៖ បឹងទន្លេសាបពេលមានទឹកមានត្រី តែបើបឹងរីងស្ងួតហួតហែង...*

***ន័យធៀប៖***

- ✓ *ទឹកត្រជាក់ប្រៀបប្រដូចទៅនឹងទីកន្លែង ដែលល្អ មានសុវត្ថិភាព សម្បូរទៅដោយការងារធ្វើ...។*
- ✓ *ត្រីកុំ ប្រៀបបានទៅនឹងមនុស្សដែលមករស់នៅ មកប្រមូលផ្តុំ...។ ទីណាមានសុខសុវត្ថិភាពមានការងារដែលផ្តល់សេចក្តីសុខទាំងកាយ និងចិត្តនោះនឹងមានមនុស្សរស់នៅកុះករ។*

***ពង្រីកន័យធៀប៖***

- ✓ *រូបភាពនៃសេចក្តីត្រូវការរបស់មនុស្ស៖ ជម្រក ការងារ ការកំសាន្ត សុវត្ថិភាព...។*

- ✓ ទីកន្លែងដែលសម្បូរទៅដោយមនុស្សរស់នៅគឺ...

ឧទាហរណ៍៖

- ✓ ក្នុងសង្គម៖ ទីក្រុងភ្នំពេញ ឬក្រុង...
- ✓ ប្រវត្តិសាស្ត្រ៖ សម័យអង្គរ...
- ✓ ក្នុងអក្សរសិល្ប៍៖
    - រឿងកុលាបប៉ៃលិន៖ ចៅហ្វាយនាយយមានទឹកចិត្តល្អដល់កម្មករ...មានកម្មករធ្វើការច្រើន...។
    - រឿង ព្រះវេស្សន្តរ៖ព្រះវេស្សន្តរនៅតែបន្តការធ្វើទានទោះបីមានការមិនពេញចិត្តពីប្រជារាស្ត្រក៏ដោយ... ដោយភាពមេត្តា យកព្រះទ័យទុកដាក់ចំពោះប្រជារាស្ត្រ...សង្គមព្រះអង្គប្រជាជនរស់នៅសម្បូរសប្បាយ និងស្រឡាញ់ គោរពព្រះអង្គ...។
    - ក្នុងរឿង តេជោយ៉ត៖ ការពលីកម្មការពារប្រទេសជាតិឱ្យមានភាពសុខសាន្ត មានសុវត្ថិភាពរបស់តេជោយ៉ត...ធ្វើឱ្យប្រជាជន និងមន្ត្រីស្រឡាញ់រាប់អាន មិនមនុស្សជាច្រើនចាំធ្វើតាមបញ្ជាក៏ដូចជារស់នៅជាមួយតេជោ...។

សរុបសេចក្តីមក

## គ. សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន
- ✓ ទស្សនផ្ទាល់ខ្លួន៖

**ប្រធានទី៣៤៖** សុភាសិតមួយចែងថា«ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់»។ ចូរពន្យល់ឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធានបទ
- ចំណូលបញ្ហា៖ សរសេរប្រធាន
- ចំណោទបញ្ហា៖ចោទសួរបែបពន្យល់

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ៖ ស្លឹកឈើ ជ្រុះ គល់
- ពន្យល់ន័យប្រធាន៖ ស្លឹកដែលជាប់នឹងដើមឈើ នៅពេលដែលវាលូតលាស់ រមែងរបូត ឬជ្រុះនៅក្បែរ ឬមិនឆ្ងាយពីគល់របស់វាឡើយ។ ប្រៀបដូចទៅនឹងកូនចៅក្រោមឱវាទតែងតែមានលក្ខណៈដូចគ្នាទៅនឹងឪពុកម្តាយ។
- ន័យធំ៖ ស្លឹកឈើដែលជាអវៈយវៈរបស់រុក្ខជាតិ ពេលវាលូតលាស់ទៅ រមែងជ្រុះនៅក្បែរគល់ឈើនោះឯង។

**ពង្រីកន័យចំ៖**

- ✓ នៅក្រោមដើមឈើតែងមានស្លឹក
- ✓ នៅពីក្រោមដើមឈើនោះ រមែងមានស្លឹកវាជ្រុះរបាត់រប៉ាយ ទៅមិនឆ្ងាយពីគល់
- ✓ បើយើងក្រឡេកទៅមើលវាលខ្សាច់ គ្មានស្លឹកឈើទេ ព្រោះគ្មានដើមឈើដុះនៅទីនោះ

- **ន័យធៀប**
  - ✓ ស្លឹកឈើប្រៀបបានទៅនឹងកូនចៅជំនាន់ក្រោយ អ្នកនៅក្រោមឱវាទ
  - ✓ គល់ឈើប្រៀបបានទៅនឹងមេបា ឬអ្នកដែលមានឥទ្ធិពលលើអ្នកដទៃ។ សុភាសិតនេះចង់បង្ហាញឱ្យឃើញថា កូនចៅ អ្នកក្រោមឱវាទរមែងមានអត្តចរិត រូបរាងទំនោរ ចិត្តគំនិត ស្រដៀងទៅនឹងមេបា ឬអ្នកស្ថិតក្រោមការគ្រប់គ្រងនរណាម្នាក់ គេនឹងមានទំនោរ របៀបរបប បែបបទទៅតាមនោះដែរ ។

**ពង្រីកន័យធៀប**

- ✓ ក្នុងគ្រួសារ៖ សមាជិកគ្រួសាររមែងមានមុខមានមាត់ មុខរបរ ការរស់នៅ និយាយស្ដី ការហូបចុកដូចគ្នា...
- ✓ ការងារ៖ ទីកន្លែងតែមួយអាចមានកូនចៅ ដែលស្ថិតក្រោមឱវាទមានគំនិត ទំនោរ អត្តចរិតដូចនឹងមេកើយ...
- ✓ មិត្តភាព៖ មានចិត្តដូចគ្នា មានចំណង់ចំណូលចិត្តប្រហាក់ប្រហែលគ្នា...
- ✓ ក្នុងសង្គម៖ មនុស្សដែលរស់នៅក្នុងសង្គមតែមួយរមែងមានផ្នត់គំនិត អត្តចរិត បែបបទនៃការរស់នៅប្រហាក់ប្រហែលគ្នា...

ឧទាហរណ៍៖

- ➢ សង្គម៖ រាជរដ្ឋាភិបាលសព្វថ្ងៃយកចិត្តទុកដាក់ចំពោះប្រជាជន...កូនទាំងអស់របស់លោកក៏ខិតខំស្វះស្វែងបម្រើប្រជាជនទៅតាមតម្រូវការ...។
- ➢ ប្រវត្តិសាស្ត្រ៖ ព្រះរាជាខ្មែរពីមួយជំនាន់ទៅមួយជំនាន់គឺជាខ្សែញាតិវង្ស
- ➢ អក្សរសិល្ប៍៖

- ✓ រឿងរាមកេរ្តិ៍៖ ទូភីមានអត្តចរិតដូចឪពុករបស់ខ្លួនមហឹង្សារាជ
- ✓ រឿងមរណមាតា៖ កូនចុងនាងចន្ធី និងនាងកាឡីមានអត្តចរិតដូចគ្នា
- ✓ រឿង ក្បូនជីវិត៖ នាងមាលា និងឪពុករបស់នាង

សរុបសេចក្ដី

## គ. សេចក្ដីបញ្ចប់

- ✓ វាយតម្លៃប្រធាន
- ✓ មតិផ្ទាល់ខ្លួន

**ប្រធានទី៣៥៖** *សុភាសិតមួយពោលថា«ចេះពីរៀន មានពីរក»។ ចូរពន្យល់សុភាសិតខាងលើនេះដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។*

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- *លំនាំបញ្ហា៖ សរសេរឱ្យទាក់ទងប្រធាន*
- *ចំណុលបញ្ហា៖ លើកប្រធានមកសរសេរ*
- *ចំណោទបញ្ហា៖ចោទសួរបែបពន្យល់*

### ខ. តួសេចក្តី៖

- *ឃ្លាភ្ជាប់សេចក្តី*
- *ពន្យល់ពាក្យ*
  - ✓ *ចេះមានន័យថា ប្រាជ្ញា មានចំណេះដឹង មានចំណេះធ្វើ...*
  - ✓ *រៀនមានន័យថា សិក្សា ឈ្វេងយល់ ក្រេបជញ្ជាក់ចំណេះដឹងគ្រប់បែបយ៉ាង...*
  - ✓ *មាន សំដៅលើការសម្បូរហូរហៀរ បរិបូរណ៍ដោយភោគទ្រព្យនានា*

- ✓ *រកសំដៅដល់ការសង្វាត ស្វែងឱ្យជួប រកស៊ី ប្រកបរបរចិញ្ចឹមជីវិត...។*

- *ពន្យល់ន័យប្រធានៈ ប្រធានចង់បង្ហាញថា អ្នកមានប្រាជ្ញាមានចំណេះដឹង គឺបណ្តាលមកពីគេខិតខំឈ្វេងយល់ ក្រេបយកចំណេះដឹងគ្រប់យ៉ាង...។ ចំណែកឯអ្នកមានទ្រព្យវិញ... ការខំប្រឹងរក ខំប្រឹងប្រកបរបររកស៊ី ចិញ្ចឹមជីវិតប្រចាំថ្ងៃ។*
- *បកស្រាយប្រធានៈ អ្វីគ្រប់យ៉ាងតែងតែទទួលបានផលដោយមានការខិតខំប្រឹងប្រែង តស៊ូ អំណត់ ព្យាយាមគ្រប់បែបយ៉ាង និងគ្រប់ពេលវេលា។*

**ចេះពីរៀន**

*-ចំណេះកើតឡើងពីការរៀនសូត្រដោយខំប្រឹងបន្តិចម្តងៗ...*

*-គ្មាននរណាម្នាក់កើតមកចេះឯងនោះទេ*

*-ការសិក្សារបស់សិស្សានុសិស្ស ពួកគេត្រូវស្វះស្វែង*

*-ចំពោះអ្នកធ្វើការរាជការ បម្រើសង្គមជាតិក៏ពួកគេនៅតែព្យាយាមសិក្សាជំនាញបន្ថែម...*

*-ចំពោះសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិក្សាបន្ថែមដើម្បីឱ្យចំណេះដឹងរីកចម្រើន...*

*ឧទាហរណ៍៖*

- **ក្នុងសង្គម៖**
  - សង្គមអតីតកាល៖ សម្តេចព្រះសង្ឃរាជ ជួនណាត...
  - សង្គមជាក់ស្តែង៖ លោក កេង វ៉ាន់សាក់...
- **ក្នុងអក្សរសិល្ប៍៖**
  - រឿង សូផាត៖ ខំប្រឹងរៀនសូត្រ មានចំណេះដឹងក្នុងខ្លួន...
  - រឿង មាលាដួងចិត្ត៖ ទីឃាវុធខំប្រឹងរៀនសូត្រ ក្លាយជាអ្នកមានចំណេះ ចេះភាសាបរទេស...។

**មានពីរក៖**

-មនុស្សខំប្រឹងរក សង្វាតរកស៊ី ដោយសន្សំបន្តិចម្តង ... ឧស្សាហ៍ព្យាយាម

-ចេះបត់បែនមិនចុះចាញ់នឹងឧបសគ្គ ដឹងពីតម្រូវការសង្គម

-មិនស្អប់ខ្ពើមការងារសុចរិត ដោយបង្កើតមុខរបរបន្ថែម...កត្តាទាំងនេះនឹងធ្វើឱ្យយើងមានទ្រព្យសម្បត្តិច្រើន

-គ្មានអ្វីបានមកស្រួលដោយមិនមានការខំប្រឹង...

-ទោះបណ្តាលអ្នកមានទាំងឡាយ គេខិតខំរកសន្សំមិនខ្ជះខ្ជាយពេលវេលា...

បណ្តាលក្រុមហ៊ុនជាច្រើន កើតឡើងពីការខំប្រឹងប្រែងធ្វើការងាររបស់ម្ចាស់ក្រុមហ៊ុន នាំឱ្យពួកគេមានទ្រព្យសម្បត្តិច្រើន...។

ឧទាហរណ៍៖

- ✓ ក្នុងសង្គម៖ លោកឧកញ៉ា ម៉ុង ឬទ្ធី លោកខិតខំមិនស្គាល់ពាក្យថាហត់ ខំប្រឹងរកស៊ីគ្រប់យ៉ាង មិនថាការងារតូច ឬធំ ចំណុចទាំងនោះហើយដែលធ្វើឱ្យលោកក្លាយជាសេដ្ឋីក្នុងស្រុកខ្មែរ។
- ✓ ក្នុងអក្សរសិល្ប៍៖
  - ○ រឿង កុលាបប៉ៃលិន៖ លោក ហ្លួង រតនសម្បត្តិ ខំប្រឹងរកស៊ីរហូតមានទ្រព្យសម្បត្តិ..
  - ○ រឿង មាយើង៖ គ្រួសារមាយើងខិតខំធ្វើការ មិនខ្លាចហត់ ទោះលំបាក ប្រើកម្លាំងកាយ ឬចិត្តកថៅមាណពនៅតែធ្វើ...រហូតក្លាយជាសេដ្ឋី។
- សរុបសេចក្តីមក

គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន
- ទស្សនៈផ្ទាល់ខ្លួន
-

**ប្រធានទី៣៦៖**ប្រធាន«ចូរអ្នកធ្វើការប្រៀបធៀបលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងលក្ខណសម្បត្តិនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ»។ តើព្រះនាងទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ងណាខ្លះ?

## គម្រោងតែង

### ក. សេចក្ដីផ្ដើម៖

- ✓ លំនាំបញ្ហា៖ រូប...លក្ខណៈខាងក្នុង...ក៏ជាទីចាប់អារម្មណ៍...។
- ✓ ចំណូលបញ្ហា៖ ...ទើបតម្រូវឱ្យយើងធ្វើការប្រៀបធៀប...។
- ✓ ចំណោទបញ្ហា៖ តើនារីទាំងពីរ...ដូច និងខុសគ្នាយ៉ាងណាខ្លះ?

### ខ. តួសេចក្ដី

- ✓ ឃ្លាភ្ជាប់សេចក្ដី
- ✓ ពន្យល់ពាក្យ
- ✓ -លក្ខណៈមានន័យថាសំដៅទៅលើចរិតលក្ខណៈតួអង្គ...។
- ✓ ពន្យល់ន័យប្រធាន៖ ប្រធានខាងលើចង់ឱ្យយើងពន្យល់ពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នានៃចរិតលក្ខណៈ...។

✓ បកស្រាយប្រធាន(ចំណុចដូច និងចំណុចខុសគ្នា)

ចំណុចដូចគ្នា៖ គំនិតសំខាន់

✓ ជានារីស្រស់ស្អាតដូចគ្នា
✓ ជានាទីពោរពេញទៅដោយភក្តីភាព
✓ យាងទៅជាមួយស្វាមី ទៅរស់នៅក្នុងព្រៃ

ឧទាហរណ៍៖

✓ ព្រះនាងសីតាជានារីល្អឯក ជាគូនឹងអវតាព្រះវិស្ណុតាមបែបព្រាហ្មណ៍សាសនា...
✓ រីឯព្រះនាងមទ្រីជានារីល្អឯក ជាកន្សែងសារពេជ្ជ ជាគូនឹងព្រះពោធិសត្វ តាមបែបពុទ្ធសាសនា...
✓ ពេលព្រះវេស្សន្តរយាងទៅក្នុងព្រៃ ព្រះនាងមទ្រីសុំយាងទៅជាមួយ។ រីឯព្រះនាសីតាយាងទៅតាមព្រះរាមបួសរយៈពេល ១៤ឆ្នាំ...។

**សរុបលក្ខណៈដូច៖**

លក្ខណៈខុសគ្នា

គំនិតសំខាន់ និងឧទាហរណ៍៖

✓ ព្រះនាងសីតា

-ព្រះនាងជានារីល្អឯកតាមព្រាហ្មណ៍សាសនា តាមជួយបំពេញកាតព្វកិច្ច ចំពោះអវតាព្រះវិស្ណុ

-ព្រះនាងជួបព្រះស្វាមីដោយការប្រឡងប្រជែងលើកធ្នូ៖ ព្រះបាទជនកបានប្រកាសបណ្តាលកូនកំលោះទាំងអស់ ប្រសិនបើមានក្សត្រអង្គណាអាចលើកធ្នូសនេះរួច នឹងទទួលបានព្រះនាងសីតាជាមហេសី។ ក្នុងបណ្តាលក្សត្រទាំងបីភពមានតែព្រះរាមទេដែលអាចលើកធ្នូសនោះរួច ហើយបានរៀបអភិសេកជាមួយព្រះនាងសីតា។

-ព្រះនាងសីតាមានបុត្របង្កើតតែមួយអង្គគឺរាមលក្ស្មណ៍៖ ចំណងស្នេហ៍រវាងព្រះនាងជាមួយនឹងព្រះរាមទទួលបានបុត្រាមួយអង្គគឺរាមលក្ស្មណ៍...។

-ព្រះនាងប្រកាន់ពាក្យសត្យ ក្លាហាន និងមានទំនួលខុសត្រូវ៖ ព្រះនាងគោរពពាក្យសច្ចៈមិនជួបព្រះរាម ឬវិលចូលនគរវិញទេ...។

✓ ព្រះនាងមទ្រី

-ព្រះនាងមទ្រីជាកន្សែរសារពេជ្រ ជាអ្នកជួយបំពេញទានបារមីឱ្យព្រះពោធិសត្វ៖ ព្រះនាងកើតក្នុងជាតិចុងក្រោយ ព្រះនាងបានជួយបំពេញទានព្រះវេស្សន្តរគ្រប់សកម្មភាព...

-ព្រះនាងស្លូត និងទន់ភ្លន់ ចេះជួយដោះស្រាយបញ្ហាចំពោះមុខ៖ ព្រះនាងជួយពន្យល់ព្រះវេស្សន្តរពីសូរសន្លឹកទ័ព...។

-ព្រះនាងមានមានចិត្តមេត្តា ជួយព្រះស្វាមី គោរពតាមបំណងព្រះស្វាមី...

-ព្រះនាងគាំទ្រក្នុងព្រះពុទ្ធសាសនា ដោយធ្វើការបរិច្ចាគទាន

-ព្រះនាងទ្រាំរស់នៅជាមួយព្រះស្វាមីរយៈពេល ចិញ្ចឹមបុត្រពីរព្រះអង្គ...។

*សរុបលក្ខណៈខុស៖*

- ✓ សរុបរួម៖ សរុបតាមការបកស្រាយ រួមមានអំណះអំណាងទាំងលក្ខណៈដូច និងលក្ខណៈខុសគ្នារវាងក្សត្រីទាំងពីរព្រះអង្គ។ បើទោះបីជាតួអង្គទាំងពីរ...។

## គ. សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន៖...លក្ខណៈសម្បត្តិប្រសើរដូចគ្នា ជួបស្ថានភាពប្រហែលគ្នា...។
- ✓ មតិផ្ទាល់ខ្លួន៖ ...

**ប្រធានទី៣៧៖** ទស្សនៈមួយចំនួនយល់ថា«បុគ្គលដែលហ៊ានធ្វើពលិកម្ម សុទ្ធតែសម្លឹងឃើញប្រយោជន៍ផ្ទាល់ខ្លួន ។ តើអ្នកយល់យ៉ាងណា? ចូរពិភាក្សា។

## គម្រោងតែង

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ តាមធម្មតាមនុស្សសាមញ្ញតែងជួបជំពាក់ចំណងតណ្ហា ប្រាថ្នាគិតគូរតែប្រយោជន៍សួនតួ ទោះជាត្រូវលះបង់ធ្វើពលិកម្មបែបណា...តែងតែគិតដល់ផលប្រយោជន៍ខ្លួន...។
- ចំណោលបញ្ហា៖ ហេតុនេះហើយទើបមាន...លើកប្រធានមកសរសេរ...
- ចំណោលបញ្ហា៖ ...ត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- ✓ ឃ្លាភ្ជាប់សេចក្តី
- ✓ ពន្យល់ពាក្យ

-ពលិកម្ម៖ ការលះបង់ បូជាគ្រប់យ៉ាង

-ផលប្រយោជន៍៖...

- ✓ ពន្យល់ន័យប្រធាន៖
- ✓ បកស្រាយប្រធាន៖

មតិស្រប៖ ជាការពិតគ្រប់សកម្មភាព ទង្វើរបស់មនុស្សម្នាក់ ដែលស្តែងឡើងសុទ្ធតែប្រាថ្នា ចង់បាននូវប្រយោជន៍ ផលចំណេញត្រឡប់មកវិញសម្រាប់ខ្លួនឯង។ ដើម្បីបានប្រយោជន៍បុគ្គលខ្លះហ៊ានពលិកម្ម លះបង់គ្រប់យ៉ាងដូចជា៖

- ✓ ពេលវេលា កម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី
- ✓ សាច់ស្រស់ ឈាមស្រស់ អាយុជីវិត ទ្រព្យធន
- ✓ ប្រថុយនឹងគ្រោះថ្នាក់គ្រប់យ៉ាងធ្វើយ៉ាងណាឱ្យបានសម្រេចនូវផលចំណេញជាច្រើនដូចជា កិត្តិយស សក្តិ អំណាច...
- ✓ ព្រោះតែទ្រព្យសុខចិត្តធ្វើអ្វីគ្រប់យ៉ាងទោះជាប៉ះពាល់អាយុជីវិតអ្នកដទៃ ឬអ្នកដទៃឈឺចាប់ឡើយ

ឧទាហរណ៍៖ លើកភាពជាក់ស្តែងក្នុងសង្គម ចោរ ឬការជួញដូរគ្រឿងញៀន...

ក្នុងអក្សរសិល្ប៍៖

- ✓ រឿងរាមកេរ្តិ៍៖ ព្រះរាមធ្វើពលិកម្ម លះបង់គ្រប់យ៉ាងធ្វើសង្គ្រាមជាមួយក្រុងរាពណ៍ ដើម្បីប្រយោជន៍ខ្លួនជាធំ...ចង់បាននាងសីតា។
- ✓ រឿង ភូមិតិរច្ឆាន៖ បាដេសសុខចិត្តលះបង់ពេលវេលា កម្លាំងកាយប្រឈមមុខនឹងការគុំគួន...ព្រោះតែងចង់បានផលប្រយោជន៍សម្រាប់ខ្លួន គឺក្លាយជារេស៊ីដង់ពេញសិទ្ធិ។
- ✓ រឿង ចៅកែចិត្តចោរ៖ ពូហំហ៊ានប្រឈមមុខនឹងគ្រោះថ្នាក់...ចង់បានប្រាក់១ម៉ឺនរៀល...។

សរុបមតិស្រប៖ បុគ្គលដែលហ៊ានធ្វើពលិកម្មលះបង់គ្រប់យ៉ាង គឺសុទ្ធតែគិតដល់ប្រយោជន៍ផ្ទាល់ខ្លួនជាប្រាកដមែន។

**សំណួរភ្ជាប់៖ តើពិតដូចជាការលើកទាំងស្រុងដែរឬទេ?**

**មតិផ្ទុយ៖**

ផ្ទុយទៅវិញបុគ្គលជាច្រើនហ៊ានពលិកម្ម លះបង់គ្រប់យ៉ាងដើម្បីបម្រើប្រយោជន៍រួម ប្រយោជន៍ជាតិមាតុភូមិ ដោយមិនបានគិតដល់ប្រយោជន៍ផ្ទាល់ខ្លួនសូម្បីតែបន្តិច។ បានជាហ៊ានលើកឡើងដូច្នោះព្រោះបណ្តាលវីរជនជាច្រើន បានធ្វើពលិកម្ម ដើម្បី៖

- ✓ រំដោះប្រទេសចេញពីការគាបសង្កត់ ជិះជាន់ពីបរទេស
- ✓ ទាមទារសិទ្ធិសេរីភាព ឯករាជ្យជូនជាតិមាតុភូមិ

- ✓ បណ្តេញខ្មាំងសត្រូវ ដើម្បីភាពសុខសាន្តរបស់ជនរួមជាតិ
- ✓ គិតដល់ប្រយោជន៍ជាតិ មិនបារម្ភពីសេចក្តីស្លាប់
- ✓ រក្សាការពារទឹកដី វប្បធម៌ ប្រពៃណី ឱ្យគង់វង្ស

ឧទាហរណ៍៖

- ✓ ក្នុងប្រវត្តិសាស្ត្រ៖ សម្តេចព្រះសីហនុ ទាមទារឯករាជ្យជូនជាតិមាតុភូមិ...។
- ✓ ក្នុងអក្សរសិល្ប៍៖
  -រឿង តេជោយ៉ត ដឹកនាំទ័ពចេញទៅកម្ចាត់សត្រូវការពារប្រទេស
  -រឿង ភូមិតិរច្ឆានៈ ជូន និងនៅធ្វើពលិកម្ម ហ៊ានលះបង់ជីវិតដើម្បីបុព្វហេតុប្រទេសជាតិ...។
  -រឿង ព្រះវេស្សន្តរៈ ព្រះវេស្សន្តរហ៊ានលះបង់ទ្រព្យសម្បត្តិ...សង្គ្រោះមនុស្សជាតិ។

សរុបសេចក្តីមក៖

សំយោគមតិ៖ មតិស្រប និងមតិផ្ទុយសុទ្ធតែមានអំណះអំណាងដូចគ្នា និងសមហេតុសមផលរៀងខ្លួន។ ដោយមតិស្របសមហេតុផលម្យ៉ាង ព្រោះបុគ្គលខ្លះហ៊ានបូជាជីវិតលះបង់អ្វីគ្រប់យ៉ាងដើម្បីប្រយោជន៍មកដល់ខ្លួនតែម្នាក់ប៉ុណ្ណោះ។ រីឯមតិទីពីរកសមហេតុ

ផលជាងដោយឱ្យតម្លៃខ្ពស់ដល់វីរជនដែលហ៊ានធ្វើពលីកម្មបុព្វហេតុជាតិ សាសនា ទឹកដី និងប្រជាជន។

គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ...មតិប្រធានមិនទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយនៅឡើយទេ ព្រោះអ្នកដែលហ៊ានពលីកម្មមិនមែនសុទ្ធសឹងតែដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ ការលះបង់កជាឧត្តមគតិបុគ្គលជាច្រើនបានតស៊ូ លះបង់ដើម្បីប្រយោជន៍ផងដែរ។
- មតិស្នេហ៍៖..........................................................................។

# ឯកសារយោង


1. ក្រសួងអប់រំ ១៩៨៣ វេយ្យាករណ៍ខ្មែរ ថ្នាក់ទី៥
2. ក្រសួងអប់រំ យុវជន និងកីឡា ១៩៩៦ ភាសាខ្មែរ ថ្នាក់ទី៧
3. ព្រៃ សំបូរ ២០១៥ តែងសេចក្តី ថ្នាក់ទី១២
4. ឃិន ធី ២០១២ សរសេរតាមអាន និងតែងសេចក្តី ថ្នាក់ទី៧
5. សម្តេចព្រះសង្ឃរាជ ជួន ណាត ១៩៦៧ វចនានុក្រមខ្មែរ
6. យ៉ង់ កំស៊ាន ២០១៥ សរសេរតាមអាន និងតែងសេចក្តី ថ្នាក់ទី៨
7. ក្រសួងអប់រំ យុវជន និងកីឡា ២០១៧ វិធីសាស្ត្រនៃការសរសេរតែងសេចក្តី
8. ក្បួនសំរាប់ធ្វើតែងសេចក្តី រៀបរៀងដោយសាស្ត្រាចារ្យខ្មែរ ***លឹម សុខុម***
9. កម្រងតែងសេចក្តីខ្មែរ របស់លោក សរ សារុន ១៩៧២
10. [www.google/youtube-veang](www.google/youtube-veang) engksa.com



សត្វត្រយ៉ង ឬ ក្ងយក្ស ជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា។វាមានសម្បុរប្រផេះក្រម៉ៅ ជើងព័ណ៌ក្រហមព្រលែត ជំពុះរាងកោងខុបចុះ និង ប្រវែងជងខ្លួន ១០៦ សង់ទីម៉ែត្រ។វាចូលចិត្តរស់នៅក្នុងព្រៃរបោះស្ងួត មានតំបន់ដីសើមច្រើន (ទន្លេ បឹង ត្រពាំង)។ឯចំណីរបស់សត្វនេះគឺជាពពួកសត្វឆ្អឹងកងដែលរស់នៅក្នុងភក់រួមមាន សត្វជន្លេន ខ្យង ក្ដាមជាដើម។

**និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆាវ៉ា**